Public Disclosure Authorized

Public Disclosure Authorized

## ព្រះរាជាណាចក្រកម្ពុជា

# គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា(CASDP)

# ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច (IPPF)

រៀបចំដោយៈ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ក្រសួងអភិវឌ្ឍន៍ជនបទ
ក្រសួងធនធានទឹក និងឧតុនិយម
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ប្រទេសកម្ពុជា

**ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៨**

## មាតិកា


បញ្ជីពាក្យកាត់ .................... ii
សេចក្តីថ្លែងអំណរគុណ .................... iv
1.0 ការណែនាំអំពី IPPF .................... 1
1.1 គោលបំណងនៃ IPPF .................... 1
2.0 គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា .................... 1
2.1 គោលបំណងនៃការរៀបចំគម្រោង .................... 1
2.2 ការរៀបចំគម្រោង និងសមាសភាគ ដែលត្រូវបានស្នើឡើង .................... 1
2.3 អ្នកទទួលផលគម្រោង និងទីតាំងគម្រោង .................... 4
3.0 ក្របខ័ណ្ឌគោលនយោបាយ និងគតិយុត្ត ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច .................... 4
3.1 ច្បាប់ពាក់ព័ន្ធរបស់ប្រទេសកម្ពុជា .................... 4
3.1.1 រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា (១៩៩៣) .................... 4
3.1.2 ច្បាប់ភូមិបាល (២០០១) .................... 4
3.1.3 គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (២០០៩) 5
3.2 គោលនយោបាយស្តីពីការការពារផលប៉ះពាល់ ដែលពាក់ព័ន្ធរបស់ធនាគារពិភពលោក .................... 5
3.3 លិខិតុបករណ៍អន្តរជាតិ ដែលពាក់ព័ន្ធ .................... 6
4.0 ជនជាតិដើមភាគតិចនៅកម្ពុជា .................... 6
5.0 ជនជាតិដើមភាគតិចក្នុងតំបន់គម្រោង .................... 9
6.0 ផលប៉ះពាល់ ដែលគម្រោងអាចបង្កដល់ជនជាតិដើមភាគតិច .................... 9
7.0 វិធានការសម្រាលផលប៉ះពាល់ ដែលអាចមានសម្រាប់ហានិភ័យដែលបានកំណត់ ....................10
7.1 ការពិនិត្យរករត្តមានជនជាតិដើមភាគតិច ....................10
7.2 ការវាយតម្លៃលើហេតុប៉ះពាល់សង្គម ....................11
7.3 ដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ ....................12
7.4 ការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ....................13
8.0 ការរៀបចំស្ថាប័ន ....................14
9.0 ការរៀបចំការពិនិត្យតាមដាន និងការវាយតម្លៃ ....................15
10.0 យន្តការដោះស្រាយបណ្តឹងសារទុក្ខ ....................17
11.0 ការរៀបចំបង្ហាញព័ត៌មានអំពីផែនការអភិវឌ្ឍជនជាតិដើមភាគតិច ដែលត្រូវរៀបចំក្រោម IPPF ....................19
12.0 ថវិកា ....................19


## បញ្ជីតារាង


តារាងទី ១៖ ស្ថិតិប្រជាជនជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា .................... 9
តារាងទី ២៖ ក្រុមជនជាតិដើមភាគតិច ក្នុងតំបន់គម្រោងដែលបែងចែកតាមខេត្ត ....................9
តារាងទី ៣៖ ចំណាយប៉ាន់ប្រមាណសម្រាប់អនុវត្ត IPPF និងសកម្មភាពពាក់ព័ន្ធរបស់អនុគម្រោង. ....................206
តារាងទី ៤៖ ការវិភាគផលប៉ះពាល់សង្គមបឋម ....................40

# បញ្ជីពាក្យកាត់

| | | |
|---|---|---|
| BP | Bank Policy | គោលនយោបាយរបស់ធនាគារ |
| CASDP | Cambodia Agricultural Sector Diversification Project | គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា |
| CERD | International Convention on the Elimination of All Forms of Racial Discrimination | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ |
| CSO | Civil Society Organizations | អង្គការសង្គមស៊ីវិល |
| DRFI | Disaster Risk Financing and Insurance | ការផ្តល់ហិរញ្ញប្បទាន និងការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ |
| DRM | Disaster Risk Management | ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ |
| EIA | Executive Implementing Agency | ទីភ្នាក់ងារប្រតិបត្តិ និងអនុវត្ត |
| ESMF | Environmental and Social Management Framework | ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESMP | Environmental and Social Management Plan | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម |
| IAIA | International Association for Impact Assessment | សមាគមវាយតម្លៃផលប៉ះពាល់អន្តរជាតិ |
| ICCPR | International Convention on Civil and Political Rights | កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ICESCR | International Convention on Economic, Social and Cultural Rights | កតិកាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| IDA | International Development Association | សមាគមអភិវឌ្ឍន៍អន្តរជាតិ |
| IP | Indigenous Peoples | ជនជាតិដើមភាគតិច |
| IPDP | Indigenous Peoples Development Plan | ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច |
| IPO | Indigenous Peoples Organization | អង្គការជនជាតិដើមភាគតិច |
| IPPF | Indigenous Peoples Planning Framework | ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច |
| IRC | Inter-Ministerial Resettlement Committee | គណៈកម្មាធិការអន្តរក្រសួង ដោះស្រាយផលប៉ះពាល់ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MLMUPC | Ministry of Land Management, Urban Planning, and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MND | Ministry of National Defence | ក្រសួងការពារជាតិ |
| MOE | Ministry of Environment | ក្រសួងបរិស្ថាន |
| MPWT | Ministry of Public Works and Transportation | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NGO | Non-Governmental Organizations | អង្គការមិនមែនរដ្ឋាភិបាល |
| OP | Operational Policy | គោលនយោបាយប្រតិបត្តិ |
| PAD | Project Appraisal Document | ឯកសារវាយតម្លៃគម្រោង |
| PAH | Project Affected Households | គ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង |
| PAP | Project Affected People | ជនដែលរងផលប៉ះពាល់ដោយសារគម្រោង |
| PDRD | Provincial Department of Rural | មន្ទីរអភិវឌ្ឍន៍ជនបទ |

| | | |
|---|---|---|
| | Development | |
| RAP | Resettlement Action Plan | ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់/តាំងទីលំនៅសាជាថ្មី |
| SEO | Social and Environmental Safeguard Office | ការិយាល័យការពារផលប៉ះពាល់សង្គម និងបរិស្ថាន |
| SIA | Social Impact Assessment | ការវាយតម្លៃផលប៉ះពាល់សង្គម |
| SMMP | Social Management and Monitoring Plan | ផែនការគ្រប់គ្រង និងពិនិត្យតាមដានសង្គម |
| TA | Technical Assistance | ជំនួយបច្ចេកទេស |
| USD | United States Dollar | ដុល្លារសហរដ្ឋអាមេរិក |
| WB | World Bank | ធនាគារពិភពលោក |
| WBG | World Bank Group | ក្រុមធនាគារពិភពលោក |

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពីក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច (IPPF) នេះត្រូវបានរៀបចំឡើងជាផ្នែកមួយនៃគម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា (CASDP) ដែលត្រូវទទួលបានហិរញ្ញប្បទានពីក្រុមធនាគារពិភពលោក (WBG) តាមរយៈហិរញ្ញប្បទានកម្ចីពីសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) និងរាជរដ្ឋាភិបាលកម្ពុជា។ ក្របខ័ណ្ឌនេះត្រូវបានរៀបចំឡើង ដើម្បីធានាថាគម្រោងដែលទទួលហិរញ្ញប្បទានពីធនាគារ នឹងមិននាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានលើជនជាតិដើមភាគតិច និងជនជាតិភាគតិច ឬក្នុងករណីដែលពុំអាចបញ្ចៀសផលប៉ះពាល់បាន នឹងមានការកាត់បន្ថយផលប៉ះពាល់ទាំងនេះឱ្យនៅតិចជាអប្បបរមា សម្រាលផលប៉ះពាល់ទាំងនេះ និង/ឬផ្តល់សំណងសម្រាប់ផលប៉ះពាល់ទាំងនេះ។ ក្របខ័ណ្ឌនេះមានគោលបំណងលើកកម្ពស់អត្ថប្រយោជន៍ និងឱកាសអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់ជនជាតិដើមភាគតិច តាមបែបផែនដែលផ្តល់ភាពងាយស្រួលដល់ពួកគេ សមស្របទៅនឹងវប្បធម៌ និងមានលក្ខណៈបរិយាបន្ន។

របាយការណ៍នេះ ត្រូវបានរៀបចំ ដោយក្រុមរៀបចំគម្រោងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងធាតុចូលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិត ចាន់ ដារ៉ុង អគ្គនាយកបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ និងការសម្របសម្រួល ប្រកបដោយប្រសិទ្ធភាពជាមួយនាយកដ្ឋានពាក់ព័ន្ធនានាក្រោមចំណុះក្រសួងអភិវឌ្ឍន៍ជនបទ ជាពិសេសនាយកដ្ឋានជនជាតិភាគតិច, ឯកឧត្តមបណ្ឌិត ទី សុគន្ធ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាសហប្រធានក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក (TWGAW), និងលោក ចាន់ ស៊ីណាត អគ្គនាយករង អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងធនធានទឹក និងឧតុនិយម។ អ្នកនិពន្ធសូមសម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមធនាគារពិភពលោក ដែលបានផ្តល់ការគាំទ្រ ជាពិសេសលោកស្រី មុទិតា ចំរើន ប្រធានក្រុមការងារ និងជាអ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍ជនបទ, លោក Martin Lenihan អ្នកឯកទេសជាន់ខ្ពស់ផ្នែកការពារសង្គម, លោក ឡេង ប៊ុនឡុង អ្នកឯកទេសជាន់ខ្ពស់ផ្នែកការពារបរិស្ថាន, ទេព ម៉ាកាធី អ្នកឯកទេសផ្នែកការពារបរិស្ថាន និងលោក ងួន ភក្តី ទីប្រឹក្សាផ្នែកការពារសង្គម។

## 1.0 ការណែនាំអំពី IPPF

1. ឯកសារនេះគឺជាក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច (IPPF) សម្រាប់គម្រោងពិពិធកម្មវិស័យកម្មនៅកម្ពុជា (CASDP) ដែលត្រូវបានលើកស្នើឡើង និងរៀបចំ ដោយមានការសហការជាមួយក្រសួងកសិកម្ម រុក្ខាមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីទទួលបានហិរញ្ញប្បទាន ពីធនាគារពិភពលោក។

### 1.1 គោលបំណងនៃ IPPF

2. ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច អនុវត្តចំពោះគម្រោង CASDP ដែលនឹងទទួលបានជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសពីធនាគារពិភពលោក រៀបរាប់ពីគោលការណ៍ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចចិត្តអនុវត្តតាម ដើម្បីបញ្ចៀស ឬសម្រាលផលប៉ះពាល់អវិជ្ជមាន ដែលគម្រោង CASDP បង្កដល់ជនជាតិដើមភាគតិច។

## 2.0 គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា

### 2.1 គោលបំណងនៃការរៀបចំគម្រោង

3. គោលបំណងនៃការរៀបចំគម្រោង ដែលត្រូវបានស្នើឡើងនេះ គឺដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍសង្វាក់តម្លៃផលិតផលវិស័យកសិកម្ម ដែលមានលក្ខណៈពិពិធកម្ម នៅតាមទីតាំងភូមិសាស្ត្រមួយចំនួននៅកម្ពុជា និងផ្តល់ការឆ្លើយតបជាបន្ទាន់ ប្រកបដោយប្រសិទ្ធភាព ក្នុងករណីដែលមានវិបត្តិ ឬស្ថានភាពអាសន្ន ដែលបំពេញទៅតាមលក្ខណៈសមស្រប ដើម្បីទទួលបានការគាំទ្រពីគម្រោងនេះ។ ការវាស់វែងការសម្រេចគោលបំណងនៃការអភិវឌ្ឍគម្រោង នឹងត្រូវធ្វើឡើងដោយប្រើប្រាស់សូចនាករខាងក្រោម៖ (ក) ការកើនឡើងនូវតម្លៃលក់សរុបនៅកម្រិតកសិដ្ឋានដែលទទួលផល (ភាគរយ), (ខ) ការបង្កើនតម្លៃនៃការលក់សរុបរបស់សហគ្រាសកសិកម្ម ដែលទទួលផលពីគម្រោង (ភាគរយ), (គ) ភាគរយផលិតផលមិនមែនស្រូវអង្ករនៃបរិមាណផលិតកម្មសរុប ក្នុងតំបន់គោលដៅរបស់គម្រោង។

### 2.2 ការរៀបចំគម្រោង និងសមាសភាគ ដែលត្រូវបានស្នើឡើង

4. **ពិពណ៌នាអំពីគម្រោង៖** គម្រោង CASDP មានបួនសមាសភាគ ដូចតទៅ៖ (ក) ការផ្តល់លទ្ធភាពឱ្យមានការធ្វើពិពិធកម្មកសិកម្ម, (ខ) ការលើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងការគ្រប់គ្រងការត្រួតពិនិត្យគុណភាព, (គ) ការគ្រប់គ្រងគម្រោង និងការពិនិត្យតាមដាន និងវាយតម្លៃ និង (ឃ) ការឆ្លើយតបចំពោះស្ថានភាពអាសន្ន ជាយថាហេតុ។

5. គម្រោងដែលត្រូវបានស្នើឡើងនេះ ត្រូវបានតាក់តែងឡើង ដើម្បីបង្កើនឱកាសទីផ្សារ និងការធ្វើពិពិធកម្មកសិកម្ម ដោយប្រើប្រាស់អភិក្រមបែបបរិយាបន្ន ដោយអ្នកទទួលផលជាអ្នកដឹកនាំ។ គម្រោងនេះបែងចែកជាបីសមាសភាគ បូករួមនឹងសមាសភាគទី ៤ ដែលពុំមានការវិភាជន៍ធនធានទុក សម្រាប់ករណីដែលមានវិបត្តិ ឬស្ថានភាពអាសន្ន ដែលបំពេញទៅតាមលក្ខណៈវិនិច្ឆ័យសមស្រប ដើម្បីទទួលបានការគាំទ្រពីគម្រោង។ សមាសភាគទី ១ គឺជាផ្នែកដ៏ធំនៃការវិយោគទាំងនេះ ហើយគឺជាសមាសភាគដែលអនុវត្តជាម៉ូឌុល និងអាចពង្រីក និងកែសម្រួលឱ្យស្របទៅតាមទីតាំងភូមិសាស្ត្រ និងផលិតផល/សង្វាក់តម្លៃ។ សមាសភាគទី ២ ផ្តោតលើការពង្រឹងស្ថាប័ន និងបង្កើនផលជះរយៈពេលវែងនៃការវិនិយោគ ដែលធ្វើឡើងក្នុងសមាសភាគទី ១ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដោយធានានូវនិរន្តរភាព និងការពង្រីកអត្ថប្រយោជន៍ទូទាំងប្រទេសកម្ពុជា។

6. ការប្រមូលព័ត៌មានអំពីការគាំទ្រសង្វាក់តម្លៃ រួមនឹងជំនួយបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ និងសេវាហិរញ្ញវត្ថុក្រោមសមាសភាគទី ១ ផ្តោតការយកចិត្តទុកដាក់លើទំនាក់ទំនងដ៏ជិតស្និទ្ធរវាងការគាំទ្រផ្ទាល់ដល់កសិករ ក្រុមអ្នកផលិត និងអាជីវកម្មកសិកម្មខ្នាតតូច និងខ្នាតមធ្យមរបស់គម្រោង ជាមួយនឹងការវិនិយោគលើផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រ។ រាល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទាំងអស់ នឹងត្រូវអនុវត្តជាផ្នែកមួយនៃការគាំទ្រដល់អនុគម្រោង ដែលអាចបំពេញទៅតាមលក្ខណៈសម្បត្តិសមស្រប និងដែលមានទំនាក់ទំនងជាមួយនឹងក្រុមផលិតជាក់លាក់។

7. **សមាសភាគទី ១៖ ផ្តល់លទ្ធភាពឱ្យមានការធ្វើពិពិធកម្មកសិកម្ម។** សមាសភាគទី ១ នេះនឹងប្រើប្រាស់អភិក្រមសង្វាក់តម្លៃ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទៅតាមស្ថានភាពទីផ្សារ និងស្ថានភាពតម្រូវការ ដើម្បីកសាងនូវសង្វាក់តម្លៃ ដែលមានលក្ខណៈប្រកួតប្រជែង និងមានពិពិធភាព ដែលក្នុងនោះអង្គការអ្នកផលិត (POs) និងសមាជិករបស់អង្គការទាំងនេះ អាចទទួលបានទីផ្សារក្នុងស្រុក និងអន្តរជាតិ ដែលផ្តល់ឱ្យពួកគេនូវប្រាក់ចំណេញខ្ពស់ត្រលប់មកវិញ ហើយសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម អាចទទួលបានវត្ថុធាតុដើម ដែលកាន់តែមានគុណភាពជាប់ជាប្រចាំ ហើយក្នុងពេលជាមួយគ្នា បង្កើនសមត្ថភាពស្រូបយក និងសម្រេចស្តង់ដារ គុណភាព ដែលទីផ្សារត្រូវការ។ សមាសភាគនេះពោរពេញដោយការប្រកួតប្រជែង និងភាគច្រើនដឹកនាំ ដោយវិស័យឯកជន ដោយរដ្ឋាភិបាលបំពេញតួនាទីជាអ្នកសម្របសម្រួល។ ប៉ុន្តែ សមាសភាគនេះក៏នឹងផ្តល់ការគាំទ្រដល់រដ្ឋាភិបាល និងតួអង្គក្នុងវិស័យសាធារណៈ ក្នុងការផ្តល់សេវាចាំបាច់នានា ដូចជា ការផ្សព្វផ្សាយកសិកម្ម ដែលភ្ជាប់ទំនាក់ទំនងជាមួយនឹងទីផ្សារ និងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈល្អប្រសើរជាងមុន ដូចជា ផ្លូវជនបទ និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន (higher order irrigation infrastructure) ក្នុងករណីដែលពុំមានសេវាដែលផ្តល់ដោយវិស័យឯកជន ឬប្រជាពលរដ្ឋពុំអាចទទួលសេវា ដែលផ្តល់ដោយវិស័យឯកជនបាន។

8. ***សមាសភាគរង ១.១៖ ការគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការពិពិធកម្ម។*** សមាសភាគរងនេះ មានគោលបំណងផ្សព្វផ្សាយព័ត៌មានអំពីគម្រោងដល់តួអង្គពាក់ព័ន្ធនានា ផ្តល់ការគាំទ្រដល់ការបង្កើតក្រុមការងារ ការកំណត់រកឱកាសអាជីវកម្ម និងនិងការបំប្លែងឱកាសទាំងនេះជាផែនការពិពិធកម្ម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដូចជា ការរៀបចំសំណើអាជីវកម្ម (BPr) និងផែនការអាជីវកម្ម (BPl) ដែលមានប្រសិទ្ធភាព និងធ្វើការវាយតម្លៃ និងជ្រើសរើសសំណើ និងផែនការទាំងនោះ និងចុងក្រោយពង្រឹងសមត្ថភាពក្រុមអ្នកផលិតដែលបានជ្រើសរើស ព្រមទាំងសមាជិករបស់ក្រុមទាំងនោះ ព្រមទាំងសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម។ សមាសភាគរងនេះនឹងផ្តល់ហិរញ្ញប្បទានដល់៖ (ក) យុទ្ធនាការបង្កើនការយល់ដឹង និងការប្រមូលតួអង្គពាក់ព័ន្ធនានា ដើម្បីបង្កើតជាក្រុម, (ខ) ការរៀបចំ និងការវាយតម្លៃផែនការពិពិធកម្ម ដែលមានប្រសិទ្ធភាព និងសំណើអាជីវកម្ម ដែលអាចផ្តល់នូវប្រាក់ចំណេញ និង (គ) ការរៀបចំ និងការវាយតម្លៃផែនការពិពិធកម្មពេញលេញ រាប់បញ្ចូលទាំងផែនការអាជីវកម្ម សម្រាប់សំណើអាជីវកម្មដែលត្រូវបានជ្រើសរើស និង (ឃ) ការគាំទ្រដល់ការអភិវឌ្ឍផែនការអាជីវកម្ម។

9. ***សមាសភាគរង ១.២៖ ការផ្តល់ហិរញ្ញប្បទានដល់ការធ្វើពិពិធកម្មកសិកម្ម។*** ដើម្បីសម្រួលដល់ការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគលើសកម្មភាពផលិតកម្ម និងជំនួយបច្ចេកទេស ក្នុងសំណើធ្វើពិពិធកម្ម និងផែនការអាជីវកម្ម ដែលទទួលបានការអនុម័ត គម្រោងនេះនឹងបង្កើតនូវកម្មវិធីផ្តល់ឥណទាន (Credit Line) ដោយមានការបំពេញបន្ថែមដោយកម្មវិធីផ្គូរផ្គងជំនួយខ្នាតតូច។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ នឹងជួយសម្រេចគោលបំណងជារួមរបស់គម្រោង ពោលគឺការធ្វើពិពិធកម្មទៅរកដំណាំដែលមានតម្លៃខ្ពស់ និងការធ្វើពាណិជ្ជភាវូបនីយកម្មវិស័យកសិកម្ម។ ដូច្នេះ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះនឹងផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគច្រើនប្រភេទពាក់ព័ន្ធនឹងការធ្វើពិពិធកម្មកសិកម្ម ដូចជា ឧបករណ៍កែច្នៃ ឧបករណ៍ធារាសាស្ត្រក្នុងកសិដ្ឋាន (ឧបករណ៍ស្រោចស្រពបែបបន្តក់ទឹក (drip) យន្តហោះខ្នាតតូច (microject) ប្រព័ន្ធបាចទឹក (sprinkler) ឃ្លាំងរក្សាកសិផលក្នុងកសិដ្ឋាន ។ល។) គ្រឿងយន្តកសិកម្ម ឃ្លាំង (ត្រជាក់) យានយន្ត ឧបករណ៍សម្រាប់វេចខ្ចប់ និងធ្វើពាណិជ្ជកម្ម ដំណោះស្រាយប្រព័ន្ធបច្ចេកវិទ្យានិងសារគមនាគមន៍ ធនធានកសិកម្ម និងការវិនិយោគសមស្របផ្សេងទៀត។

10. ***សមាសភាគរង ១.៣៖ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។*** គម្រោងនេះនឹងគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធ សាធារណៈ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលមិននៅជាប់ជាមួយនឹងកសិដ្ឋាន និងផ្លូវជនបទ ដើម្បីបង្កើន លទ្ធភាពរបស់ក្រុមអ្នកផលិតក្នុងការធ្វើពិពិធកម្មការដាំដុះរបស់ខ្លួន តាមរយៈការបង្កើនការផ្គត់ផ្គង់ទឹកទៅតាមតម្រូវការជាក់ស្តែង និងដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារប្រកបដោយប្រសិទ្ធភាព ដែលអាចជួយពន្លឿនការផ្គត់ផ្គង់ និងកាត់បន្ថយការខាតបង់ឱ្យនៅតិចជាអប្បបរមា។

11. **សមាសភាគទី ២៖ លើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងការគ្រប់គ្រងការត្រួតពិនិត្យគុណភាព។** គោលបំណងនៃសមាសភាគទី ២ នេះ គឺដើម្បីពង្រឹងចំណេះដឹងជាមូលដ្ឋាន សមត្ថភាពវិភាគទិន្នន័យ និងប្រព័ន្ធអនុវត្តលិខិតបទដ្ឋានគតិយុត្តិក្នុងវិស័យសាធារណៈ ព្រមទាំងការអនុវត្ត និងការពង្រឹងការអនុវត្តប្រព័ន្ធទាំងនេះ។ ការងារទាំងនេះនឹងរួមចំណែកពង្រីក និងបង្កើនតម្លាភាពចំណេះដឹង ព្រមទាំងកែលម្អការធ្វើសេចក្តីសម្រេចចិត្តរបស់តួអង្គក្នុងវិស័យសាធារណៈ និងវិស័យឯកជន ដែលផលសម្រេចបាននឹងមានវិសាលភាពលើសពី

អនុគម្រោង PA ដែលបានទទួលការគាំទ្រទៅទៀត។ ប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងគុណភាពកសិកម្ម នឹងផ្តល់ប្រយោជន៍ដល់អ្នកពាក់ព័ន្ធផ្ទាល់ ក៏ដូចជា កសិករ ក្រុមអ្នកផលិត និងសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម ដែលកំពុងប្រតិបត្តិការនៅក្នុងឃុំ និងខេត្តផ្សេងទៀត ក្រៅតែពីតំបន់គម្រោងផងដែរ។ សមាសភាគនេះក៏នឹងផ្តល់ហិរញ្ញប្បទានដល់ការងារវិភាគ និងផ្តល់ប្រឹក្សាគោលនយោបាយ ដើម្បីតម្រង់ទិសការវិនិយោគរបស់រដ្ឋាភិបាលក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម។

12. ***សមាសភាគរង ២.១៖ ប្រព័ន្ធព័ត៌មានកសិកម្ម។*** នឹងមានការផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគលើការបន្តអភិវឌ្ឍន៍ និងលើកកម្ពស់ការប្រើប្រាស់ផែនទីដី/ក្បេត្របរិស្ថាន ប្រព័ន្ធផ្តល់ព័ត៌មានទាន់ពេលវេលាពាក់ព័ន្ធនឹងកសិកម្ម ស្ថិតិផលិតកម្មអាហារ និងកសិកម្ម/ទិន្នន័យជំរឿន (ព័ត៌មានទីផ្សារកសិកម្ម និងប្រព័ន្ធព័ត៌មានទីផ្សារ) និងទិន្នន័យដទៃទៀត។ បច្ចេកវិទ្យា ICT ថ្មីៗ នឹងត្រូវយកមកប្រើប្រាស់ ដើម្បីធានាឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយបំផុត និងការប្រើប្រាស់ឱ្យបានល្អបំផុតនូវទិន្នន័យ និងព័ត៌មានដែលមាន សម្រាប់ការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្តរបស់តួអង្គពាក់ព័ន្ធក្នុងវិស័យសាធារណៈ និងវិស័យឯកជនពាក់ព័ន្ធនឹងផលិតកម្ម ការកែច្នៃ ការស្វែងរកទីផ្សារផលិតផលកសិកម្ម និងសេវាកម្ម។ លើសពីនេះក៏នឹងមានការគាំទ្រដល់ការប្រមូលព័ត៌មានទីផ្សារ ដើម្បីកំណត់រកឱកាសរយៈពេលមធ្យម និងរយៈពេលវែងសម្រាប់ផលិតផលសមស្របផងដែរ។នឹងមានការផ្តល់ថវិកា សម្រាប់ផ្តល់ព័ត៌មានឱ្យចំក្រុមគោលដៅ ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្របថ្មីៗ ដើម្បីផ្តល់ព័ត៌មានដល់កសិករជាស្ត្រីចូលរួមក្នុងគម្រោង ដែលមានលទ្ធភាពតិចតួច ដើម្បីយល់ពីឯកសារជាលាយល័ក្ខណ៍អក្សរ។ ការផ្សព្វផ្សាយព័ត៌មាន នឹងបញ្ចូលសារអប់រំ ពាក់ព័ន្ធនឹងអាហារូបត្ថម្ភ និងឯកសារនានា ពាក់ព័ន្ធនឹងការពង្រឹងលទ្ធផលអាហារូបត្ថម្ភរបស់គម្រោង។

13. ***សមាសភាគរង ២.២ ការគ្រប់គ្រងគុណភាព។*** ការវិនិយោគ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការការពាររុក្ខជាតិ និងភូតគាមអនាម័យ សុខភាពសត្វ និងការឃ្លាំមើលភូតគាមអនាម័យសុខភាពសត្វ និងសុវត្ថិភាពអាហារ ប្រព័ន្ធរាយការណ៍ និងប្រព័ន្ធអធិការកិច្ច ហើយនឹងមានការគាំទ្រដល់ប្រព័ន្ធពង្រឹងការអនុវត្តការគ្រប់គ្រងលើវត្ថុធាតុដើមកសិកម្ម។ ការគាំទ្រនេះ រួមមានការគាំទ្រដល់ការបង្កើតសេវាចេញវិញ្ញាបនបត្រ ផ្តល់អាជ្ញាប័ណ្ណ និងត្រួតពិនិត្យ និងគ្រប់គ្រងគុណភាពផ្សេងទៀត ព្រមទាំងការរៀបចំ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តអំពីការអនុវត្តល្អផ្នែកកសិកម្ម (GAP) និងការអនុវត្តល្អផ្នែកផលិតផលសរីរាង្គ ការចិញ្ចឹមសត្វ និងការប្រើប្រាស់ព័ត៌មានសម្គាល់ភូមិសាស្ត្រ។ល។

14. **សមាសភាគទី ៣៖ ការគ្រប់គ្រងគម្រោង និងការពិនិត្យតាមដាន និងវាយតម្លៃ។** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាទីភ្នាក់ងារប្រតិបត្តិចម្បង សម្រាប់អនុវត្ត និងគ្រប់គ្រងការសម្របសម្រួលជារួម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងទទួលខុសត្រូវគ្រប់គ្រងការសម្របសម្រួលជារួម និងអនុវត្តសមាសភាគទាំង៤។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គភាពបច្ចេកទេសនៃក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ដែលជាដៃគូអនុវត្តទទួលខុសត្រូវលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ជនបទ។ នឹងមានការគាំទ្រដល់ការបង្កើតក្រុមសម្របសម្រួលគម្រោង និងគាំទ្រការអនុវត្តក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលស្ថិតនៅជាមួយលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក។ ការបង្កើតគណៈកម្មាធិការដឹកនាំកម្រិតខ្ពស់ នឹងត្រូវធ្វើឡើងផងដែរ ដើម្បីផ្តល់ដំបូន្មាន និងដោះស្រាយបញ្ហាអន្តរវិស័យ ដែលកើតឡើងថ្មីៗ។ ព័ត៌មានលំអិត នឹងត្រូវរៀបរាប់ ក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង។

15. ***សមាសភាគទី ៤៖ សមាសភាគឆ្លើយតប ចំពោះស្ថានភាពអាសន្នជាយថាហេតុ*** គោលបំណងនៃ សមាសភាគឆ្លើយតបចំពោះស្ថានភាពអាសន្នជាយថាហេតុ ដែលមានការវិភាជន៍ថវិកាបណ្តោះអាសន្នស្មើសូន្យនេះ គឺដើម្បីផ្តល់លទ្ធភាពឱ្យមានការវិភាជន៍ថវិកាឡើងវិញទៅតាមយន្តការឆ្លើយតបបន្ទាន់របស់ IDA សំដៅផ្តល់ការឆ្លើយតបបន្ទាន់ ចំពោះវិបត្តិ ឬស្ថានភាពអាសន្ន ទៅតាមការចាំបាច់។ សៀវភៅណែនាំស្តីពីការឆ្លើយតបចំពោះ ស្ថានភាពអាសន្ន (ERM) នឹងត្រូវរៀបចំឡើង សម្រាប់សកម្មភាពនានា ក្រោមសមាសភាគនេះ ដោយរៀបរាប់លម្អិតពីការរៀបចំសម្រួលនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម ការការពារផលប៉ះពាល់ និងការរៀបចំការអនុវត្តចាំបាច់ផ្សេងទៀត។ ក្នុងករណីដែលត្រូវអនុវត្តសមាសភាគនេះ នឹងមានការកែសម្រួលក្របខ័ណ្ឌលទ្ធផល ដោយធ្វើការរៀបចំរចនាសម្ព័ន្ធផ្លូវការសារជាថ្មី ដើម្បីបញ្ចូលសូចនាករសមស្របពាក់ព័ន្ធនឹងសកម្មភាពឆ្លើយតប ចំពោះស្ថានភាពអាសន្ន។

## 2.3 អ្នកទទួលផលគម្រោង និងទីតាំងគម្រោង

16. **ទីតាំងភូមិសាស្ត្រគោលដៅ៖** គម្រោងនេះនឹងអនុវត្តក្នុងខេត្តចំនួន ១២ បូករួមទាំងទីក្រុងភ្នំពេញ។ ខេត្តទាំងនេះត្រូវបានជ្រើសរើស ដោយសារស្ថានភាពកេ្សត្របរិស្ថានសមស្រប សម្រាប់ផលិតផល ដែលមានតម្លៃខ្ពស់ ដោយទីក្រុងភ្នំពេញ គឺជាទីតាំង ដែលអាចមានសហគ្រាសកសិកម្មខ្នាតតូចជាច្រើនមានលទ្ធភាពចូលរួម។ ខេត្តទាំងនេះ រួមមាន បាត់ដំបង មណ្ឌលគិរី ស្ទឹងត្រែង រតនគិរី ព្រះវិហារ កំពង់ចាម កំពង់ធំ ក្រចេះ សៀមរាប កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង និងភ្នំពេញ។ នៅតាមបណ្តាខេត្តទាំងនេះ គេរំពឹងថាទីតាំងគម្រោង ដែលបំពេញតាមលក្ខណៈសម្បត្តិសមស្រប នឹងស្ថិតនៅតាមតំបន់ ដែល (i) មានក្រុមអ្នកផលិតសកម្មដែលបានចងក្រងគ្នាជាក្រុមរួចជាស្រេច, (ii) មានទឹកប្រើប្រាស់ច្រើនរដូវក្នុងកម្រិតអាចជឿទុកចិត្តបាន និង (iii) មានផ្លូវតូចៗ ដែលមានស្រាប់ ដែលមានប្រវែងអតិបរមា ១០ គីឡូម៉ែត្រ សម្រាប់ភ្ជាប់ជាមួយនឹងផ្លូវដែលអាចប្រើប្រាស់បានគ្រប់រដូវ។

17. **អ្នកទទួលផលគោលដៅ៖** អ្នកទទួលផលផ្ទាល់ពីគម្រោងនេះ រួមមាន កសិករខ្នាតតូច និងខ្នាតមធ្យម ដែលត្រូវបានចងក្រងជាក្រុមអ្នកផលិត ឬជាសហគមន៍ និងបង្ហាញពីសក្តានុពល និងចំណាប់អារម្មណ៍ចង់អភិវឌ្ឍន៍ អាជីវកម្មកសិកម្មរបស់ពួកគេ និងអាជីវកម្មកសិកម្មខ្នាតតូច និងខ្នាតមធ្យម ដែលចាប់អារម្មណ៍ចង់សហការដោយផ្ទាល់ជាមួយកសិករ ដើម្បីរួមគ្នាអភិវឌ្ឍន៍អាជីវកម្ម/សង្វាក់តម្លៃរបស់ខ្លួន។ គម្រោងក៏នឹងមានការផ្តល់ព័ត៌មាន សម្ភារៈ និងយុទ្ធនាការឱ្យចំក្រុមគោលដៅដែលជាកសិករស្ត្រី និងម្ចាស់អាជីវកម្មផងដែរ ។ អ្នកទទួលផលដោយប្រយោលផ្សេងទៀត រួមមាន អ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវបានកែសម្រួលសម្រាប់លើកកម្ពស់ការភ្ជាប់ទំនាក់ទំនងជាមួយទីផ្សារ ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ។ ការបង្កើនភាពអាចរកបាននូវទិន្នន័យ និងព័ត៌មាន និងលទ្ធភាពទទួលបានទិន្នន័យ និងព័ត៌មានទាំងនេះ ព្រមទាំងយន្តការធានាគុណភាព (ដូចជា ក្របខ័ណ្ឌនិយតកម្មហេដ្ឋារចនាសម្ព័ន្ធ) នឹងផ្តល់ជាប្រយោជន៍ដល់វិស័យទាំងមូល។

# 3.0 ក្របខ័ណ្ឌគោលនយោបាយ និងគតិយុត្ត ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច

## 3.1 ច្បាប់ពាក់ព័ន្ធរបស់ប្រទេសកម្ពុជា

### 3.1.1 រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា (១៩៩៣)

18. រដ្ឋធម្មនុញ្ញកម្ពុជា (១៩៩៣) ធានាសិទ្ធិដូចគ្នា សម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដោយមិនគិតពីជាតិសាសន៍ ព័ត៌សម្បុរ ភាសា និងជំនឿសាសនា។ រាជរដ្ឋាភិបាលកម្ពុជា ក៏ទទួលស្គាល់ពីសារៈសំខាន់នៃសង្គមកម្ពុជា ដែលមានវប្បធម៌ចម្រុះក្នុងកម្មវិធីនយោបាយ សម្រាប់នីតិកាលទី ៣ នៃរដ្ឋសភាផងដែរ។

19. មាត្រា ៣១ ចែងថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។

### 3.1.2 ច្បាប់ភូមិបាល (២០០១)

20. ច្បាប់ភូមិបាល (២០០១) នៃប្រទេសកម្ពុជាផ្តល់កម្មសិទ្ធិដីសមូហភាពដល់ជនជាតិដើមភាគតិច។ មាត្រា ២៥ ចែងថា កម្មសិទ្ធិនៃអចលនវត្ថុ ត្រូវបានផ្តល់ដោយរដ្ឋ ជូនសហគមន៍ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពរួមមាន រាល់សិទ្ធិ និងការការពារកម្មសិទ្ធិ ដូចកម្មសិទ្ធិឯកជនដែរ។ ការអនុវត្តសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនទ្រព្យរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដី ត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរ ប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់របស់ពួកគេ ហើយត្រូវដាក់ឱ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅ ទាក់ទងនឹងអចលនទ្រព្យ ដូចជា ច្បាប់ការពារបរិស្ថានជាដើម (មាត្រា ២៦)។

21. ក្នុងមាត្រា ២៣ សហគមន៍ជនជាតិដើមភាគតិច ត្រូវបានឱ្យនិយមន័យថាជា "ក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដី ដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព”។

### 3.1.3 គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (២០០៩)

22. គោលនយោបាយនេះ ជំរុញឱ្យមានការប្រើប្រាស់ភាសាមូលដ្ឋាន ក្នុងការអប់រំពហុភាសានៅកម្រិតបឋមសិក្សា ប្រព័ន្ធផ្សព្វផ្សាយ និងក្នុងកិច្ចពិគ្រោះយោបល់សាធារណៈនានា។ គោលនយោបាយនេះ ដាក់ចេញនូវយុទ្ធសាស្ត្រសង្ខេបចំនួន ១០ ផ្តោតលើវប្បធម៌, ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, សុខភាព, បរិស្ថាន, ដីធ្លី, កសិកម្ម, ធនធានទឹក, ហេដ្ឋារចនាសម្ព័ន្ធ, យុត្តិធម៌ និងឧស្សាហកម្ម រ៉ែ និងថាមពល។ លើសពីនេះ យុទ្ធសាស្ត្រនេះ ក៏អំពាវនាវឱ្យមានការវាយតម្លៃលើហេតុប៉ះពាល់ សម្រាប់គ្រប់គម្រោងហេដ្ឋារចនាសម្ព័ន្ធទាំងអស់ផងដែរ។

23. ស្របតាមគោលនយោបាយនេះ ក្រសួង និងស្ថាប័នរដ្ឋាភិបាលទទួលស្គាល់ថា ដីដែលកាន់កាប់ និងប្រើប្រាស់ដោយសហគមន៍ជនជាតិដើមភាគតិចទៅតាមទំនៀមទម្លាប់របស់ពួកគេ ដូចជា ដីលំនៅដ្ឋាន និងដីដែលប្រើប្រាស់សម្រាប់ការដាំដុះបែបពនេចរ ការដាំដំណាំវិលជុំ ដីកប់សព ដីអារក្សអ្នកតា។ រាជរដ្ឋាភិបាលកម្ពុជាក៏ទទួលស្គាល់ពីការដាំដុះបែបប្រពៃណី ព្រមទាំងការប្រមូលធនធានធម្មជាតិផ្សេងៗ របស់ជនជាតិដើមភាគតិចផងដែរ តាមរយៈការអភិវឌ្ឍផលិតកម្មកសិកម្ម ដើម្បីធានានូវសុវត្ថិភាពអាហារ ក៏ដូចជា បង្កើតគុណភាពអាហាររូបត្ថម្ភ និងចំណូលរបស់គ្រួសារ។

## 3.2 គោលនយោបាយស្តីពីការការពារផលប៉ះពាល់ ដែលពាក់ព័ន្ធរបស់ធនាគារពិភពលោក

24. គេរំពឹងថា ការអនុវត្តអនុគម្រោង និងសកម្មភាពនានា ក្រោមហិរញ្ញប្បទានរបស់គម្រោងនេះ នឹងបង្កឱ្យមានផលប៉ះពាល់សង្គមនៅកម្រិត និងវិសាលភាពផ្សេងៗគ្នា អាស្រ័យទៅតាមទំហំ និងទីតាំងនៃសកម្មភាពទាំងនោះ ដែលពុំទាន់ត្រូវបានកំណត់លម្អិតនៅឡើយ។

25. គោលនយោបាយស្តីពីការការពារផលប៉ះពាល់លើជនជាតិដើមភាគតិច (OP/BP 4.10) ត្រូវយកមកអនុវត្តចំពោះអនុគម្រោង និងសកម្មភាពបណ្តុះបណ្តាលនានា ដោយហេតុថាជនជាតិភាគតិច អាចរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល ដូច្នេះ សកម្មភាពទាំងនេះ ត្រូវអនុវត្តទៅតាមលក្ខណៈវិនិច្ឆ័យស្តីពីភាព សមស្របនៃគោលនយោបាយ OP/BP 4.10។

26. គោលនយោបាយនេះទទួលស្គាល់ថា អត្តសញ្ញាណ និងវប្បធម៌ពិសេសរបស់ជនជាតិដើមភាគតិច នៅតែមានទំនាក់ទំនងពុំអាចកាត់ផ្តាច់បាន ជាមួយនឹងដី ដែលពួកគេកំពុងរស់នៅ និងធនធានធម្មជាតិ ដែលពួកគេពឹងអាស្រ័យលើ ដើម្បីរស់រាន។ គោលនយោយបាយ OP/BP 4.10 ត្រូវបានរៀបចំឡើង ដើម្បីធានាថា គម្រោងដែលទទួលបានហិរញ្ញប្បទានពីធនាគារ នឹងមិននាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានលើជនជាតិដើមភាគតិច និងជនជាតិភាគតិច ឬនៅពេលដែលការបញ្ចៀសផលប៉ះពាល់ទាំងនេះ មិនអាចធ្វើទៅបាន ត្រូវមានការកាត់បន្ថយឱ្យនៅជាអប្បបរមា សម្រាល និង/ឬផ្តល់សំណងសម្រាប់ផលប៉ះពាល់ទាំងនេះ។ គោលនយោបាយនេះមានគោលបំណងលើកកម្ពស់អត្ថប្រយោជន៍ និងឱកាសដែលបានពីការអភិវឌ្ឍប្រកបដោយចីរភាពដល់ជនជាតិដើមភាគតិច តាមបែបផែន ដែលផ្តល់ភាពងាយស្រួលដល់ពួកគេ សមស្របទៅនឹងវប្បធម៌របស់ពួកគេ និងមានលក្ខណៈបរិយាបន្ន។ គោលនយោបាយ OP/BP 4.10 កំណត់នូវលក្ខខណ្ឌតម្រូវ ដូចតទៅ៖ ការពិនិត្យរកផលប៉ះពាល់ ការវាយតម្លៃសង្គម កិច្ចពិគ្រោះយោបល់ជាមួយសហគមន៍ដែលពាក់ព័ន្ធ ការរៀបចំផែនការ ឬក្របខ័ណ្ឌ និងការបង្ហាញព័ត៌មាន។ គោលនយោបាយនេះ ក៏តម្រូវឱ្យអ្នកខ្ចីកម្ចីស្វែងរកការគាំទ្រពីសហគមន៍ជនជាតិដើមភាគតិច តាមរយៈដំណើរការពិគ្រោះយោបល់ ដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ មុនពេលធ្វើការសម្រេចចិត្តរៀបចំអនុគម្រោងអ្វីមួយ ដែលជ្រើសរើសជនជាតិដើមភាគតិចជាក្រុមគោលដៅ ឬបង្កផលប៉ះពាល់ដល់ជនជាតិដើមភាគតិច និងត្រូវបន្តរក្សាទំនាក់ទំនងផ្អែកតាមកិច្ចពិគ្រោះយោបល់ ប្រកបដោយអត្ថន័យ ជាមួយនឹងជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ក្នុងវដ្តនៃអនុគម្រោងទាំងមូល។ ចុងក្រោយ គោលនយោបាយ OP/BP 4.10 មានគោលបំណងទទួលស្គាល់ គោរព និងការពារវប្បធម៌ ចំណេះដឹង និងទម្លាប់របស់ជនជាតិដើមភាគតិច ព្រមទាំងផ្តល់ឱ្យពួកគេនូវឱកាសសម្របខ្លួនទៅតាមការផ្លាស់ប្តូរស្ថានភាព តាមបែបផែន និងតាមពេលវេលា ដែលពួកគេអាចទទួលយកបាន។

27. គោលនយោបាយ OP/BP 4.10 ពុំបានកំណត់និយមន័យ "ជនជាតិដើមភាគតិច" នោះឡើយ ដោយហេតុថា ពុំមាននិយមន័យ ដែលត្រូវបានទទួលស្គាល់ជាសកលនោះឡើយ។ សម្រាប់គោលបំណងនៃគោលនយោបាយនេះ ពាក្យថា "ជនជាតិដើមភាគតិច" ត្រូវបានប្រើប្រាស់ក្នុងន័យទូទៅ ដើម្បីសំដៅលើក្រុម សង្គម និងវប្បធម៌ពិសេស និងងាយរងគ្រោះ ដែលមានលក្ខណៈខាងក្រោម ក្នុងកម្រិតខុសៗគ្នា៖

ក) កំណត់អត្តសញ្ញាណដោយខ្លួនឯងថាជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើមភាគតិចពិសេស និងមានការទទួលស្គាល់អត្តសញ្ញាណនេះ ដោយក្រុមផ្សេងទៀត

ខ) ទំនាក់ទំនងជាសមូហភាពជាមួយនឹងទីកន្លែងរស់នៅដែលមានលក្ខណៈភូមិសាស្ត្រពិសេស ឬដែនដីបុព្វបុរសក្នុងតំបន់អនុគម្រោង និងជាមួយធនធានធម្មជាតិនៅក្នុងដែនជម្រក និងដែនដីទាំងនេះ

គ) ស្ថាប័នវប្បធម៌ សេដ្ឋកិច្ច សង្គម ឬនយោបាយ បែបទំនៀមទម្លាប់ មានលក្ខណៈដាច់ដោយឡែកពីស្ថាប័ននៃសង្គម និងវប្បធម៌ទូទៅ និង

ឃ) ភាសាជនជាតិដើមភាគតិច ជារឿយៗ មានលក្ខណៈខុសប្លែកពីភាសាផ្លូវការ ដែលប្រើប្រាស់ក្នុងប្រទេស ឬតំបន់។

28. គោលនយោបាយ OP/BP 4.10 ក៏អនុវត្តចំពោះសហគមន៍ ឬក្រុមជនជាតិដើមភាគតិច ដែលក្នុងអំឡុងពេលរស់នៅរបស់សមាជិកសហគមន៍ ឬក្រុម បានបាត់បង់ទំនាក់ទំនងជាសមូហភាពជាមួយនឹងដែនជម្រកពិសេស ឬដែនដីបុព្វបុរសក្នុងតំបន់អនុគម្រោង ដោយសារតែការបង្ខំឱ្យកាត់ផ្ដាច់ទំនាក់ទំនងបែបនេះ ឬដោយសារទំនាស់ កម្មវិធីផ្លាស់ប្តូរទីលំនៅរបស់រដ្ឋាភិបាល ការដកហូតដីធ្លីរបស់ពួកគេ គ្រោះមហន្តរាយធម្មជាតិ ឬការបញ្ចូលដែនដីទាំងនេះទៅក្នុងតំបន់ប្រជុំជនជាដើម។ គោលនយោបាយនេះក៏អនុវត្តចំពោះអ្នករស់នៅក្នុងព្រៃ អ្នកបរបាញ់សត្វ អ្នកចិញ្ចឹមសត្វលើវាលស្មៅ ឬក្រុមពនេចរដទៃទៀត អាស្រ័យទៅតាមការបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការពិចារណាពិសេស ដូចមានចែងក្នុងកថាខណ្ឌ១៦ នៃគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច (OP/BP 4.10)។

### 3.3 លិខិតុបករណ៍អន្តរជាតិ ដែលពាក់ព័ន្ធ

29. ប្រទេសកម្ពុជាគឺជាហត្ថលេខីនៃលិខិតុបករណ៍អន្តរជាតិជាច្រើន ដែលការពារសិទ្ធិជនជាតិដើមភាគតិច។ លិខិតុបករណ៍ទាំងនេះ រួមមាន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR), កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR) និងកតិកាសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD)។ ប្រទេសកម្ពុជា ក៏ជាភាគីនៃអនុសញ្ញាស្តីពីភាពចម្រុះខាងជីវសាស្ត្រ (១៩៩២) ដែលទទួលស្គាល់ពីតួនាទីរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការការពារជីវចម្រុះផងដែរ។

## 4.0 ជនជាតិដើមភាគតិចនៅកម្ពុជា

30. ប្រទេសកម្ពុជាមានប្រជាជន ១៦,៣ លាននាក់[1] ដែលក្នុងនោះ ៩០% ជាជនជាតិខ្មែរ។ ប្រជាពលរដ្ឋដែលនៅសល់ ១០% ទៀត គឺជាជនជាតិភាគតិច ដូចជា ជនជាតិចាម ចិន វៀតណាម និងក្រុមជនជាតិដើមភាគតិចចំនួន ១៧ ក្រុម ដែលគេហៅម្យ៉ាងទៀតថា "ខ្មែរលើ" ឬ "កុលសម្ព័ន្ធភ្នំ" ជាជនជាតិភាគតិច និងពុំមែនជាជនជាតិខ្មែរ។ គេបាន់ប្រមាណថាក្រុមទាំងនេះ មានសមាជិកប្រមាណ ២៦៤.៦០០ នាក់ ស្មើនឹងប្រមាណ ៤% នៃចំនួនប្រជាជនកម្ពុជា។ ជនជាតិដើមភាគតិចមាន ២៤ ក្រុម ដែលមានសមាជិកចាប់ពី ១៥ នាក់ រហូតដល់ ៤១.៣២១ នាក់ ដូចបង្ហាញក្នុងតារាងទី ១ ខាងក្រោម។ ក្រុមជនជាតិដើមភាគតិច គឺជាក្រុមភាគច្រើនក្នុងខេត្តរតនគិរី (៤១,៧%) និងមណ្ឌលគិរី (១៤,៤%)។ ក្រោមគម្រោង CASDP និងសម្រាប់គោលបំណងនៃគោលនយោបាយ OP 4.10 ស្តីពីជនជាតិដើមភាគតិចរបស់ធនាគារពិភពលោក មានតែក្រុមជនជាតិភាគតិចដែលត្រូវបានចាត់ទុកថាជា "ខ្មែរលើ" ឬ "កុលសម្ព័ន្ធភ្នំ" ប៉ុណ្ណោះ ដែលត្រូវបានចាត់ទុកថាជាជនជាតិដើមភាគតិច។

[1] ប្រភព៖ ប្រព័ន្ធទិន្នន័យ MFMOD ខែ ឧសភា ឆ្នាំ ២០១៨

**តារាងទី ១៖** ស្ថិតិប្រជាជនជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា

| lr | CnCati | rtnKirI | mNÐlKirli | RkecH | RBHvihar | kMBg;FM | sÞwgERtg | ]>m>C½y | kMBg;cam | eBaFi_sat; | kMBg;s<W | b>m>C½y | )at;dMbg | RBHslhnu | esomrab | srub |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | kYy | | | 5,939 | 16,731 | 13,044 | 1,644 | 2,203 | | | | 1,712 | 8 | | | 41,321 |
| 2 | Bñg | 267 | 26,866 | 12,454 | 24 | | 430 | 699 | | | | | 3 | | | 40743 |
| 3 | TMBYn | 31,088 | 388 | | 5 | | 4 | 281 | | | | | 16 | | | 31,782 |
| 4 | Caray | 20,170 | 84 | | | | 12 | 158 | | | | | 14 | | | 20,438 |
| 5 | RKwg | 18,442 | 57 | | | | 278 | 124 | | | | | | | | 18,901 |
| 6 | esÞog | | 648 | 10,593 | | | | 27 | 2,564 | | | | | | | 13,832 |
| 7 | eRBA | 7,968 | | | | | 444 | | | | | | | | | 8,412 |
| 8 | kaEvt | 2,379 | | | | | 2,710 | 18 | | | | | | | | 5,107 |
| 9 | eRkal | | 659 | 3,411 | | | | 29 | | | | | | | | 4,099 |
| 10 | mil | | | 3,172 | | | | | | | | | | | | 3,172 |
| 11 | kack; | 2,887 | | | | | 1 | 52 | | | | | | | | 2,940 |
| 12 | B½r | | | | 1,329 | | | | | 1,207 | | | | | | 2,536 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 13 | exaj | | | 1,529 | | | | | | | | | 433 | | | 1,982 |
| 14 | Cg | | | | | | | | | 774 | | | | | | 1,838 |
| 15 | sYy | | | | | | | | | | 1,833 | | | | | 1,833 |
| 16 | fµÜn | | 148 | 448 | | | | 5 | | | | | | | | 601 |
| 17 | Lun | 289 | | | | | 251 | | | | | | | | | 540 |
| 18 | s¥Úc | | | | | | | | | | | | | 106 | | 106 |
| 19 | rEd | 2 | | | | | | 16 | | | | | | | | 18 |
| 20 | Xi | | | | | | | 15 | | | | | | | | 15 |
| 21 | rGg | | | | | | | | | | | | | | | 0 |
| 22 | sþúg | | | | | | | | | | | | | | | 0 |
| 23 | l¥Wn | | | | | | | | | | | | | | | 0 |
| 24 | sMEr | | | | | | | | | | | | | | | 0 |
| | **srub** | **83,492** | **28,850** | **37,566** | **18,089** | **13,044** | **5,774** | **3,627** | **2,564** | **1,981** | **1,833** | **1,712** | **474** | **106** | **0** | **200,216** |

CnCatirGg manenARsukEkvsIma PUmixüMú nigPUmilVW -

RbPB ³ naykdæanGPivDÆCnCatiPaKtic

## 5.0 ជនជាតិដើមភាគតិចក្នុងតំបន់គម្រោង

31. ក្នុងខេត្ត រាជធានីទាំង ៩ ដែលជាតំបន់គោលដៅរបស់គម្រោង ជនជាតិដើមភាគតិច ស្មើនឹង ០,៨៥% (ប្រមាណ ១៣៨.០៣៨) នាក់ នៃចំនួនប្រជាជនដែលរស់នៅតាមតំបន់ជនបទក្នុងខេត្តទាំង ២៤ និងស្មើនឹង ១% (ប្រមាណ ២០០.២១៦ នាក់) ក្នុងខេត្តទាំង ១៥។ ជនជាតិដើមភាគតិច ចំនួន ២៤ ក្រុម ស្មើនឹងប្រមាណ ១% នៃចំនួនប្រជាជនសរុប រស់នៅក្នុងខេត្តចំនួន ១៥ ដែលក្នុងនោះមានខេត្តចំនួន ៧ ជាតំបន់គោលដៅ នៃគម្រោង CASDP ដូចបង្ហាញក្នុងតារាងទី ២ ខាងក្រោម៖

**តារាងទី ២ ក្រុមជនជាតិដើមភាគតិច ក្នុងតំបន់គម្រោងបែងចែកតាមខេត្ត**

| ជនជាតិ | រាជធានី ខេត្ត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | បាត់ដំបង | មណ្ឌលគិរី | រតនគិរី | ស្ទឹងត្រែង | ព្រះវិហារ | សៀមរាប | កំពង់ស្ពឺ | កណ្តាល | កំពង់ឆ្នាំង | ភ្នំពេញ |
| ស្អៀង | | √ | | | √ | | | | | |
| ក្រោល | | √ | | | | | | | | |
| មិល | | | | | | | | | | |
| ព្នង | | √ | √ | √ | √ | | | | | |
| កួយ | | | | √ | √ | | | | | |
| ថ្មូន | | | | | | | | | | |
| រអង | | √ | | | | | | | | |
| រដែ | | √ | √ | √ | | | | | | |
| ទំពួន | | | √ | √ | | | | | | |
| ជារាយ | | | √ | √ | | | | | | |
| គ្រឹង | | | √ | √ | | | | | | |
| ព្រៅ | | | √ | √ | √ | | | | | |
| ឡូន | | | √ | √ | | | | | | |
| កាវែត | | | √ | √ | | | | | | |
| កាចក់ | | | √ | | | | | | | |
| ឃិ | | | | √ | | | | | | |
| ព័រ | √ | | | | √ | | | | | |
| សួយ | | | | | | | √ | | | |
| ស្តួង | | | | | | | | | | |
| សំរ៉ែ | | | | | | √ | | | | |
| ជង | | | | | | | | | | |
| ល្មីន | | | | | | | | | | |
| ខោញ | | | | | | | | | | |
| ថ្មូន | | | | | | | | | | |

## 6.0 ផលប៉ះពាល់ ដែលគម្រោងអាចបង្កដល់ជនជាតិដើមភាគតិច

32. គេមិនរំពឹងថា គម្រោងនេះនឹងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ជនជាតិដើមភាគតិច រួមទាំងជនជាតិភាគតិចនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ អាចមានផលប៉ះពាល់ដោយប្រយោល កើតចេញពីការអនុវត្តអនុគម្រោង។ ឧទាហរណ៍ ចល័តភាព និងភាពងាយស្រួលក្នុងការទទួលបានសេវានានា អាចជាបញ្ហា ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធជនបទ ពុំមានការជួសជុលថែទាំឱ្យបានល្អប្រសើរនោះទេ។

33. ការទទួលបានសេវាថែទាំសុខភាព គឺជាអាទិភាពមួយ សម្រាប់ជនជាតិដើមភាគតិច ដោយហេតុថា ឃុំរបស់ពួកគេ មានទីតាំងនៅឆ្ងាយពីមន្ទីរពេទ្យស្រុក ឬមណ្ឌលសុខភាព។ ការអប់រំរបស់កុមារ គឺជាអាទិភាពមួយ សម្រាប់ជនជាតិដើមភាគតិច ទោះជាយ៉ាងណាក៏ដោយ កុមារដល់អាយុចូលរៀននៅបឋមសិក្សា យ៉ាងហោចណាស់ដល់ ១០% ពុំបានចូលរៀនឡើយ ដោយសារតែចម្ងាយផ្លូវទៅសាលារៀន ឬដោយសារតែរយៈពេលដែលត្រូវចំណាយ ដើម្បីទៅរៀន។ ការបោះបង់ចោលការសិក្សា មានអត្រាខ្ពស់ ដោយសារតែកត្តាជាច្រើន ដូចជា រយៈពេលធ្វើដំណើរទៅកាន់សាលារៀន និង/ឬស្ថានភាពហេដ្ឋារចនាសម្ព័ន្ធជនបទពុំមានភាពល្អប្រសើរ។

ក្នុងអំឡុងពេលពិគ្រោះយោបល់បឋម ក្នុងសហគមន៍ជនជាតិដើមភាគតិច និងក្នុងអំឡុងកិច្ចពិគ្រោះយោបល់ ជាមួយនឹងអង្គការជនជាតិដើមភាគតិច គេអាចកំណត់រកឃើញផលប៉ះពាល់ខាងក្រោម ដែលអាចកើតចេញពីសកម្មភាពគម្រោង មកលើជនជាតិដើមភាគតិច។

- ហានិភ័យនៃការផាត់ចេញ ឬការពុំប្រើប្រាស់សេវាផែនការអាជីវកម្មពីសំណាក់ជនជាតិដើមភាគតិច ដោយសារតែបញ្ហាមិនចេះអក្សររបស់ពួកគេ
- ហានិភ័យនៃការផាត់ចេញ ឬការពុំប្រើប្រាស់សេវាគាំទ្រផ្នែកហិរញ្ញវត្ថុពីសំណាក់អង្គការជនជាតិដើមភាគតិច និងកសិករ ដោយសារការព្រួយបារម្ភជុំវិញ ហានិភ័យនៃការកើនឡើងនូវការជាប់បំណុល
- ហានិភ័យបន្ទាប់បន្សំ ដែលកើតឡើងដោយសារសកម្មភាពរបស់សហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម ដែលទទួលបានឥណទាន ដែលអាចបង្កផលប៉ះពាល់ជាអវិជ្ជមានលើដីធ្លី និងបរិស្ថានរបស់សហគមន៍ជនជាតិដើមភាគតិច
- លទ្ធកម្មដីធ្លី ដែលអាចកើតមានឡើង និងផលប៉ះពាល់នៃការហូលចូលនូវកម្លាំងពលកម្ម ដោយសារតែផលប៉ះពាល់ពាក់ព័ន្ធនឹងការសាងសង់
- ហានិភ័យនៃការដកខ្លួនចេញពីការបណ្តុះបណ្តាល ដោយសារតែបញ្ហាអក្ខរកម្ម
- ការលំបាកក្នុងការទទួលបានព័ត៌មានទីផ្សារ ពីសំណាក់សហគមន៍ជនជាតិដើមភាគតិច
- ហានិភ័យនៃការផាត់អង្គការជនជាតិដើមភាគតិចចេញពីដំណើរការពិគ្រោះយោបល់

34. សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមពិនិត្យមើលការវិភាគសង្គមបឋម ដែលបង្ហាញក្នុងឧបសម្ព័ន្ធទី ១។

## 7.0 វិធានការសម្រាលផលប៉ះពាល់ ដែលអាចមានសម្រាប់ហានិភ័យដែលបានកំណត់

35. សម្រាប់ផលប៉ះពាល់ និងហានិភ័យ ដែលត្រូវបានកំណត់ខាងលើ វិធានការសម្រាលផលប៉ះពាល់ ដែលអាចមាន និងដែលត្រូវបានកំណត់ក្នុងការវិភាគសង្គមបឋម (សូមមើលឧបសម្ព័ន្ធទី ១) រួមមាន៖

- ការប្រើប្រាស់យុទ្ធនាការបង្កើនការយល់ដឹង ដោយប្រើប្រាស់មធ្យោបាយសោតទស្សន៍ ដើម្បីដោះស្រាយឧបសគ្គពាក់ព័ន្ធនឹងចេះអក្សរក្នុងយុទ្ធនាការបង្កើនការយល់ដឹង
- បង្កើនការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ដូចជា ការប្រើប្រាស់គ្រូបង្វឹកអាជីវកម្ម ដើម្បីជម្នះឧបសគ្គក្នុងការទទួលបានសេវាប្រឹក្សាអាជីវកម្ម
- គម្រោងផ្តល់ការគាំទ្រដល់ពលករជាជនជាតិដើមភាគតិច ដើម្បីផ្តល់ដំបូន្មានដល់ជនជាតិដើមភាគតិច ដែលជាអ្នកប្រើប្រាស់ឥណទាន អំពីផលវិបាក ដែលកើតឡើងចេញពីការប្រើប្រាស់ឥណទាន
- កិច្ចពិគ្រោះយោបល់ដោយសេរីជាមុន ផ្អែកតាមព័ត៌មានត្រឹមត្រូវ ដែលនាំឱ្យមានការគាំទ្រទូលំទូលាយពីសហគមន៍ ដល់សកម្មភាពហេដ្ឋារចនាសម្ព័ន្ធ
- កម្មវិធីបណ្តុះបណ្តាលសមស្របទៅតាមស្ថានភាពជាក់ស្តែង (ប្រើប្រាស់មធ្យោបាយសោតទស្សន៍) សម្រាប់សហគមន៍ជនជាតិដើមភាគតិច

## 7.1 ការពិនិត្យរកវត្តមានជនជាតិដើមភាគតិច

36. ធនាគារពិភពលោកបានធ្វើការពិនិត្យតំបន់ ដែលនឹងមានអន្តរាគមន៍ពីគម្រោង និងបានរកឃើញពីវត្តមានរបស់ជនជាតិដើមភាគតិច ដូចដែលតម្រូវដោយគោលនយោបាយ

ប្រតិបត្តិស្តីពីជនជាតិដើមភាគតិច។ ក្នុងអំឡុងរយៈពេលនៃការអនុវត្តអនុគម្រោងនេះ ទីភ្នាក់ងារអនុវត្តត្រូវបំពេញទម្រង់ពិនិត្យផលប៉ះពាល់បរិស្ថាន និងសង្គម ដែលមានបញ្ចូលសំណួរអំពីវត្តមានរបស់ជនជាតិដើមភាគតិច។ ធនាគារពិភពលោកនឹងធ្វើការពិនិត្យឡើងវិញ លើទម្រង់ទាំងនេះតាមកាលកំណត់ ដើម្បីកំណត់ឱ្យឃើញថាតើមានការពិនិត្យវត្តមានរបស់ជនជាតិដើមភាគតិចបានត្រឹមត្រូវដែរឬទេ។ សកម្មភាពទាំងឡាយដែលគ្របដណ្តប់ទូទាំងប្រទេស (ដូចជា វគ្គបណ្តុះបណ្តាល ឬការបង្កើនការយល់ដឹង) ដោយស្វ័យប្រវត្តិ គឺតម្រូវឱ្យមានការអនុវត្តបញ្ញត្តិនៃក្របខ័ណ្ឌនេះ ដោយសារតែជាធម្មតានឹងមានអ្នកទទួលផលជាជនជាតិដើមភាគតិច។

## 7.2 ការវាយតម្លៃលើហេតុប៉ះពាល់សង្គម

37. ការវាយតម្លៃលើហេតុប៉ះពាល់សង្គម (SIA) គឺជាដំណើរការកំណត់ និងពិនិត្យឡើងវិញលើផលប៉ះពាល់សង្គម ដែលកើតឡើងដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន ឬគម្រោងរចនាសម្ព័ន្ធដែលត្រូវបានស្នើឡើង និងអន្តរាគមន៍អភិវឌ្ឍន៍ដទៃទៀត។ បើតាមសមាគមវាយតម្លៃផលប៉ះពាល់អន្តរជាតិ (IAIA), ការវាយតម្លៃហេតុប៉ះពាល់សង្គមនេះ ត្រូវបញ្ចូលដំណើរ ការវិភាគ ពិនិត្យតាមដាន និងគ្រប់គ្រងផលវិបាកផ្នែកសង្គម ដែលនឹងកើតឡើងដោយមានការគ្រោងទុកជាមុន និងដែលកើតឡើងដោយចៃដន្យ ទាំងវិជ្ជមាន ទាំងអវិជ្ជមានចេញពីអន្តរាគមន៍ ដែលបានគ្រោងទុក (គោលនយោបាយ កម្មវិធី ផែនការ គម្រោង) និងដំណើរការនៃការផ្លាស់ប្តូរសង្គម ដែលកើតចេញពីអន្តរាគមន៍ទាំងនេះ។

38. វិសាលភាព កម្រិតស៊ីជម្រៅ និងប្រភេទនៃការវិភាគ ដែលត្រូវធ្វើក្នុងការវាយតម្លៃសង្គម ត្រូវសមាមាត្រទៅនឹងលក្ខណៈ និងវិសាលភាពនៃផលប៉ះពាល់ ដែលអនុគម្រោង ដែលត្រូវបានស្នើឡើងទាំងនេះ អាចបង្កលើសហគមន៍ មិនថាផលប៉ះពាល់ទាំងនេះ ជាផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមាននោះទេ។ ការវាយតម្លៃហេតុប៉ះពាល់សង្គម គួរបញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) របស់គម្រោង ដូចដែលត្រូវបានរៀបរាប់ក្នុងក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ហើយលទ្ធផលនៃការវិភាគនេះ ត្រូវប្រើប្រាស់ ដើម្បីរៀបចំផែនការគ្រប់គ្រង និងពិនិត្យតាមដានសង្គម (SMMP)។

39. នៅក្នុងករណីដែលដំណើរការពិនិត្យ ដូចរៀបរាប់ក្នុងផ្នែក ៥.១ ខាងលើរកឃើញវត្តមានរបស់ជនជាតិដើមភាគតិច ក្នុងតំបន់គម្រោង និងមានការអនុវត្តដំណើរការវាយតម្លៃសង្គមពិសេសមួយ ស្របតាមគោលការណ៍ណែនាំ ដែលត្រូវបានលើកឡើងក្នុង OP 4.10។ ដំណើរការនេះ មានសមាសភាគដូចតទៅ៖

ក) អាស្រ័យទៅតាមវិសាលភាពរបស់គម្រោង និងមានការពិនិត្យលើក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌស្ថាប័ន ដែលអនុវត្តចំពោះជនជាតិដើមភាគតិចក្នុងសហគមន៍ដែលរងផលប៉ះពាល់។

ខ) ការប្រមូល និងការវិភាគលើព័ត៌មានដើមគ្រា ដែលពាក់ព័ន្ធអំពីលក្ខណៈវប្បធម៌ សង្គម សេដ្ឋកិច្ច និងនយោបាយរបស់សហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ និងប្រសិនបើពាក់ព័ន្ធលើដីធ្លី និងដែនដី ដែលពួកគេកាន់កាប់ជាប្រពៃណី និងធនធានធម្មជាតិ ដែលពួកគេពឹងអាស្រ័យលើ។

គ) ដោយប្រើប្រាស់ព័ត៌មានដើមគ្រានេះ នឹងមានការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធសំខាន់ៗរបស់គម្រោង ដែលស្ថិតនៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ ហើយនិងមានការកំណត់ពីដំណើរការពិគ្រោះយោបល់សមស្របតាមវប្បធម៌ ជាមួយនឹងជនជាតិដើមភាគតិច ក្នុងអំឡុងពេលរៀបចំ និងអនុវត្តអនុគម្រោង រួមគ្នាជាមួយនឹងតួអង្គពាក់ព័ន្ធទាំងនោះ (សូមមើលកថាខណ្ឌ ៩ នៃ OP 4.10)។

ឃ) ការវាយតម្លៃផ្អែកតាមការពិគ្រោះយោបល់ដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវជាមួយនឹងសហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ អំពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ដែលអាចកើតចេញពីអនុគម្រោង។ ការវាយតម្លៃនេះ ត្រូវគិតគូរពីភាពងាយរងគ្រោះពិសេសរបស់សហគមន៍ជនជាតិដើមភាគតិច ដោយធ្វើការពិចារណាពីចម្ងាយកាលៈទេសៈ និងទំនាក់ទំនងរបស់សហគមន៍ទាំងនោះ ជាមួយនឹងដីធ្លី និងធនធានធម្មជាតិទាំងនេះ ក៏ដូចជា ឧបសគ្គ ដែលរារាំងពួកគេមិនឱ្យទទួលបានឱកាសពីការអភិវឌ្ឍ ដែលកំពុងមានក្នុងសង្គមទូទៅ។

ង) ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃលើវិធានការដែលចាំបាច់ ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមាន ឬប្រសិនបើវិធានការទាំងនេះពុំអាចអនុវត្តទៅបាន ត្រូវមានការកំណត់វិធានការដើម្បីកាត់បន្ថយឱ្យនៅជាអប្បបរមា សម្រាលផលប៉ះពាល់ ឬផ្តល់សំណងសម្រាប់ផលប៉ះពាល់ទាំងនេះ និងធានាយ៉ាងណាឱ្យជនជាតិដើមភាគតិច ទទួលបានអត្ថប្រយោជន៍សមស្របតាមវប្បធម៌របស់ពួកគេ ក្រោមអនុគម្រោង ដោយវិធានការទាំងនេះ ត្រូវកំណត់ក្នុងកិច្ចពិគ្រោះយោបល់ ដោយសេរីជាមុន ផ្អែកតាមព័ត៌មានត្រឹមត្រូវជាមួយសហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់។

40. នៅក្នុងករណីដែលសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ ដោយសារអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ ការវាយតម្លៃសង្គមនេះ ត្រូវបង្ហាញជាជំពូកដោយឡែក ក្នុង ESMP ហើយក៏អាចបង្ហាញជាឯកសារដាច់តែឯងផងដែរ សម្រាប់គោលបំណងនៃកិច្ចពិគ្រោះយោបល់ និងការបង្ហាញព័ត៌មាន។

នៅក្នុងករណីដែលសហគមន៍ជនជាតិដើមភាគតិច រងផលប៉ះពាល់ដោយសារសកម្មភាពបណ្តុះបណ្តាល ឬសកម្មភាពបង្កើនការយល់ដឹង នោះភាពចាំបាច់ដើម្បីធ្វើការវាយតម្លៃសង្គមនៅថ្នាក់ជាតិ ឬថ្នាក់ខេត្ត ត្រូវបញ្ចូលទៅក្នុងលក្ខខណ្ឌប្រតិបត្តិរបស់អ្នកផ្តល់សេវាបណ្តុះបណ្តាលទាំងនេះ។

### 7.3 ដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ

41. គោលនយោបាយរបស់ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច តម្រូវឱ្យមានការអនុវត្តដំណើរការពិគ្រោះយោបល់ដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ ដើម្បីកៀរគរការគាំទ្រពីសហគមន៍ជនជាតិដើមភាគតិច ដែលនឹងទទួលប្រយោជន៍ ឬរងផលប៉ះពាល់ដោយសារអនុគម្រោង ដែលទទួលបានហិរញ្ញប្បទានពីធនាគារ។ គោលការណ៍នៃកិច្ចពិគ្រោះយោបល់ដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ ទទួលស្គាល់ពីសិទ្ធិ ដែលបន្តពីបុព្វបុរសរបស់សហគមន៍ជនជាតិដើមភាគតិច លើដីធ្លី ដែនដី និងធនធានរបស់ពួកគេ និងគោរពសមត្ថកិច្ចស្របច្បាប់របស់ពួកគេ ក៏ដូចជា តម្រូវឱ្យមានការអនុវត្តដំណើរការ ដែលផ្តល់លទ្ធភាពនិងគាំទ្រឱ្យជនជាតិដើមភាគតិច ធ្វើការជ្រើសរើសមាគ៌ាអភិវឌ្ឍន៍សម្រាប់សហគមន៍របស់ពួកគេ។

42. អ្នកខ្ចីកម្ចីចាំបាច់ត្រូវប្រើប្រាស់វិធីសាស្ត្រពិគ្រោះយោបល់តាមបែបចូលរួម សមស្របទៅតាមគុណតម្លៃសង្គម និងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ ព្រមទាំងស្ថានភាពនៅមូលដ្ឋានរបស់ពួកគេ ហើយក្នុងរៀបចំវិធីសាស្ត្រទាំងនេះ អ្នកខ្ចីកម្ចីត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះបញ្ហាដែលជាក្តីបារម្ភរបស់ស្ត្រី យុវជន និងកុមារជនជាតិដើមភាគតិច និងការទទួលបានឱកាស និងភាគផលពីការអភិវឌ្ឍរបស់ក្រុមទាំងនេះ។

43. វេទិកាធម្មតាសម្រាប់កិច្ចពិគ្រោះយោបល់ គឺជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សង្គម ហើយវិសាលភាពនៃកិច្ចពិគ្រោះយោបល់ ដែលចាំបាច់ត្រូវរៀបចំ មានការប្រែប្រួលខុសៗគ្នាអាស្រ័យទៅតាមគម្រោងជាក់លាក់ និងលក្ខណៈនៃផលប៉ះពាល់ដែលត្រូវឆ្លើយតប។ វិធីសាស្ត្រ ដែលត្រូវប្រើប្រាស់សម្រាប់រៀបចំកិច្ចពិគ្រោះយោបល់ ប្រែប្រួលអាស្រ័យទៅតាមប្រភេទសហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោងជាក់លាក់ (ឧទាហរណ៍ ភាពងាយរងគ្រោះ ភាសា និងការបន្តទំនាក់ទំនងរបស់ពួកគេ ជាមួយសង្គមទូទៅ ឬសហគមន៍ជិតខាង)។

ដំណើរការពិគ្រោះយោបល់នេះ ចាំបាច់ត្រូវធានាថា៖

- ជនជាតិដើមភាគតិច ពុំត្រូវបានបង្ខិតបង្ខំ ទទួលរងសម្ពាធ ឬសំឡុតគំរាមឱ្យធ្វើការជ្រើសរើសយកជម្រើសណាមួយនៃការអភិវឌ្ឍ។
- ត្រូវមានការស្វែងរកការយល់ព្រមពីជនជាតិដើមភាគតិចជាមុន មុនពេលផ្តល់ការអនុញ្ញាត ឬមុនពេលចាប់ផ្តើមសកម្មភាព ហើយត្រូវមានការផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ដើម្បីរៀបចំកិច្ចពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច/អនុវត្តដំណើរការ ដែលនាំឱ្យមានការឯកភាពគ្នាជារួមនៅក្នុងសហគមន៍ជនជាតិដើមភាគតិច និង
- សហគមន៍ជនជាតិដើមភាគតិចទទួលបានព័ត៌មានពេញលេញអំពីវិសាលភាព និងផលប៉ះពាល់ ដែលសកម្មភាពអភិវឌ្ឍន៍ដែលស្នើឡើងមានលើដីធ្លី ធនធាន និងសុខុមាលភាពរបស់ពួកគេ។ គួរមានការផ្តល់ព័ត៌មានអំពីលក្ខណៈ ទំហំ ល្បឿន ភាពអាចប្តូរត្រលប់មកវិញបាន វិសាលភាពនៃអនុគម្រោង ឬសកម្មភាព ដែលត្រូវបានស្នើឡើង, គោលបំណង

នៃអនុគម្រោង និងរយៈពេលអនុគម្រោង, ទីតាង និងតំបន់ដែលរងផលប៉ះពាល់, ការវាយតម្លៃបឋមលើផលប៉ះពាល់សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ដែលអាចកើតមានឡើង រួមទាំងហានិភ័យ ដែលអាចកើតមានឡើងផង, បុគ្គលិកដែលទំនងជានឹងចូលរួមក្នុងការអនុវត្តគម្រោងនេះ និងនីតិវិធីដែលអនុគម្រោងអាចយកមកអនុវត្ត។ ដំណើរការនេះ អាចបញ្ចូលជម្រើសដកចេញវិញនូវការយល់ព្រមផងដែរ។

44. កិច្ចពិគ្រោះយោបល់ និងការចូលរួម គឺជាសមាសភាគសំខាន់ៗនៃដំណើរការផ្តល់ការយល់ព្រម ហើយត្រូវមានការចងក្រងទុកជាឯកសារ អំពីដំណើរការពិគ្រោះយោបល់ទាំងនេះ។

45. គួរមានការពិចារណាឱ្យបានល្អិតល្អន់ អំពីការរៀបចំកិច្ចពិគ្រោះយោបល់ និងរៀបចំឱ្យបានសមស្របទៅនឹងបរិបទរបស់គម្រោង ផលប៉ះពាល់ដែលគេរំពឹងថានឹងកើតមានឡើង និងបរិបទនៃសហគមន៍មូលដ្ឋាន។ កិច្ចពិគ្រោះយោបល់គួរធ្វើឡើងជាភាសាជនជាតិភាគតិច នៅពេលដែលចាំបាច់ និងត្រូវទុកពេលឱ្យបានគ្រប់គ្រាន់ (យ៉ាងហោចណាស់ពីរសប្តាហ៍) ដើម្បីធានាថា សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ទាំងអស់ នឹងអាចចូលរួមក្នុងកិច្ចពិគ្រោះយោបល់ទាំងនេះ ដោយបានដឹងព័ត៌មានពេញលេញអំពីគម្រោង។ អភិក្រមដែលប្រើប្រាស់សម្រាប់ពិគ្រោះយោបល់ អាចមានដូចជា៖

- កិច្ចប្រជុំសហគមន៍ ទាំងជាមួយសហគមន៍ទាំងមូល និងជាមួយនឹងអនុក្រុមផ្សេងៗគ្នាក្នុងសហគមន៍
- កិច្ចពិភាក្សាក្រុមគោលដៅ និងការរៀបចំផែនការដែលមានការចូលរួម
- ការផ្តល់ព័ត៌មានគម្រោង ក្នុងទម្រង់ពេញលេញ (ឯកសារគម្រោង របាយការណ៍វាយតម្លៃ។ល។ ទម្រង់សាមញ្ញៗ ដូចជា ផ្ទាំងរូបភាព និងខិតប័ណ្ណ និងសម្ភារៈសោតទស្សន៍ ដោយប្រើប្រាស់ភាសានៅមូលដ្ឋាន
- ការកំណត់រកជនបង្គោលក្នុងសហគមន៍ (វគ្គបណ្តុះបណ្តាលមួយចំនួនប្រហែលជាត្រូវរៀបចំ ដើម្បីបង្កើនលទ្ធភាពរបស់ពួកគេ ក្នុងការចូលរួម ប្រកបដោយអត្ថន័យ ក្នុងដំណើរការពិគ្រោះយោបល់)
- ការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ អង្គការជនជាតិដើមភាគតិច ប្រសិនបើមាន និងអង្គការសង្គមស៊ីវិលនៅមូលដ្ឋានផ្សេងទៀត ដែលត្រូវបានលើកឡើងដោយសហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ និង
- ឱកាសពិគ្រោះយោបល់នៅដំណាក់កាលនីមួយៗនៃការរៀបចំ និងការអនុវត្តគម្រោង។

46. នៅក្នុងករណីដែលសហគមន៍ជនជាតិដើមភាគតិច រងផលប៉ះពាល់ដោយសារសកម្មភាពបណ្តុះបណ្តាល ឬសកម្មភាពបង្កើនការយល់ដឹង នោះភាពចាំបាច់ ដើម្បីរៀបចំកិច្ចពិគ្រោះយោបល់ជាមួយនឹងតំណាងជនជាតិដើមភាគតិចនៅថ្នាក់ជាតិ ឬថ្នាក់ខេត្តត្រូវបញ្ចូលទៅក្នុងលក្ខខណ្ឌប្រតិបត្តិរបស់អ្នកផ្តល់សេវា។

## 7.4 ការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច

47. បើតាម OP/BP 4.10 នៅពេលដែលការពិនិត្យដំបូងរកឃើញថា ជនជាតិដើមភាគតិច ដែលមានទំនាក់ទំនងជាសមូហភាពជាមួយនឹងតំបន់គម្រោង ទំនងជាមានវត្តមាននៅក្នុងតំបន់គម្រោង លទ្ធផលរកឃើញពីការវាយតម្លៃហេតុប៉ះពាល់សង្គម និងដំណើរការពិគ្រោះយោបល់ដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ នឹងត្រូវប្រើប្រាស់ដោយដៃគូ ដែលត្រូវបានជ្រើសរើសឱ្យអនុវត្តគម្រោង ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) សម្រាប់អនុគម្រោងជាក់លាក់ ដែលបង្កផលប៉ះពាល់ដល់ជនជាតិភាគតិច។ ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ត្រូវដាក់ចេញនូវវិធានការ ដែលអ្នកខ្ចីកម្ចីនឹងអនុវត្ត ដើម្បីធានាថា (ក) ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដោយសារគម្រោង នឹងទទួលបានអត្ថប្រយោជន៍ផ្នែកសង្គមសេដ្ឋកិច្ច សមស្របទៅតាមវប្បធម៌របស់ពួកគេ និង (ខ) នៅពេលដែលផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើងលើជនជាតិដើមភាគតិច ត្រូវបានកំណត់រកឃើញផលប៉ះពាល់ជាអវិជ្ជមានទាំងនេះ ត្រូវបានបញ្ចៀសកាត់បន្ថយឱ្យនៅតិចជាអប្បបរមា សម្រាល ឬទូទាត់សង។ ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច គួររៀបចំ

ប្រកបដោយភាពបត់បែន និងឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែង ហើយកម្រិតពិស្តារនៃផែនការនេះមានការប្រែប្រួលខុសៗគ្នា អាស្រ័យទៅតាមគម្រោងជាក់លាក់ និងទៅតាមលក្ខណៈនៃផលប៉ះពាល់ដែលត្រូវឆ្លើយតប។ អ្នកខ្ចីកម្ចីត្រូវបញ្ចូលផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចទៅក្នុងការគាក់តែងគម្រោង។

48. នៅពេលដែលមានការតម្រូវ ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច គួរបញ្ចូលសមាសភាគខាងក្រោមទៅតាមការចាំបាច់ (សមាមាត្រទៅនឹងវិសាលភាព អត្ថប្រយោជន៍ ផលប៉ះពាក់ និងហានិភ័យរបស់គម្រោង)៖

ក) ពិពណ៌នាគម្រោង និងពិពណ៌នាដោយសង្ខេបអំពីបញ្ហាពាក់ព័ន្ធនឹងជនជាតិភាគតិច
ខ) សេចក្តីសង្ខេបអំពីក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌស្ថាប័ន ដែលអនុវត្តចំពោះជនជាតិភាគតិច
គ) សេចក្តីសង្ខេបអំពីការវាយតម្លៃសង្គម ដូចជា ព័ត៍មានដើមគ្រាអំពីលក្ខណៈប្រជាសាស្ត្រសង្គម វប្បធម៌ និងនយោបាយរបស់ជនជាតិភាគតិច ដែលរងផលប៉ះពាល់ដីធ្លី និងដែនដីដែលពួកគេកាន់កាប់ជាប្រពៃណី ឬប្រើប្រាស់ ឬកាន់កាប់ជាទំនៀមទម្លាប់ និងធនធានធម្មជាតិ ដែលពួកគេពឹងអាស្រ័យលើ
ឃ) សេចក្តីសង្ខេបអំពីលទ្ធផលនៃកិច្ចពិគ្រោះយោបល់ដោយសេរីជាមុន និងផ្អែកតាមព័ត៍មានត្រឹមត្រូវ ជាមួយជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ ដែលនាំឱ្យមានការគាំទ្រយ៉ាងទូលំទូលាយពីសហគមន៍ ដោយគម្រោង
ង) ក្របខ័ណ្ឌដើម្បីធានាឱ្យមានកិច្ចពិគ្រោះយោបល់ដោយសេរីជាមុន និងផ្អែកតាមព័ត៍មានត្រឹមត្រូវ ជាមួយនឹងជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ក្នុងអំឡុងពេលអនុវត្តសកម្មភាពគម្រោង
ច) វិធានការដើម្បីធានាថា ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ទទួលបានអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចសមស្របទៅតាមវប្បធម៌របស់ពួកគេ។
ឆ) សេចក្តីពិពណ៌នាអំពីការរៀបចំស្ថាប័ន សម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច
ជ) វិធានការដើម្បីបញ្ចៀសកាត់បន្ថយឱ្យនៅជាអប្បបរមា សម្រាល ឬផ្តល់សំណងចំពោះផលប៉ះពាល់អវិជ្ជមាន
ឈ)ការប៉ាន់ប្រមាណចំណាយ និងផែនការហិរញ្ញប្បទានសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច
ញ) យន្តការដោះស្រាយបណ្តឹងសារទុក្ខ ដែលផ្តល់ភាពងាយស្រួលដល់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ និង
ដ) ការពិនិត្យតាមដាន ការវាយតម្លៃ និងការរៀបចំរបាយការណ៍អំពីការអនុវត្តផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច រួមនឹងសូចនាករពិនិត្យតាមដានជាក់លាក់ (បែងចែកតាមជាតិពន្ធ)។

49. នៅពេលដែលជនជាតិដើមភាគតិច គឺជាក្រុមតែមួយគត់ ឬក្រុមភាគច្រើនលើសលុបក្នុងចំណោមក្រុមដែលទទួលផលផ្ទាល់ពីអនុគម្រោង គេគួរបញ្ចូលសមាសភាគនានានៃផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចនេះទៅក្នុងការគាក់តែងគម្រោងទាំងមូល ហើយក្នុងករណីនេះគេពុំចាំបាច់រៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចដាច់ដោយឡែកនោះទេ។ ក្នុងករណីនេះ សមាសភាគសំខាន់ៗនៃផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (សូមមើលចំណុច ខ-ដ ខាងលើ) និងត្រូវបញ្ចូលទៅក្នុង ESMP សម្រាប់គម្រោងពាក់ព័ន្ធ អមនឹងលទ្ធផលរកឃើញពីការវាយតម្លៃសង្គម។ ESMP ដែលត្រូវបានរៀបចំ ស្របតាមចំណុចខាងលើនេះ នឹងអាចទទួលយកបានតែក្នុងករណីដែលសមាសភាគទាំងនេះត្រូវបានបញ្ចូលក្នុងកម្រិតជាទីពេញចិត្ត ដោយ PMU និងអ្នកឯកទេសផ្នែកអភិវឌ្ឍន៍សង្គមរបស់ក្រុមការងារធានាគារពិភពលោកតែប៉ុណ្ណោះ។

50. ក្នុងករណីដែលសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ ដោយសារសកម្មភាពបណ្តុះបណ្តាល ឬបង្កើនការយល់ដឹង នោះភាពចាំបាច់ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ដែលរៀបរាប់ពីវិធានការពិសេស ឬវិធីសាស្ត្រសម្រាប់ផ្តល់ការបណ្តុះបណ្តាលនៅថ្នាក់ជាតិ ឬថ្នាក់ខេត្ត ត្រូវបញ្ចូលទៅក្នុងលក្ខខណ្ឌប្រតិបត្តិរបស់អ្នកផ្តល់សេវា។

## 8.0 ការរៀបចំស្ថាប័ន

51. គម្រោងនេះនឹងត្រូវអនុវត្តដោយប្រើប្រាស់ប្រព័ន្ធរបស់រដ្ឋាភិបាល។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាទីភ្នាក់ងារប្រតិបត្តិចម្បង ដែលទទួលខុសត្រូវអនុវត្ត និងការរៀបចំការសម្របសម្រួលទាំងមូល។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវលើការគ្រប់គ្រង/ការសម្របសម្រួលគម្រោងទាំងមូល និងលើការអនុវត្តសមាសភាគទាំងបួន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសហការយ៉ាងជិតស្និទ្ធជាមួយនឹងអង្គភាពបច្ចេកទេសរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម ដែលជា ដៃគូអនុវត្ត ទទួលខុសត្រូវលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទ។ នឹងមានការផ្តល់ការគាំទ្រដល់ការបង្កើតក្រុមការងារសម្របសម្រួល និងអនុវត្តក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ភ្ជាប់ជាមួយនឹង (លេខាធិការដ្ឋាន) ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក (TWGAW)។ នឹងមានការបង្កើតគណ:កម្មាធិការដឹកនាំនៅកម្រិតខ្ពស់ ដើម្បីផ្តល់ដំបូន្មាន និងដោះស្រាយបញ្ហាអន្តរវិស័យដែលកើតចេញថ្មី។

52. មន្ត្រីទទួលបន្ទុកការពារផលប៉ះពាល់សង្គម និងបរិស្ថាន ត្រូវទទួលខុសត្រូវអនុវត្ត និងពិនិត្យតាមដានវិធានការការពារផលប៉ះពាល់ សម្រាប់សមាសភាគ ដែលផ្តោតលើពិពិធកម្មវិស័យកសិកម្ម និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ។ បើទោះបីជាការយល់ដឹងអំពីបញ្ហាការពារផលប៉ះពាល់បរិស្ថាន និងសង្គម នៅមានកម្រិត និងទាមទារឱ្យមានការកសាងសមត្ថភាពបន្ថែម តាមរយ:ការដាក់ចេញនូវគោលការណ៍ណែនាំស្តីពីការការពារផលប៉ះពាល់បរិស្ថាន និងឯកសារនីតិវិធីក៏ដោយ ក្រសួងបរិស្ថាន ត្រូវទទួលខុសត្រូវផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការការពារផលប៉ះពាល់ ដោយធានាឱ្យមានការបញ្ជ្រាបលក្ខខណ្ឌតម្រូវនៃការការពារផលប៉ះពាល់ទៅក្នុងវដ្តនៃគម្រោងអភិវឌ្ឍន៍ផ្លូវថ្នល់ និងធ្វើសកម្មភាពស្រាវជ្រាវដែលចាំបាច់នានា។ លើសពីនេះ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អតីតគណ:កម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ [IRC]) នឹងចូលរួមផងដែរ ដោយសារតែការធ្វើលទ្ធកម្មដីធ្លីជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ នឹងកើតមានឡើងមិនអាចចៀសរួច។

53. ក្រសួងកសិកកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាទីភ្នាក់ងារប្រតិបត្តិ និងអនុវត្តសម្រាប់គម្រោង CASDP នៅកម្ពុជា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (ដូចជា ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម) នឹងរួមគ្នាទទួលខុសត្រូវលើលទ្ធផលការងារផ្នែកបរិស្ថាន និងសង្គមនៃអនុគម្រោង ដែលអនុវត្តក្រោមជំនួយបច្ចេកទេសរបស់ក្រសួងបរិស្ថាន និងគណ:កម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ គួរមានមន្ត្រីការពារផលប៉ះពាល់បរិស្ថាន និងសង្គមបំពេញការងារ ដើម្បីសម្រេចគោលបំណងនេះ។ អាស្រ័យទៅតាមការបណ្តុះបណ្តាល និងបទពិសោធន៍វិជ្ជាជីវ: ខាងការអនុវត្ត និងការពិនិត្យតាមដាន វិធានការការពារផលប៉ះពាល់បរិស្ថាន និងសង្គម មន្ត្រីទាំងនេះទំនងជាត្រូវការការបណ្តុះបណ្តាល និងការគាំទ្របន្ថែមទៀត។ មន្ត្រីទាំងនេះគួរទទួលបានការគាំទ្រពីក្រុមទីប្រឹក្សាផ្តល់ជំនួយបច្ចេកទេស ដែលនឹងជួយដល់ការអនុវត្តតាមលក្ខខណ្ឌតម្រូវ ក្នុង ESMF ហើយក្នុងពេលជាមួយគ្នាកសាងសមត្ថភាពបុគ្គលិក ដើម្បីឆ្លើយតបចំពោះបញ្ហាពាក់ព័ន្ធនឹងការការពារផលប៉ះពាល់។

54. ខណ:ពេលដែលកំពុងមានការកំណត់ពីគម្រោង ដែលត្រូវអនុវត្ត ទីភ្នាក់ងារប្រតិបត្តិ និងអនុវត្ត (ក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ) នឹងរួមគ្នាកំណត់ពីភារកិច្ច និងការទទួលខុសត្រូវជុំវិញការអនុវត្តអនុគម្រោងជាក់លាក់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធនឹងរួមគ្នាពិនិត្យលើរបាយការណ៍ពិនិត្យផលប៉ះពាល់បឋមដែលរៀបចំដោយទីភ្នាក់ងារប្រតិបត្តិ និងអនុវត្តនៅតាមមូលដ្ឋានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ នឹងរៀបចំព្រាងលក្ខខណ្ឌប្រតិបត្តិ សម្រាប់ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) និងលក្ខខណ្ឌតម្រូវ ដើម្បីរៀបចំ IPDP។ ESMP និងឯកសារផែនការ (ដូចជា ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ [RAP] និង IPDP) នឹងត្រូវចែករំលែកជាមួយតួអង្គពាក់ព័ន្ធនានា និងក្រុមប្រជាជនក្នុងអំឡុងពេលធ្វើការពិគ្រោះយោបល់។ បញ្ហា និងចំណុចដែលសង្កេតឃើញក្នុងកិច្ចពិគ្រោះយោបល់ទាំងនេះ នឹងត្រូវបញ្ចូលទៅក្នុងឯកសារទាំងនេះ។ ឯកសារទាំងនេះ នឹងត្រូវដាក់បង្ហាញជាសាធារណ: និងដាក់ជូនធនាគារដើម្បីពិនិត្យឡើងវិញ។

## 9.0 ការរៀបចំការពិនិត្យតាមដាន និងការវាយតម្លៃ

55. គម្រោងនេះនឹងពិនិត្យ និងវាយតម្លៃលើជនជាតិដើមភាគតិច ជាពិសេសរបៀបដែលការងារស្តារផ្លូវថ្នល់ឡើងវិញ នឹងបង្កផលប៉ះពាល់ដល់ពួកគេ ទាំងវិជ្ជមាន ទាំងអវិជ្ជមាន។ ប្រសិនបើជនជាតិដើមភាគតិចរងផលប៉ះពាល់ជាអវិជ្ជមាន ដោយសារតែលទ្ធកម្មដីធ្លី ឬទ្រព្យសម្បត្តិផ្សេងទៀត នោះការពិនិត្យតាមដាន និងវាយតម្លៃនេះ នឹងពិនិត្យលើលទ្ធកម្មដីធ្លី ការ

ប៉ះពាល់ដល់ទីលំនៅ និងការផ្លាស់ប្តូរទីតាំងជនជាតិដើមភាគតិច ព្រមទាំងនីតិវិធីនានា ដែលត្រូវបានចងក្រងទុកជាឯកសារក្នុង RAP។

56. លើសពីនេះ ដូចដែលត្រូវបានតម្រូវដោយ ESMF, របាយការណ៍ពិនិត្យតាមដានប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស នឹងត្រូវរៀបចំឡើងតាមសកម្មភាពជាក់លាក់ ដើម្បី៖

- ធ្វើឱ្យកាន់តែប្រសើរនូវការគ្រប់គ្រងបរិស្ថាន និងសង្គម
- ធានាប្រសិទ្ធភាព និងគុណភាពនៃដំណើរការវាយតម្លៃ បរិស្ថាន និងសង្គម
- ប្រមូលភស្តុតាងនានា និងធ្វើការវាយតម្លៃបរិស្ថាន និងសង្គមផ្អែកតាមលទ្ធផលសម្រាប់អនុគម្រោង និង
- ផ្តល់ឱកាសឱ្យមានការរាយការណ៍ពីលទ្ធផលនៃការការពារផលប៉ះពាល់ និងការអនុវត្តវិធានការសម្រាលផលប៉ះពាល់ ដែលត្រូវបានលើកស្នើឡើង។

ពាក់ព័ន្ធនឹងការអនុវត្តគម្រោងវិញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ នឹងរួមគ្នាអនុវត្តសកម្មភាពពិនិត្យតាមដានផ្ទៃក្នុង ក្នុងអំឡុងពេលរៀបចំ និងសិក្ខាពីសមិទ្ធិលទ្ធភាព ក៏ដូចជា រៀបចំ ESMPs ដើម្បីកំណត់ពីវិសាលភាពនៃការអនុវត្តវិធានការសម្រាល ប្រកបដោយជោគជ័យ។ មន្ត្រីទទួលបន្ទុកការការពារសង្គម និងបរិស្ថាន ក៏នឹងត្រូវអនុវត្តសកម្មភាពពិនិត្យតាមដានប្រចាំត្រីមាសផ្ទៃក្នុង និងត្រូវដាក់របាយការណ៍ជូនគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងធនាគារពិភពលោក ដើម្បីពិនិត្យឡើងវិញដោយរបាយការណ៍នេះ ត្រូវដាក់ តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ។ ការពិនិត្យតាមដាននឹងផ្តោតលើផ្នែកសំខាន់ចំនួនបី ដូចជា៖

ក. ការពិនិត្យតាមដានភាពអនុលោម៖ ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ថា វិធានការសម្រាលដែលចាំបាច់ត្រូវបានយកមកធ្វើការពិចារណា និងអនុវត្ត។ ក្នុងអំឡុងដំណាក់កាលរៀបចំអនុគម្រោង សកម្មភាពពិនិត្យតាមដាន ភាពអនុលោម និងផ្តោតលើការធានាឱ្យមានការអនុវត្ត ESMF ប្រកបដោយប្រសិទ្ធភាព និងការគោរពទៅតាមនីតិវិធី។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងមន្ត្រីឯកទេសខាងបរិស្ថាន និងសង្គមរបស់ក្រសួងពាក់ព័ន្ធ ត្រូវធានាឱ្យមានការសិក្សាគម្រោងឱ្យបានត្រឹមត្រូវ និងឱ្យបានឆាប់រហ័ស ស្របតាមច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងបទដ្ឋានគតិយុត្តរបស់ក្រុមធនាគារពិភពលោក។

ការសិក្សាសមិទ្ធិលទ្ធភាព ក៏ត្រូវបញ្ចូលការវាយតម្លៃលើស្ថានភាពនៃការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹង ARAP/RAP និងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចផងដែរ

- បណ្តឹងសារទុក្ខ ជាពិសេសបណ្តឹងសារទុក្ខទាំងឡាយ ដែលពុំទាន់ត្រូវបានដោះស្រាយនៅថ្នាក់មូលដ្ឋាន និងដែលត្រូវការដំណោះស្រាយនៅកម្រិតខ្ពស់ជាង ដូចដែលត្រូវបានកំណត់ពីដំបូងក្នុង ESMF
- ការរៀបចំឯកសារស្តីពីការដោះស្រាយផលប៉ះពាល់ និងការផ្តល់សំណងក្នុងអនុគម្រោង ប្រសិនបើពាក់ព័ន្ធ រួមបញ្ចូលទាំងឯកសារសម្រាប់គ្រប់ការបាត់បង់អចិន្ត្រៃយ៍ និងបណ្តោះអាសន្នទាំងអស់
- ការវាយតម្លៃលើគុណភាពនៃវិធានការផ្តល់សំណង ឬវិធានការសម្រាលផលប៉ះពាល់ដែលពាក់ព័ន្ធផ្សេងទៀត ដែលត្រូវអនុវត្តទៅតាមលក្ខខណ្ឌតម្រូវនៃគម្រោងវិនិយោគនាពេលអនាគត ដូចដែលត្រូវបានកំណត់ពីដំបូង រួមនឹងផលប៉ះពាល់លើជីវភាពរស់នៅផងដែរ និង
- វិធានការសម្រាល នៅពេលដែលមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ក្នុងសូចនាករដែលប្រហែលជាតម្រូវឱ្យមានការអនុវត្តអន្តរាគមន៍ជាយុទ្ធសាស្ត្រ ឧទាហរណ៍ប្រសិនបើ ក្រុមប្រជាជនផ្សេងៗ (ជនជាតិភាគតិច និងក្រុមងាយរងគ្រោះដូចជា ស្ត្រី និងយុវជន/យុវតី និងកុមារ បុរស ចាស់ជរា និងជនពិការ អ្នកដែលគ្មានដីធ្លី និងប្រជាពលរដ្ឋក្រីក្រ។ល។) ពុំបានទទួលការគាំទ្រឱ្យបានគ្រប់គ្រាន់ពីគម្រោង ដែលនឹងត្រូវអនុវត្តនេះ។

ក្នុងអំឡុងដំណាក់កាលអនុវត្តការពិនិត្យតាមដានលើភាពអនុលោម ត្រូវបញ្ចូលការពិនិត្យក្នុងអំឡុងពេលសាងសង់នៃគំនិតផ្តួចផ្តើមអនុគម្រោង និង//ឬសកម្មភាព ដើម្បីផ្ទៀតផ្ទាត់ពីភាពអនុលោមទៅតាមស្ថានភាព និងអាជ្ញាប័ណ្ណ ដែលបានចេញជូន។ ដំណាក់សាងសង់ប្រតិបត្តិការ និងរះវេក្រោយបញ្ចប់អនុគម្រោង គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ ហើយការពិនិត្យ

តាមដានលើភាពអនុលោម និងត្រូវធានាដោយក្រសួងបរិស្ថាន។

ខ. ការពិនិត្យតាមដានផលប៉ះពាល់៖ ក្រោយពេលដែលគម្រោង CASDP បានចាប់ផ្តើមអនុវត្ត ការពិនិត្យតាមដានលើវិធានការសម្រាលផលប៉ះពាល់ នៃគំនិតផ្តួចផ្តើមអនុគម្រោង និង/ឬសកម្មភាព គួរជាភារកិច្ចរបស់ទីភ្នាក់ងារប្រតិបត្តិ និងអនុវត្ត និងមន្ត្រីការពារសង្គម និងបរិស្ថាន។ គេរំពឹងថាឯកសារការពារបរិស្ថាន និងសង្គមនឹងត្រូវផ្តល់ទៅឱ្យអ្នកម៉ៅការ ហើយទីភ្នាក់ងារប្រតិបត្តិ និងអនុវត្តត្រូវពិនិត្យតាមដាន ដើម្បីធានាថា ពិតជាមានការបំពេញការងារស្របតាមវិធានការសម្រាលផលប៉ះពាល់ ដែលបានឯកភាពគ្នា (រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមធនាគារពិភពលោក)។

ការពិនិត្យតាមដាន និងការវាយតម្លៃផលប៉ះពាល់សង្គមទាំងនេះ នឹងវាស់វែងចំណុចដូចខាងក្រោម៖

- ផលប៉ះពាល់លើបុគ្គលដែលរងផលប៉ះពាល់ ក្រុមប្រជាជនផ្សេងៗគ្នា គ្រួសារ និងសហគមន៍ ដែលជីវភាពរស់នៅរបស់ពួកគេ ត្រូវរក្សានៅត្រឹមកម្រិតមុនគម្រោង ឬធ្វើឱ្យកាន់តែប្រសើរជាងកម្រិតមុនគម្រោង
- ផលប៉ះពាល់តាមយេនឌ័រ ដែលត្រូវបញ្ចៀសកាត់បន្ថយឱ្យនៅជាអប្បបរមា ឬឆ្លើយតប
- ស្ថានភាពសង្គម សេដ្ឋកិច្ច ក្រោយគម្រោងរបស់សហគមន៍ ដែលរងផលប៉ះពាល់ដោយសារអនុគម្រោង និង
- ការគ្រប់គ្រងវិវាទ ឬជម្លោះនានា។

ដើម្បីវាស់វែងផលប៉ះពាល់ទាំងនេះ ការសិក្សាបុរេសមិទ្ធិលទ្ធភាព ត្រូវកំណត់ពី៖

- សូចនាករជាក់លាក់ ដែលត្រូវពិនិត្យតាមដាន ដោយប្រើប្រាស់ទិន្នន័យបែងចែកតាមយេនឌ័រ
- កំណត់ថាតើនឹងមានការវាស់វែងសូចនាករទាំងនេះជាទៀងទាត់កម្រិតណា និង
- កំណត់ពីចំណុចដៅ សម្រាប់ពិនិត្យតាមដាន សំខាន់ៗ (ឧទាហរណ៍ នៅពាក់កណ្តាលនៃដំណើរការអនុវត្ត ARAP/RAP ប្រសិនបើពាក់ព័ន្ធ)។

គណៈកម្មាធិការអន្តរក្រសួង ដោះស្រាយផលប៉ះពាក់ អាចជ្រើសរើសមន្ត្រីពិនិត្យតាមដានឯករាជ្យម្នាក់ ដើម្បីវាយតម្លៃផលប៉ះពាល់ដែលអាចកើតមានពាក់ព័ន្ធនឹងអនុគម្រោង ទៅតាមលក្ខណៈ និងវិសាលភាពនៃផលប៉ះពាល់ទាំងនោះ។ របាយការណ៍របស់មន្ត្រីពិនិត្យតាមដានទាំងនេះ ត្រូវដាក់ជូនគណៈកម្មាធិការអន្តរក្រសួង ដោះស្រាយផលប៉ះពាល់ និងធនាគារពិភពលោក។

គ. ការពិនិត្យតាមដានផលប៉ះពាល់សរុប៖ ផលប៉ះពាល់ដែលគំនិតផ្តួចផ្តើម និង/ឬសកម្មភាពរបស់អនុគម្រោងមានលើធនធានបរិស្ថាន និងសង្គមក្នុងខេត្តទាំងប្រាំមួយ ក៏នឹងត្រូវពិនិត្យតាមដានផងដែរ ដោយធ្វើការពិចារណាលើការអភិវឌ្ឍន៍ដទៃទៀត ដែលអាចកើតឡើងផងដែរ។

57. ដើម្បីធានាថា ជនជាតិដើមភាគតិចបានចូលរួមក្នុងដំណើរពិនិត្យតាមដាន និងវាយតម្លៃ និងមានការបង្កើតក្រុមពិនិត្យតាមដានមួយ ដែលមានសមាសភាពជាអ្នកទទួលផលនៅតាមភូមិ។ សមាសភាពនៃគណៈកម្មាធិការនេះ អាចមានការប្រែប្រួលអាស្រ័យទៅតាម ដំណើរការពិគ្រោះយោបល់ដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ និងប្រើប្រាស់រចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចចិត្តពិសេស របស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗ ក៏ដូចជា លក្ខខណ្ឌតម្រូវឱ្យមានតុល្យភាពយេនឌ័រ និងតុល្យភាពអន្តរជំនាន់។ ក្រុមពិនិត្យតាមដានទាំងនេះ នឹងពិនិត្យឡើងវិញលើរបាយការណ៍ពិនិត្យតាមដាន និងបរិស្ថាន និងសង្គម ដូចរៀបរាប់ខាងលើ ក៏ដូចជារបាយការណ៍ប្រចាំត្រីមាស ដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ អំពីស្ថានភាពនៃការអនុវត្តអនុគម្រោង។ លើសពីនេះនៅឆ្នាំនីមួយៗ មេភូមិនឹងពិនិត្យលើសកម្មភាពអនុគម្រោង ដែលកំពុងអនុវត្តក្នុងភូមិ ដើម្បីបញ្ជាក់ថាតើការសាងសង់ ការរៀបចំកិច្ចសន្យា និងការងារផ្សេងទៀត ត្រូវបានអនុវត្តសមស្របដែរឬទេ។ អាជ្ញាធរនៅកម្រិតអនុគម្រោង ត្រូវពិនិត្យ និងតាមដានការអនុវត្តផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចឱ្យបានជាប់ជាប្រចាំ។

## 10.0 យន្តការដោះស្រាយបណ្តឹងសារទុក្ខ

58. អាជ្ញាធរខេត្តត្រូវបង្កើតនូវគណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅកម្រិតមូលដ្ឋាន (ថ្នាក់ខេត្ត ស្រុក និងឃុំ) ដែលត្រូវដឹកនាំដោយអភិបាលខេត្ត ឬអភិបាលខេត្តរង អភិបាលស្រុក និងមេឃុំ។ សម្រាប់ យន្តការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ឃុំ សមាជិកនៃយន្តការដោះស្រាយបណ្តឹងសារទុក្ខនេះ គឺជាតំណាងមកពីគ្រួសារ ដែលរងផលប៉ះពាល់ដោយសារគម្រោង ដែលត្រូវជ្រើសរើសចេញពីក្នុងចំណោមក្រុមប្រជាជន ដែលរងផលប៉ះពាល់ដោយសារគម្រោង។ ក្នុងករណីសហគមន៍ជនជាតិដើមភាគតិច គណៈកម្មាធិការនៅថ្នាក់ឃុំនឹងត្រូវបង្កើតឡើង និងមានការរៀបចំដំណើរការពិគ្រោះយោបល់ ដោយសេរីជាមុន នឹងផ្អែកតាមព័ត៌មានត្រឹមត្រូវ។ គណៈកម្មាធិការទាំងនេះ នឹងបង្កើតរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចចិត្តពិសេស សម្រាប់ សហគមន៍ជនជាតិដើមភាគតិចនីមួយៗ ក៏ដូចជា ត្រូវធានាឱ្យមានតុល្យភាពយេនឌ័រ និងតុល្យភាពអន្តរជំនាន់។ គណៈកម្មាធិការទាំងនេះ នឹងទទួលបានវាយតម្លៃ ព្រមទាំងសម្របសម្រួលដំណោះស្រាយជាការឆ្លើយតបចំពោះការព្រួយបារម្ភពាក្យបណ្តឹង និងបណ្តឹងសារទុក្ខរបស់ប្រជាជនដែលរងផលប៉ះពាល់ និងគ្រួសារដែលរងផលប៉ះពាល់ ដោយសារគម្រោង។ គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខ និងបំពេញមុខងារក្នុងអំឡុងរយៈពេលទាំងមូលរបស់គម្រោង រួមនឹងរយៈពេលធានាការខូចខាត ក្រោយរយៈពេលរបស់គម្រោងផងដែរ ដើម្បីប្រយោជន៍ប្រជាជន និងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង។ ព័ត៌មានពិស្តារអំពីយន្តការដោះស្រាយបណ្តឹងសារទុក្ខ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈនៅថ្នាក់ឃុំ ដូចជា តាមរយៈផ្ទាំងរូបភាព និងឯកសារ រូបភាពផ្សេងទៀត។ ពុំមានការគិតថ្លៃសេវាសម្រាប់ការដាក់បណ្តឹងសារទុក្ខឡើយ។

59. ក្នុងគម្រោងដែលជនជាតិដើមភាគតិចរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលរាល់ពាក្យបណ្តឹងទាំងអស់ ត្រូវលើកយកមកធ្វើការពិភាក្សា និងត្រូវមានការចរចាក្នុងសហគមន៍ដែលប្រជាជន និងគ្រួសាររងផលប៉ះពាល់ដោយសារគម្រោង កំពុងរស់នៅ។ ក្នុងករណីដែលគ្រួសាររងផលប៉ះពាលដោយសារគម្រោងដាក់ពាក្យបណ្តឹង គឺជាគ្រួសារមកពីសហគមន៍ជនជាតិដើមភាគតិច ពួកគេអាចស្នើសុំឱ្យមានអ្នកសម្របសម្រួលម្នាក់នៅអមជាមួយនឹងពួកគេ ដែលអ្នកសម្របសម្រួលរូបនេះ ទទួលបានការទូទាត់ពីអនុគម្រោង និងត្រូវបានជ្រើសរើសដោយមានការឯកភាពពីគ្រួសាររងផលប៉ះពាល់ដោយសារគម្រោង។ អ្នកសម្របសម្រួលរូបនេះ គឺជាអ្នកដែលចេះភាសារបស់ជនជាតិដើមភាគតិច និងត្រូវបំពេញតួនាទីជាអ្នកស្វែងរកមតិគាំទ្រឱ្យគ្រួសាររងផលប៉ះពាល់ដែលកំពុងកើតទុក្ខមិនសុខចិត្តក្នុងអំឡុងដំណើរការនេះ និងត្រូវធានាឱ្យមានការការពារសិទ្ធិរបស់ជនជាតិដើមភាគតិច។

60. បណ្តឹងសារទុក្ខរបស់ប្រជាជន និងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង ពាក់ព័ន្ធនឹងការ អនុវត្តផែនការដោះស្រាយផលប៉ះពាល់ និងទទួលបានការឆ្លើយតប តាមរយៈការចរចាក្នុងគោលបំណងឈានទៅសម្រេចការឯកភាពគ្នាមួយ។ បណ្តឹងមានជម្រើសឆ្លងកាត់បួនដំណាក់កាល (ដូចរៀបរាប់ខាងក្រោម) មុនពេលដាក់ទៅកាន់តុលាការ ដែលជាជម្រើសចុងក្រោយ។

### *ដំណាក់កាលទី ១៖ ថ្នាក់ឃុំ*

61. គ្រួសាររងផលប៉ះពាក់ដោយសារគម្រោង ដែលកើតទុក្ខមិនសុខចិត្ត អាចដាក់ពាក្យបណ្តឹងទៅកាន់ មេឃុំ។ មេឃុំ នឹងកោះឱ្យមានកិច្ចប្រជុំក្រុម ដើម្បីធ្វើការសម្រេចចិត្តអំពីសកម្មភាពដែលត្រូវធ្វើ ដើម្បីឆ្លើយតបចំពោះពាក្យបណ្តឹងមិនឱ្យហួសរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីគ្រួសាររងផលប៉ះពាល់ដោយសារគម្រោង ដែលកើតទុក្ខមិនសុខចិត្ត បានដាក់ពាក្យបណ្តឹងរួច។ សមាសភាពដែលចូលរួមក្នុងកិច្ចប្រជុំក្រុម គួររួមមាន មេឃុំ តំណាងការិយាល័យស្រុក PRSC-WG និងគ្រួសាររងផលប៉ះពាល់ដោយសារគម្រោង ដែលកើតទុក្ខមិនសុខចិត្ត។ មេឃុំជាអ្នកទទួលខុសត្រូវកត់កំណត់ហេតុ និងរក្សាទុកឯកសារ នៃពាក្យបណ្តឹងទាំងអស់ ដែលកំពុងឆ្លើយតប។ ប្រសិនបើក្រោយរយៈពេល ១៥ ថ្ងៃ គ្រួសាររងផលប៉ះពាល់ដោយសារគម្រោង ដែលកើតទុក្ខមិនសុខចិត្ត ពុំបានទទួលព័ត៌មានពីអាជ្ញាធរភូមិ ឬឃុំ ឬប្រសិនបើគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោងពុំពេញចិត្តជាមួយនឹងការសម្រេចចិត្ត ដែលធ្វើឡើងក្នុងដំណាក់កាលទី ១ នោះទេ គេអាចដាក់ពាក្យបណ្តឹងនេះទៅកាន់សាលាស្រុកជាលាយលក្ខណ៍អក្សរដោយដោយផ្ទាល់មាត់បាន។

### *ដំណាក់កាលទី ២៖ សាលាស្រុក*

62. សាលាស្រុកមានរយៈពេល ១៥ ថ្ងៃ ដើម្បីដោះស្រាយពាក្យបណ្តឹង ដើម្បីឱ្យអ្នកពាក់ព័ន្ធទាំងអស់ អស់ចិត្ត។ ប្រសិនបើគេពុំអាចដោះស្រាយបណ្តឹងនៅដំណាក់កាលនេះបានទេ សាលាស្រុកត្រូវបញ្ជូនករណីនេះទៅគណៈកម្មាធិការដោះស្រាយបណ្តឹង

សារទុក្ខនៅថ្នាក់ខេត្ត។

***ដំណាក់កាលទី ៣៖ គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ខេត្ត***

63. គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ខេត្ត ដែលមានសមាសភាព ជាអភិបាលខេត្ត ឬអភិបាលខេត្តរង ជាប្រធានគណៈកម្មាធិការ និងមានសមាជិកជាប្រធានមន្ទីរពាក់ព័ន្ធ (ដែលនឹងត្រូវបង្កើតឡើងក្នុងខេត្តនីមួយៗ មុនពេល DMS) ជួបប្រជុំជាមួយភាគីដែលកើតទុក្ខមិនសុខចិត្ត និងព្យាយាមដោះស្រាយបណ្តឹងនេះ។ គណៈកម្មាធិការនេះ អាចរៀបចំឱ្យទីភ្នាក់ងារពិនិត្យតាមដានខាងក្រៅ ពិនិត្យលើ DMS។ ក្នុងអំឡុង ៣០ ថ្ងៃក្រោយដាក់បណ្តឹងសារទុក្ខទៅកាន់គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ខេត្តរួចហើយ ត្រូវមានការចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ហើយសំណៅចម្លងនៃសេចក្តីសម្រេចនេះ ត្រូវផ្ញើទៅកាន់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ក្រសួងអភិវឌ្ឍន៍ជនបទ និងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង។

***ដំណាក់កាលចុងក្រោយ៖ នីតិវិធីតុលាការ***

64. ប្រសិនបើគ្រួសាររងផលប៉ះពាល់ដោយសារគម្រោងពុំពេញចិត្តជាមួយនឹងដំណោះស្រាយដែលស្នើឡើងដោយគណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ខេត្ត ផ្អែកតាមគោលនយោបាយ ដែលបានព្រមព្រៀងគ្នា ក្នុង RF-RP នោះទេ គណៈកម្មាធិការនេះ ត្រូវរៀបចំនីតិវិធីរដ្ឋបាល ប្រឆាំងនឹងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង ដោយមានការចូលរួមពីព្រះរាជអាជ្ញាខេត្ត។ ករណីនេះនឹងត្រូវដាក់ទៅកាន់តុលាការខេត្ត និងដោះស្រាយក្រោមក្របខ័ណ្ឌនៃវិធានតុលាការ។ ក្នុងពេលជាមួយគ្នា គ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង ក៏អាចដាក់បណ្តឹងនេះទៅកាន់តុលាការខេត្តផងដែរ។ ក្នុងអំឡុង ដំណើរការក្តី រាជរដ្ឋាភិបាលកម្ពុជានឹងស្នើសុំឱ្យតុលាការអនុញ្ញាតឱ្យគម្រោងនេះបន្តអនុវត្ត ដោយពុំមានការអាក់ខាន ខណៈពេលដែលករណីនេះកំពុងស្ថិតក្នុងដំណើរការសវនាការ។ ប្រសិនបើភាគីណាមួយពុំពេញចិត្តជាមួយនឹងការវិនិច្ឆ័យរបស់តុលាការខេត្តនោះទេ ភាគីនោះអាចប្តឹងឧទ្ធរណ៍បន្ថែមទៀត។ រាជរដ្ឋាភិ- បាលកម្ពុជាត្រូវអនុវត្តទៅតាមសេចក្តីសម្រេចរបស់តុលាការ។

65. បន្ថែមពីលើយន្តការខាងលើនេះ នឹងជាបុព្វសិទ្ធិរបស់ប្រជាជន និងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង គេអាចដាក់បណ្តឹងសារទុក្ខទៅកាន់ស្ថាប័នផ្សះផ្សារផ្សេងទៀត ដូចជា ក្រុមប្រឹក្សាចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃតាមវត្តអារាម ឬស្ថាប័នដោះស្រាយវិវាទផ្សេងទៀត ដែលទទួលស្គាល់ដោយប្រជាជន និងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង។

## 11.0 ការរៀបចំបង្ហាញព័ត៌មានអំពីផែនការអភិវឌ្ឍជនជាតិដើមភាគតិច ដែលត្រូវរៀបចំក្រោម IPPF

66. ក្នុងករណីដែលគម្រោងទំនងជាបង្កផលប៉ះពាល់ ឬផ្តល់ជាប្រយោជន៍ដោយផ្ទាល់ដល់សហគមន៍ជនជាតិដើមភាគតិច គម្រោងនេះនឹងមិនទទួលការអនុម័តចុងក្រោយឡើយ រហូតដល់ពេលដែល SIA-IPDP ត្រូវបានបង្ហាញពេញលេញ សមស្របតាមវប្បធម៌នៃគម្រិតសហគមន៍ ដែលរងផលប៉ះពាល់។ មធ្យោបាយបង្ហាញព័ត៌មាននេះ ត្រូវលើកយកមកធ្វើការពិភាក្សាក្នុងអំឡុងដំណើរការនៃកិច្ចពិគ្រោះយោបល់ ដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ ប៉ុន្តែអាចតម្រូវឱ្យមានការរៀបចំឯកសារនេះជាក្រដាសស្នាម ដោយប្រើប្រាស់ភាសានៅមូលដ្ឋានសម្រាប់ចែកក្នុងកិច្ចប្រជុំសាធារណៈ (ឧទាហរណ៍ នៅក្នុងមជ្ឈមណ្ឌលសហគមន៍ជាដើម) ការចែកសេចក្តីសង្ខេបមួយទំព័រ (ជាភាសាសមស្រប) នៅក្នុងកិច្ចប្រជុំសាធារណៈ ក៏ដូចជា ការបង្ហាញផ្ទាល់មាត់ ដោយប្រើប្រាស់ភាសាសមស្រប ធ្វើឡើងដោយទីប្រឹក្សា ដែលត្រូវបានជួលឱ្យរៀបចំ និងពិគ្រោះយោបល់អំពីលិខិតុបករណ៍ទាំងនេះ។ បន្ទាប់ពីលិខិតុបករណ៍ទាំងនេះ ត្រូវបានបង្ហាញពេញលេញ និងលើកយកមកធ្វើការពិភាក្សានៅកម្រិតសហគមន៍រួច ដំណើរការនេះ ត្រូវបញ្ចូលជាឯកសារក្នុងលិខិតុបករណ៍ពាក់ព័ន្ធ ហើយនិងត្រូវពិនិត្យឡើងវិញ ដោយអ្នកឯកទេសផ្នែកសង្គមរបស់គម្រោង និងដាក់តាំងបង្ហាញនៅលើគេហទំព័ររបស់គម្រោង។ ឯកសារទាំងនេះ ក៏ត្រូវបញ្ជូនទៅឱ្យធនាគារពិភពលោក ដើម្បីពិនិត្យ និងបង្ហាញលើគេហទំព័ររបស់ធនាគារផងដែរ។

## 12.0 ថវិកា

67. តារាងទី ២ បង្ហាញពីចំណាយប៉ាន់ប្រមាណសម្រាប់អនុវត្ត IPPF និងសកម្មភាពពាក់ព័ន្ធនៃអនុគម្រោង។ ប្រភពហិរញ្ញប្បទានសម្រាប់រៀបចំ និងអនុវត្ត IPP របស់គម្រោង នឹងត្រូវ

ផ្តល់ក្រោមសមាសភាគ ៣ ការគ្រប់គ្រងគម្រោង នៃគម្រោង CASDP។

**តារាងទី ៣៖ ចំណាយប៉ាន់ប្រមាណសម្រាប់អនុវត្ត IPPF និងសកម្មភាពពាក់ព័ន្ធរបស់អនុគម្រោង**

| សកម្មភាព | ពិពណ៌នា | ចំណាយប៉ាន់ប្រមាណ (ដុល្លារ) |
|---|---|---|
| ១ | កិច្ចពិគ្រោះយោបល់ជាមួយនឹងជនជាតិដើមភាគតិច ក្នុងខេត្តគោលដៅរបស់គម្រោង សម្រាប់រៀបចំ ESMP និងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) | ២០.០០០ |
| ២ | ការជ្រើសរើសទីប្រឹក្សាជាតិ (ក្រៅម៉ោង) ដើម្បីរៀបចំ IPDPs និងផ្នែកពាក់ព័ន្ធ នៃ EMSPs | ៣០.០០០ |
| ៣ | ការជ្រើសរើស (ទៅតាមការចាំបាច់) អ្នកសម្របសម្រួល ដែលចេះនិយាយពីរភាសា ដើម្បីគាំទ្រដល់គ្រួសារ ដែលរងផលប៉ះពាល់ដោយគម្រោងជាជនជាតិដើមភាគតិច ក្នុងអំឡុងដំណើរការឆ្លើយតបចំពោះបណ្តឹងសារទុក្ខ | ៥.០០០ |
| ៤ | ការជ្រើសរើសទីប្រឹក្សាជាតិ ដើម្បី រៀបចំការវាយតម្លៃលើគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច តាមបែបចូលរួម | ២០.០០០ |
| | **សរុប** | **៧៥.០០០** |

# ឧបសម្ព័ន្ធទី ១. ការវិភាគសង្គម សម្រាប់រៀបចំគម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា

## សេចក្ដីផ្ដើម

**1.** ព្រះរាជាណាចក្រកម្ពុជាកំពុងរៀបចំគម្រោងពិពិធកម្មវិស័យកសិកម្ម។ របាយការណ៍នេះមានគោលបំណងបង្ហាញពីចំណេះដឹងសារគារ ដែលអាចប្រើប្រាស់ជាធាតុចូលសម្រាប់ការរៀបចំលិខិតុបករណ៍ការពារផលប៉ះពាល់សង្គម ជាពិសេសក្របខ័ណ្ឌផែនការជនជាតិភាគតិច។ របាយការណ៍នេះ បែងចែកជាបួនផ្នែក។ ផ្នែកទី ១ សង្ខេបព័ត៌មានសំខាន់ៗ ដែលបានពីឯកសារវាយតម្លៃគម្រោងចុងក្រោយគេ ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៨ (PAD2505), ដែលបង្ហាញពីគោលបំណងនៃការអភិវឌ្ឍគម្រោង ដែលត្រូវបានស្នើឡើង ខេត្ត អ្នកទទួលផល សមាសភាគ និងសមាសភាគរងនានា។ ផ្នែកទី ២ ផ្ដោតលើការវិភាគហានិភ័យ ដែលអាចកើតមានឡើងពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពគម្រោងនៅតាមសហគមន៍ជនជាតិភាគតិច។ ផ្នែកទី ៣ និងផ្នែកទី ៤ នៃរបាយការណ៍នេះ លើកស្នើនូវអនុសាសន៍មួយចំនួន សម្រាប់រៀបចំក្របខ័ណ្ឌផែនការជនជាតិភាគតិច និងក្របខ័ណ្ឌគោលនយោបាយស្ដីពីការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ។ សូមកត់សម្គាល់ថា សិក្ខាសាលារៀបចំរបាយការណ៍ ត្រូវបានរៀបចំឡើងជាមួយនឹងមន្ត្រីបង្គោលផ្នែកការពារផលប៉ះពាល់មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិភាក្សាពីលទ្ធផលនៃការវិភាគសង្គមនេះ និងរៀបចំលិខិតុបករណ៍ការពារផលប៉ះពាល់សង្គមដែលពាក់ព័ន្ធ។

**2.** ការវិភាគនេះ ធ្វើឡើង តាមរយៈការពិនិត្យលើឯកសារពាក់ព័ន្ធ និងការសម្ភាសជាមួយតួអង្គរដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ ក៏ដូចជា ការពិភាក្សាក្រុមគោលដៅ ជាមួយសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ស្ត្រីនៅតាមខេត្ត ដែលអាចជ្រើសរើសធ្វើជាតំបន់គោលដៅរបស់គម្រោង។ ឯកសារនានា ដែលត្រូវបានប្រើប្រាស់សម្រាប់ការពិនិត្យលើឯកសារពាក់ព័ន្ធនេះ រួមមាន យុទ្ធសាស្ត្រជាតិ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកសិកម្ម ជនជាតិដើមភាគតិច និងទិដ្ឋភាពសង្គមផ្សេងទៀត។ ការវិភាគនេះក៏បញ្ចូលការសិក្សាឯកសារគម្រោង សង្ខេបគោលនយោបាយ និងឯកសារពាក់ព័ន្ធ ដែលបានពីប្រភពមិនមែនរដ្ឋាភិបាលនានា ដូចជា ADB, AusAID/ CAVAC, FAO, IFAD, UNDP, និង USAID/HARVEST។ ក្នុងករណីដែលពាក់ព័ន្ធ ឯកសារសិក្សាស្រាវជ្រាវក៏ត្រូវបានបញ្ចូលក្នុងការពិនិត្យលើឯកសារពាក់ព័ន្ធផងដែរ។ បន្ថែមពីលើការពិនិត្យលើឯកសារពាក់ព័ន្ធ ការសម្ភាសពាក់កណ្ដាលរចនាសម្ព័ន្ធត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ២ ខែ មីនា រហូតដល់ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៨ ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗមកពីរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ។ សរុបមានការសម្ភាសចំនួន ២១ លើក ដោយការសម្ភាសមួយលើក ចំណាយពេលប្រមាណ ៤៥ នាទី។ ចុងក្រោយការចុះវាយតម្លៃដល់មូលដ្ឋាន ត្រូវបានធ្វើឡើងក្នុងខេត្តសក្ដានុពលមួយចំនួន ដូចជា ខេត្តព្រះវិហារ មណ្ឌលគិរី ស្ទឹងត្រែង និងសៀមរាប។ ក្នុងខេត្តនីមួយៗ មានការរៀបចំការពិភាក្សាក្រុមគោលដៅ ជាមួយតួអង្គពាក់ព័ន្ធ ដូចជា អាជ្ញាធរមូលដ្ឋាន សហគមន៍កសិកម្ម និងសហគមន៍មូលដ្ឋាន រួមនឹងជនជាតិដើមភាគតិច និងស្ត្រីផងដែរ។ ប្រធានបទដែលត្រូវបានលើកយកមកធ្វើការពិភាក្សាក្នុងអំឡុងពេលពិភាក្សាក្រុមគោលដៅទាំងនេះ រួមមាន ជម្រើសប្រកបមុខរបរចិញ្ចឹមជីវិត និងបញ្ហាប្រឈមនានា សំណូមពរអំពីរៀបបង្កើនលទ្ធភាពទទួលបានទីផ្សារ និងប្រតិកម្មចំពោះសកម្មភាពគម្រោង ដែលនឹងត្រូវអនុវត្ត។ ការសម្ភាសដែលធ្វើឡើងនៅទីក្រុងភ្នំពេញ និងការពិភាក្សាក្រុមគោលដៅ នៅក្នុងខេត្ត សុទ្ធតែមានកំណត់ហេតុទាំងអស់។

## ផ្នែកទី I. សារគារគម្រោង

**3.** គោលបំណងនៃការរៀបចំគម្រោង ដែលត្រូវបានស្នើឡើងនេះ គឺដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍសង្វាក់តម្លៃផលិតផលវិស័យកសិកម្ម ដែលមានលក្ខណៈពិពិធកម្ម នៅតាមទីតាំងភូមិសាស្ត្រមួយចំនួននៅកម្ពុជា និងផ្ដល់ការឆ្លើយតបជាបន្ទាន់ ប្រកបដោយប្រសិទ្ធភាព ក្នុងករណីដែលមានវិបត្តិ ឬស្ថានភាពអាសន្ន ដែលបំពេញទៅតាមលក្ខណៈសមស្រប ដើម្បីទទួលបានការគាំទ្រពីគម្រោងនេះ។

**4.** **ទីតាំងភូមិសាស្ត្រគោលដៅ៖** គម្រោងនេះនឹងអនុវត្តក្នុងខេត្តចំនួន ១២ បូករួមទាំងទីក្រុងភ្នំពេញ។ ខេត្តទាំងនេះត្រូវបានជ្រើសរើស ដោយសារស្ថានភាពកៀក្រៃបរិស្ថានសមស្រប សម្រាប់ផលិតផលដែលមានតម្លៃខ្ពស់ ដោយទីក្រុងភ្នំពេញ គឺជាទីតាំង ដែលអាចមានសហគ្រាសកសិកម្មខ្នាតតូចជាច្រើនមានលទ្ធភាពចូលរួម។ ខេត្តទាំងនេះ រួមមាន បាត់ដំបង មណ្ឌលគិរី ស្ទឹងត្រែង រតនគិរី ព្រះវិហារ កំពង់ចាម កំពង់ធំ ក្រចេះ សៀមរាប កណ្ដាល កំពង់ស្ពឺ កំពង់ឆ្នាំង និងភ្នំពេញ។ នៅតាមបណ្ដាខេត្តទាំងនេះ គេរំពឹងថាទីតាំងគម្រោង ដែលបំពេញតាមលក្ខណៈសម្បត្តិសមស្រប នឹងស្ថិតនៅតាមតំបន់ ដែល (i) មានក្រុមអ្នកផលិតសកម្ម ដែលបានចងក្រងគ្នាជាក្រុមរួចជាស្រេច, (ii) មានទឹកប្រើប្រាស់ច្រើនរដូវក្នុងកម្រិតអាចជឿទុកចិត្តបាន និង (iii) មានផ្លូវតូចៗ

ដែលមានស្រាប់ ដែលមានប្រវែងអតិបរមា ១០ គីឡូម៉ែត្រ សម្រាប់ភ្ជាប់ជាមួយនឹងផ្លូវដែលអាចប្រើប្រាស់បានគ្រប់រដូវ។

5. **អ្នកទទួលផលគោលដៅ៖** អ្នកទទួលផលផ្ទាល់ពីគម្រោងនេះ រួមមាន កសិករខ្នាតតូច និងខ្នាតមធ្យម ដែលត្រូវបានចងក្រងជាក្រុមអ្នកផលិត ឬជាសហគមន៍ និងបង្ហាញពីសក្តានុពល និងចំណាប់អារម្មណ៍ចង់អភិវឌ្ឍន៍ អាជីវកម្មកសិកម្មរបស់ពួកគេ និងអាជីវកម្មកសិកម្មខ្នាតតូច និងខ្នាតមធ្យម ដែលចាប់អារម្មណ៍ចង់សហការដោយផ្ទាល់ជាមួយកសិករ ដើម្បីរួមគ្នាអភិវឌ្ឍន៍អាជីវកម្ម/សង្វាក់តម្លៃរបស់ខ្លួន។ គម្រោងក៏នឹងមានការផ្តល់ព័ត៌មាន សម្ភារៈ និងយុទ្ធនាការឱ្យចំក្រុមគោលដៅដែលជាកសិករស្ត្រី និងម្ចាស់អាជីវកម្មផងដែរ។ អ្នកទទួលផលដោយប្រយោលផ្សេងទៀត រួមមាន អ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវបានកែសម្រួលសម្រាប់លើកកម្ពស់ការភ្ជាប់ទំនាក់ទំនងជាមួយទីផ្សារ ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ។ ការបង្កើនភាពអាចរកបាននូវទិន្នន័យ និងព័ត៌មាន និងលទ្ធភាពទទួលបានទិន្នន័យ និងព័ត៌មានទាំងនេះ ព្រមទាំងយន្តការធានាគុណភាព (ដូចជា ក្របខ័ណ្ឌនិយតកម្ម ហេដ្ឋារចនាសម្ព័ន្ធ) នឹងផ្តល់ជាប្រយោជន៍ដល់វិស័យទាំងមូល។

6. ខាងក្រោមនេះបង្ហាញពីសមាសភាគ និងសមាសភាគរង ដែលត្រូវបានស្នើឡើងសម្រាប់គម្រោងនេះ៖

a. **សមាសភាគទី ១៖ ផ្តល់លទ្ធភាពឱ្យមានការធ្វើពិពិធកម្មកសិកម្ម** សមាសភាគទី ១ នេះនឹងប្រើប្រាស់អភិក្រមសង្វាក់តម្លៃ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទៅតាមស្ថានភាពទីផ្សារ និងស្ថានភាពតម្រូវការ ដើម្បីកសាងនូវសង្វាក់តម្លៃ ដែលមានលក្ខណៈប្រកួតប្រជែង និងមានពិពិធភាព ដែលក្នុងនោះអង្គការអ្នកផលិត (POs) និងសមាជិករបស់អង្គការទាំងនេះ អាចទទួលបានទីផ្សារក្នុងស្រុក និងអន្តរជាតិ ដែលផ្តល់ឱ្យពួកគេនូវប្រាក់ចំណេញខ្ពស់ត្រលប់មកវិញ ហើយសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម អាចទទួលបានវត្ថុធាតុដើមដែលកាន់តែមានគុណភាពជាប់ជាប្រចាំ ហើយក្នុងពេលជាមួយគ្នា បង្កើនសមត្ថភាពស្រូបយក និងសម្រេចស្តង់ដារ គុណភាព ដែលទីផ្សារត្រូវការ។ សមាសភាគនេះ ពោរពេញដោយការប្រកួតប្រជែង និងភាគច្រើនដឹកនាំ ដោយវិស័យឯកជន ដោយរដ្ឋាភិបាលបំពេញតួនាទីជាអ្នកសម្របសម្រួល។ ប៉ុន្តែ សមាសភាគនេះក៏នឹងផ្តល់ការគាំទ្រដល់រដ្ឋាភិបាល និងតួអង្គក្នុងវិស័យសាធារណៈ ក្នុងការផ្តល់សេវាចាំបាច់នានា ដូចជា ការផ្សព្វផ្សាយកសិកម្ម ដែលភ្ជាប់ទំនាក់ទំនងជាមួយនឹងទីផ្សារ និងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈល្អប្រសើរជាងមុន ដូចជា ផ្លូវជនបទ និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន (higher order irrigation infrastructure) ក្នុងករណីដែលពុំមានសេវាដែលផ្តល់ដោយវិស័យឯកជន ឬប្រជាពលរដ្ឋពុំអាចទទួលសេវា ដែលផ្តល់ដោយវិស័យឯកជនបាន។

i. ***សមាសភាគរង ១.១៖ ការគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការពិពិធកម្ម*** សមាសភាគរងនេះ មានគោលបំណងផ្សព្វផ្សាយព័ត៌មានអំពីគម្រោងដល់តួអង្គពាក់ព័ន្ធនានា ផ្តល់ការគាំទ្រដល់ការបង្កើតក្រុមការងារ ការកំណត់រកឱកាសអាជីវកម្ម និងនិងការបំប្លែងឱកាសទាំងនេះជាផែនការពិពិធកម្ម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដូចជា ការរៀបចំសំណើអាជីវកម្ម (BPr) និងផែនការអាជីវកម្ម (BPl) ដែលមានប្រសិទ្ធភាព និងធ្វើការវាយតម្លៃ និងជ្រើសរើសសំណើ និងផែនការទាំងនោះ និងចុងក្រោយពង្រឹងសមត្ថភាពក្រុមអ្នកផលិត ដែលបានជ្រើសរើស ព្រមទាំងសមាជិករបស់ក្រុមទាំងនោះ ព្រមទាំងសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម។ សមាសភាគរងនេះនឹងផ្តល់ហិរញ្ញប្បទានដល់៖ (ក) យុទ្ធនាការបង្កើនការយល់ដឹង និងការប្រមូលតួអង្គពាក់ព័ន្ធនានា ដើម្បីបង្កើតជាក្រុម, (ខ) ការរៀបចំ និងការវាយតម្លៃផែនការពិពិធកម្ម ដែលមានប្រសិទ្ធភាព និងសំណើអាជីវកម្ម ដែលអាចផ្តល់នូវប្រាក់ចំណេញ និង (គ) ការរៀបចំ និងការវាយតម្លៃផែនការពិពិធកម្មពេញលេញរាប់បញ្ចូលទាំងផែនការអាជីវកម្ម សម្រាប់សំណើអាជីវកម្មដែលត្រូវបានជ្រើសរើស និង (ឃ) ការគាំទ្រដល់ការអភិវឌ្ឍផែនការអាជីវកម្ម។

ii. ***សមាសភាគរង ១.២៖ ការផ្តល់ហិរញ្ញប្បទានដល់ការធ្វើពិពិធកម្មកសិកម្ម*** ដើម្បីសម្រួលដល់ការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគលើសកម្មភាពផលិតកម្ម និងជំនួយបច្ចេកទេស ក្នុងសំណើធ្វើពិពិធកម្ម និងផែនការរអាជីវកម្ម ដែលទទួលបានការអនុម័ត គម្រោងនេះនឹងបង្កើតនូវកម្មវិធីផ្តល់ឥណទាន (Credit Line) ដោយមានការបំពេញបន្ថែមដោយកម្មវិធីផ្គូរផ្គងជំនួយខ្នាតតូច។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ នឹងជួយសម្រេចគោលបំណងជារួមរបស់គម្រោង ពោលគឺការធ្វើពិពិធកម្មទៅរកដំណាំដែលមានតម្លៃខ្ពស់ និងការធ្វើពាណិជ្ជភាវូបនីយកម្មវិស័យកសិកម្ម។ ដូច្នេះ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះនឹងផ្តល់

ហិរញ្ញប្បទានដល់ការវិនិយោគច្រើនប្រភេទ ពាក់ព័ន្ធនឹងការធ្វើពិពិធកម្មកសិកម្ម ដូចជា ឧបករណ៍កែច្នៃ ឧបករណ៍ធារាសាស្ត្រក្នុងកសិដ្ឋាន (ឧបករណ៍ស្រោចស្រពបែបបន្តក់ទឹក (drip) យន្តហោះខ្នាតតូច (microject) ប្រព័ន្ធបាចទឹក (sprinkler) ឃ្លាំងរក្សាកសិផលក្នុងកសិដ្ឋាន ។ល។) គ្រឿងយន្តកសិកម្ម ឃ្លាំង (ត្រជាក់) យានយន្ត ឧបករណ៍សម្រាប់វេចខ្ចប់ និងធ្វើពាណិជ្ជកម្ម ដំណោះស្រាយប្រព័ន្ធបច្ចេកវិទ្យានិងសារគមនាគមន៍ ធនធានកសិកម្ម និងការវិនិយោគសមស្របផ្សេងទៀត។

iii. ***សមាសភាគរង ១.៣៖ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។*** គម្រោងនេះនឹងគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធ សាធារណៈ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលមិននៅជាប់ជាមួយនឹងកសិដ្ឋាន និងផ្លូវជនបទ ដើម្បីបង្កើន លទ្ធភាពរបស់ក្រុមអ្នកផលិតក្នុងការធ្វើពិពិធកម្ម ការដាំដុះរបស់ខ្លួន តាមរយៈការបង្កើនការផ្គត់ផ្គង់ទឹកទៅតាមតម្រូវការជាក់ស្តែង និងដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារប្រកបដោយប្រសិទ្ធភាព ដែលអាចជួយពន្លឿនការផ្គត់ផ្គង់ និងកាត់បន្ថយការខាតបង់ឱ្យនៅតិចជាអប្បបរមា។

b. **សមាសភាគទី ២៖ លើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងការគ្រប់គ្រងការត្រួតពិនិត្យគុណភាព។** គោលបំណងនៃសមាសភាគទី ២ នេះ គឺដើម្បីពង្រឹងចំណេះដឹងជាមូលដ្ឋាន សមត្ថភាពវិភាគទិន្នន័យ និងប្រព័ន្ធអនុវត្តលិខិតបទដ្ឋានគតិយុត្តិក្នុងវិស័យសាធារណៈ ព្រមទាំងការអនុវត្ត និងការពង្រឹងការអនុវត្តប្រព័ន្ធទាំងនេះ។ ការងារទាំងនេះនឹងរួមចំណែកពង្រីក និងបង្កើនតម្លាភាពចំណេះដឹង ព្រមទាំងកែលម្អការធ្វើសេចក្តីសម្រេចចិត្តរបស់តួអង្គក្នុងវិស័យសាធារណៈ និងវិស័យឯកជន ដែលផលសម្រេចបាននឹងមានវិសាលភាពលើសពីអនុគម្រោង PA ដែលបានទទួលការគាំទ្រទៅទៀត។ ប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងគុណភាពកសិកម្ម នឹងផ្តល់ប្រយោជន៍ដល់អ្នកពាក់ព័ន្ធផ្ទាល់ ក៏ដូចជា កសិករ ក្រុមអ្នកផលិត និងសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម ដែលកំពុងប្រតិបត្តិការនៅក្នុងឃុំ និងខេត្តផ្សេងទៀត ក្រៅតែពីតំបន់គម្រោងផងដែរ។ សមាសភាគនេះក៏នឹងផ្តល់ហិរញ្ញប្បទានដល់ការងារវិភាគ និងផ្តល់ប្រឹក្សាគោលនយោបាយ ដើម្បីតម្រង់ទិសការវិនិយោគរបស់រដ្ឋាភិបាលក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម។

i. ***សមាសភាគរង ២.១៖ ប្រព័ន្ធព័ត៌មានកសិកម្ម។*** នឹងមានការផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគលើការបន្តអភិវឌ្ឍន៍ និងលើកកម្ពស់ការប្រើប្រាស់ផែនទីដី/ក្សេត្របរិស្ថាន ប្រព័ន្ធផ្តល់ព័ត៌មានទាន់ពេលវេលាពាក់ព័ន្ធនឹងកសិកម្ម ស្ថិតិផលិតកម្មអាហារ និងកសិកម្ម/ទិន្នន័យជំរឿន (ព័ត៌មានទីផ្សារកសិកម្ម និងប្រព័ន្ធព័ត៌មានទីផ្សារ) និងទិន្នន័យដទៃទៀត។ បច្ចេកវិទ្យា ICT ថ្មីៗ នឹងត្រូវយកមកប្រើប្រាស់ ដើម្បីធានាឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយបំផុត និងការប្រើប្រាស់ឱ្យបានល្អបំផុតនូវទិន្នន័យ និងព័ត៌មានដែលមាន សម្រាប់ការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្តរបស់តួអង្គពាក់ព័ន្ធក្នុងវិស័យសាធារណៈ និងវិស័យឯកជន ពាក់ព័ន្ធនឹងផលិតកម្ម ការកែច្នៃ ការស្វែងរកទីផ្សារផលិតផលកសិកម្ម និងសេវាកម្ម។ លើសពីនេះ ក៏នឹងមានការគាំទ្រដល់ការប្រមូលព័ត៌មានទីផ្សារ ដើម្បីកំណត់រកឱកាសរយៈពេលមធ្យម និងរយៈពេលវែង សម្រាប់ផលិតផលសមស្របផងដែរ។នឹងមានការផ្តល់ថវិកា សម្រាប់ផ្តល់ព័ត៌មានឱ្យចំក្រុមគោលដៅ ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្របថ្មីៗ ដើម្បីផ្តល់ព័ត៌មានដល់កសិករជាស្ត្រីចូលរួមក្នុងគម្រោង ដែលមានលទ្ធភាពតិចតួច ដើម្បីយល់ពីឯកសារជាលាយល័ក្ខណ៍អក្សរ។ ការផ្សព្វផ្សាយព័ត៌មាន នឹងបញ្ចូលសារអប់រំ ពាក់ព័ន្ធនឹងអាហារូបត្ថម្ភ និងឯកសារនានា ពាក់ព័ន្ធនឹងការពង្រឹងលទ្ធផលអាហារូបត្ថម្ភរបស់គម្រោង។

ii. ***សមាសភាគរង ២.២ ការគ្រប់គ្រងគុណភាព។*** ការវិនិយោគ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការការពាររុក្ខជាតិ និងភូតគាមអនាម័យ សុខភាពសត្វ និងការឃ្លាំមើលភូតគាមអនាម័យ សុខភាពសត្វ និងសុវត្ថិភាពអាហារ ប្រព័ន្ធរាយការណ៍ និងប្រព័ន្ធអធិការកិច្ច ហើយនឹងមានការគាំទ្រដល់ប្រព័ន្ធពង្រឹងការអនុវត្តការគ្រប់គ្រងលើវត្ថុធាតុដើមកសិកម្ម។ ការគាំទ្រនេះ រួមមាន ការគាំទ្រដល់ការបង្កើតសេវាចេញវិញ្ញាបនបត្រ ផ្តល់អាជ្ញាប័ណ្ណ និងត្រួតពិនិត្យ និងគ្រប់គ្រងគុណភាពផ្សេងទៀត ព្រមទាំងការរៀបចំ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ អំពីការអនុវត្តល្អផ្នែកកសិកម្ម (GAP) និងការអនុវត្តល្អផ្នែកផលិតផលសរីរាង្គ ការចិញ្ចឹមសត្វ និងការប្រើប្រាស់ព័ត៌មានសម្គាល់ភូមិសាស្ត្រ។ល។

c. ***សមាសភាគទី ៣៖ ការគ្រប់គ្រងគម្រោង និងការពិនិត្យតាមដាន និងវាយតម្លៃ។*** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាទីភ្នាក់ងារប្រតិបត្តិចម្បង សម្រាប់អនុវត្ត និងគ្រប់គ្រងការសម្របសម្រួលជារួម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងទទួលខុសត្រូវគ្រប់គ្រងការសម្របសម្រួលជារួម និងអនុវត្តសមាសភាគទាំង៤។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គភាពបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ដែលជាដៃគូអនុវត្តទទួលខុសត្រូវលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ជនបទ។ នឹងមានការគាំទ្រដល់ការបង្កើតក្រុមសម្របសម្រួលគម្រោង និងគាំទ្រការអនុវត្តក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលស្ថិតនៅជាមួយលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក។ ការបង្កើតគណៈកម្មាធិការដឹកនាំកម្រិតខ្ពស់ នឹងត្រូវធ្វើឡើងផងដែរ ដើម្បីផ្តល់ដំបូន្មាន និងដោះស្រាយបញ្ហាអន្តរវិស័យ ដែលកើតឡើងថ្មីៗ។ ព័ត៌មានលំអិត នឹងត្រូវរៀបរាប់ ក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង។

d. ***សមាសភាគទី ៤៖ សមាសភាគឆ្លើយតប ចំពោះស្ថានភាពអាសន្នជាយថាហេតុ៖*** គោលបំណងនៃ សមាសភាគឆ្លើយតបចំពោះស្ថានភាពអាសន្នជាយថាហេតុ ដែលមានការវិភាជន៍ថវិកាបណ្តោះអាសន្នស្មើសូន្យនេះ គឺដើម្បីផ្តល់លទ្ធភាពឱ្យមានការវិភាជន៍ថវិកាឡើងវិញ ទៅតាមយន្តការឆ្លើយតបបន្ទាន់របស់ IDA សំដៅផ្តល់ការឆ្លើយតបបន្ទាន់ ចំពោះវិបត្តិ ឬស្ថានភាពអាសន្ន ទៅតាមការចាំបាច់។ សៀវភៅណែនាំស្តីពីការឆ្លើយតបចំពោះ ស្ថានភាពអាសន្ន (ERM) នឹងត្រូវរៀបចំឡើង សម្រាប់សកម្មភាពនានា ក្រោមសមាសភាគនេះ ដោយរៀបរាប់លម្អិតពីការរៀបចំសម្រួលនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម ការការពារផលប៉ះពាល់ និងការរៀបចំការអនុវត្តចាំបាច់ផ្សេងទៀត។ ក្នុងករណីដែលត្រូវអនុវត្តសមាសភាគនេះ នឹងមានការកែសម្រួលក្របខ័ណ្ឌលទ្ធផល ដោយធ្វើការរៀបចំរចនាសម្ព័ន្ធផ្លូវការសារជាថ្មី ដើម្បីបញ្ចូលសូចនាករសមស្រប ពាក់ព័ន្ធនឹងសកម្មភាពឆ្លើយតប ចំពោះស្ថានភាពអាសន្ន។

## ផ្នែកទី II. ការវិភាគសង្គម

7. **ហានិភ័យសង្គមសម្រាប់គម្រោងនេះ បច្ចុប្បន្នត្រូវបានបែងចែកចំណាត់ថ្នាក់មានកម្រិតតិចតួច៖** គេរំពឹងថា ការអនុវត្តគម្រោងទាំងនេះ នឹងបង្កផលប៉ះពាល់សង្គម ក្នុងកម្រិត និងក្នុងវិសាលភាពផ្សេងៗគ្នា អាស្រ័យទៅតាមវិសាលភាព និងទីតាំងនៃអនុគម្រោងទាំងនោះ ដែលពុំទាន់ត្រូវបានកំណត់លម្អិតនៅឡើយ។ ផ្អែកតាមកិច្ចពិគ្រោះយោបល់បឋម ជាមួយអ្នកពាក់ព័ន្ធ សក្តានុពលទាក់ទិននឹងការវិនិយោគ ដែលអាចធ្វើឡើង គម្រោងនេះ ទំនងជានាំឱ្យមានការអនុវត្តគោលនយោបាយការពារផលប៉ះពាល់សង្គមចំនួនពីរ របស់ធនាគារពិភពលោក គឺគោលនយោបាយស្តីពីជនជាតិដើមភាគតិច (OP/BP 4.10) និងគោលនយោបាយស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) និងគោលនយោបាយការពារផលប៉ះពាល់បរិស្ថានចំនួនប្រាំពីរ ដូចតទៅ៖ ការវាយតម្លៃបរិស្ថាន (OP/BP 4.01), ដែនជម្រកធម្មជាតិ (OP/BP 4.04), ព្រៃឈើ (OP/BP 4.36), ការគ្រប់គ្រងសមាសភាគចង្រៃ (OP 4.09), ធនធានវប្បធម៌រូបវន្ត (OP/BP 4.11), សុវត្ថិភាពទំនប់ (OP/BP 4.37), និងគម្រោងដែលស្ថិតនៅតាមផ្លូវទឹកអន្តរជាតិ (OP/BP 7.50)។

8. **ជនជាតិដើមភាគតិច (OP/BP 4.10)** គោលនយោបាយអនុវត្តចំពោះជនជាតិភាគតិចដែលអាចរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល។ ដូច្នេះក្របខ័ណ្ឌផែនការជនជាតិដើមភាគតិចនេះ ត្រូវបានរៀបចំឡើង ដើម្បីតម្រង់ទិសដល់ការរៀបចំ និងការអនុវត្តសកម្មភាពនៅតាមទីតាំងជាក់លាក់។ ការរៀបចំលិខិតុបករណ៍នេះ ត្រូវបានធ្វើឡើងផ្អែកទៅតាមព័ត៌មាន ដែលបានពីការវាយតម្លៃ/ការវិភាគសង្គមបឋម ដែលផ្តោតលើឧបសគ្គ និងហានិភ័យ (រាប់បញ្ចូលទាំងការពុំមានសិទ្ធិកាន់កាប់ដីធ្លីបានជាប់លាប់ ដែលអ្នកផលិតខ្នាតតូចមកពីសហគមន៍ជនជាតិដើមភាគតិច ដែលកំពុងចូលរួមក្នុងសង្វាក់តម្លៃកសិកម្មកំពុងជួបប្រទះ។ ក្រសួងអភិវឌ្ឍន៍ជនបទ មានអង្គភាពផ្តោតលើជនជាតិដើមភាគតិចមួយ ដែលផ្តល់ដំបូន្មានអំពីរបៀបជំរុញឱ្យមានការចូលរួមពីសហគមន៍ជនជាតិភាគតិច និងសហគមន៍ជនជាតិដើមភាគតិច ហើយក្នុងពេលជាមួយគ្នាអគ្គនាយកដ្ឋានកសិកម្មមានផ្តល់ជាកម្មវិធីបណ្តុះបណ្តាល ដែលរៀបចំឡើង ស្របទៅតាមតម្រូវការពិសេសរបស់អ្នកទទួលផលទាំងនេះ។

9. **ក្របខ័ណ្ឌគតិយុត្តរបស់ប្រទេសកម្ពុជា ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ភាគច្រើនមានសង្គតិភាពជាមួយនឹងស្តង់ដារបរិស្ថាន និងសង្គមអន្តរជាតិ។** មានការទទួលស្គាល់វប្បធម៌ជនជាតិដើមភាគតិច បើទោះបីជាមានការផ្តោតការយកចិត្តទុកដាក់ក្នុងកម្រិតខ្ពស់ជារួមលើវប្បធម៌ខ្មែរ ដែលជាវប្បធម៌ជាតិ និងស្ថានភាពពុំទាន់ដាច់ស្រេច

របស់ជនជាតិភាគតិច ដែលមានទំនាក់ទំនងជាមួយប្រទេសជិតខាងយ៉ាងណាក៏ដោយ។ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ច្បាប់ និងយុទ្ធសាស្រ្តជាតិជាច្រើន ដូចជា ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ សុទ្ធតែទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិច វប្បធម៌របស់ពួកគេ និងសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តក្របខ័ណ្ឌនេះ ទើបតែចាប់ផ្តើមកាលពីពេលថ្មីៗនេះតែប៉ុណ្ណោះ។ កាលយល់ដឹងអំពីជនជាតិដើមភាគតិចនៅមានកម្រិតទាប ហើយសមត្ថភាពស្ថាប័ននៅមានកម្រិតខ្សោយនៅឡើយ បើទោះបីជាមានការគាំទ្រពីសង្គមស៊ីវិលយ៉ាងណាក៏ដោយ។ លើសពីនេះ ឯកសារប្រតិបត្តិការសម្រាប់ផ្តល់ការណែនាំអំពីការអនុវត្តគោលនយោបាយ ផ្តោតលើជនជាតិដើមភាគតិចនៅខ្វះខាតនៅឡើយ។ ដូច្នេះហានិភ័យដែលគម្រោងវិនិយោគអាចបង្កផលប៉ះពាល់អវិជ្ជមាន នៅមានកម្រិតខ្ពស់នៅឡើយ ក្នុងវិស័យជាច្រើនដែលគម្រោងធនាគារពិភពលោក អាចនឹងមានវត្តមាននាពេលខាងមុខនេះ ដូចជា ក្នុងវិស័យព្រៃឈើ និងវិស័យកសិ-ពាណិជ្ជកម្មជាដើម។ ក្នុងវិស័យផ្សេងទៀត គេអាចគ្រប់គ្រងហានិភ័យទាំងនេះ ដោយប្រើប្រាស់ប្រព័ន្ធរបស់ជាតិ និងគោលនយោបាយរបស់ធនាគារពិភពលោក រួមបញ្ចូលគ្នា។

10. **គោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ (OP/BP 4.12)** ត្រូវយកមកអនុវត្តផងដែរ ដោយហេតុថា គម្រោងនេះ នឹងផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមួយចំនួន (ដូចជា ធារាសាស្រ្ត ផ្លូវ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធទីផ្សារជាដើម)។ ដូច្នេះ ការធ្វើលទ្ធកម្មដីធ្លីតូចតាច ឬការធ្វើឱ្យបាត់បង់ទ្រព្យសម្បត្តិឯកជន (ដូចជា ដំណាំ ឬដើមឈើផលិតកម្មជាដើម) ប្រហែលជាចាំបាច់ត្រូវធ្វើឡើង។ ដើម្បីសម្រេចគោលដៅនេះ ក្របខ័ណ្ឌគោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់/តាំងទីលំនៅ ត្រូវបានរៀបចំឡើង ដោយសហការជាមួយនឹងអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ និងបានទទួលការឯកភាពពីគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើសពីនេះក្រសួងអភិវឌ្ឍន៍ជនបទក៏មានបទពិសោធន៍អនុវត្តគោលនយោបាយស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តរបស់ ADB ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទផងដែរ និងបានបង្កើតការិយាល័យមួយ ដែលមានភារកិច្ចគ្រប់គ្រងផលប៉ះពាល់សង្គម និងបរិស្ថាន។

11. **រដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល និងច្បាប់អស្សាមិករណ៍ បានដាក់ចេញនូវទស្សនទានជាមូលដ្ឋានគ្របដណ្តប់លើការធ្វើលទ្ធកម្មដីធ្លី និងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តនៅកម្ពុជា។** ខណៈពេលដែលបញ្ញត្តិជាច្រើនក្នុងច្បាប់ទាំងនេះ បង្ហាញពីគោលការណ៍យ៉ាងរឹងមាំក៏ដោយ មានគម្លាតសំខាន់ៗចំនួនបីរវាងក្របខ័ណ្ឌគតិយុត្តនេះ ជាមួយនឹងស្តង់ដាអន្តរជាតិនានា ពាក់ព័ន្ធនឹង (i) ការបញ្ចូលឱ្យបានពេញលេញនូវបញ្ហាដីធ្លីទៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន, (ii) ជនដែលរងផលប៉ះពាល់ដែលពុំមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ និង (iii) ការស្តារឡើងវិញនូវមុខរបរចិញ្ចឹមជីវិតបន្ទាប់ពីការតាំងទីលំនៅ។ ការបង្ហាញព័ត៌មានជាសាធារណៈ និងការដោះស្រាយបណ្តឹងសារទុក្ខ ក៏ជាចំណុចខ្សោយនៅក្នុងក្របខ័ណ្ឌនោះផងដែរ។ ផ្ទុយទៅវិញ ក្របខ័ណ្ឌគតិយុត្តសម្រាប់តំបន់ការពារជាទូទៅដាក់កំហិតលើការប្រើប្រាស់ដីធ្លី បើទោះបីជាការមិនចាំបាច់យ៉ាងណាក៏ដោយ។ ពាក់ព័ន្ធនឹងការអនុវត្តវិញ រដ្ឋាភិបាល តាមរយៈអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ដែលស្ថិតក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកសាងសមត្ថភាព រៀបចំផែនការ និងថវិកាលទ្ធកម្មដីធ្លី និងការតាំងទីលំនៅ បើទោះបីជាបញ្ហាប្រឈមពាក់ព័ន្ធនឹងការសម្របសម្រួលជាមួយនឹងទីភ្នាក់ងារអនុវត្ត និងជាមួយថ្នាក់ក្រោមជាតិ ហាក់បីដូចជា កត្តាដាក់កំហិតលើប្រសិទ្ធភាពនៃការអនុវត្តយ៉ាងណាក៏ដោយ។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ កាលពីពេលថ្មីៗនេះ ទើបតែរៀបចំបញ្ចប់នីតិវិធីប្រតិបត្តិការស្តង់ដា សម្រាប់ការធ្វើលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ ដើម្បីភ្ជាប់គម្លាតរវាងក្របខ័ណ្ឌជាតិ និងគោលនយោបាយរបស់អ្នកផ្តល់ជំនួយអន្តរជាតិ។ ជាមួយនឹងនីតិវិធីថ្មីៗទាំងនេះ ចាំបាច់ត្រូវមានការធ្វើបច្ចុប្បន្នភាពអភិក្រម ដែលប្រើប្រាស់ សម្រាប់រៀបចំ និងអនុវត្តគម្រោង។

12. **ពាក់ព័ន្ធនឹងផលប៉ះពាល់បរិស្ថាន ដែលអាចកើតមានឡើងវិញ** គម្រោងនេះទំនងជានឹងបង្កឱ្យមានផលប៉ះពាល់បណ្តោះអាសន្នជាទ្រង់ទ្រាយតូច ដែលពុំអាចប្តូរត្រឡប់មកវិញបាន ដោយសារតែគម្រោងនេះ មានគោលបំណងបង្កើតនូវប្រព័ន្ធព័ត៌មានកសិកម្ម និងស្បៀង និងប្រព័ន្ធគ្រប់គ្រងហានិភ័យ, ធ្វើពិពិធកម្មប្រព័ន្ធកសិកម្ម បង្កើនផលិតភាព និងអភិវឌ្ឍន៍ទីផ្សារផលិតផលកែច្នៃ ដែលមានតម្លៃខ្ពស់, ផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា ដូចជា ផ្លូវកម្រិតទី ៣ និងការស្តារឡើងវិញនូវសំណង់ធារាសាស្រ្ត ព្រមទាំងកែលម្អមន្ទីរពិសោធន៍។ ហេតុផលភាគច្រើន ដែលនាំឱ្យមានការដាក់ពិន្ទុបែបនេះ គឺដោយសារតែមានការផ្តល់ការគាំទ្រយ៉ាងច្រើនពីសំណាក់ក្រុមការងារ (task team) និងដោយសារបញ្ហាច្បាប់ ពោលគឺដោយសារបទដ្ឋានគតិយុត្តិបរិស្ថានរបស់ប្រទេសនៅមានកម្រិតខ្សោយនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ គេនៅតែអាចគ្រប់គ្រងហានិភ័យបរិស្ថាន ដែលមានលក្ខណៈអវិជ្ជមាន តាមរយៈការដាក់ឱ្យអនុវត្តនូវលិខិតុបករណ៍ការពារផលប៉ះពាល់បរិស្ថានដែលចាំបាច់ និងវិភាជន៍ថវិកាដោយឡែក សម្រាប់ការការពារផលប៉ះពាល់ និងបន្តកសាងសមត្ថភាពមន្រ្តីបង្គោល ដែលទទួលបានពន្ទុកការពារផលប៉ះពាល់បរិស្ថាន

ដែលទទួលបានការចាត់តាំងពីទីភ្នាក់ងារអនុវត្ត។

13. **ស្ថានភាពជាតិពន្ធុនៅកម្ពុជា។** ផ្អែកតាមការអង្កេតប្រជាជនចុងក្រោយ (ក្រសួងផែនការឆ្នាំ ២០១៣) **មានជនជាតិដើមភាគតិចចំនួន ២៤ ក្រុមនៅកម្ពុជា។** តំបន់ដែលមានប្រជាជនរស់ជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ គឺភាគខាងជើង និងភាគឦសាននៃប្រទេសកម្ពុជា ដែលជាតំបន់ដែលមានប្រជាជនរស់នៅឆ្ងាយៗពីគ្នា៖ ក្រចេះ (ស្ទៀង ក្រោល មិល ព្នង កួយ ថ្មូន), មណ្ឌលគិរី (ព្នង ស្ទៀង ក្រោល រូង រ៉ាដ), រតនគិរី (ទំពួន ជារាយ គ្រឹង ព្រៅ ឡូន ក្រវ៉េត កាចក់), ស្ទឹងត្រែង (កួយ ព្នង កាវ៉េត គ្រឹង ខ្មែរឃិ ឡូន ព្រៅ), ព្រះវិហារ (កួយ) និងកំពង់ធំ (កួយ) និងកុលសម្ព័ន្ធតំបន់ភ្នំក្នុងខេត្តកោះកុង (ព័រ), ពោធិ៍សាត់ (ព័រ), កំពង់ស្ពឺ (សួយ) និងព្រះសីហនុ (សើច)។ តំបន់ទាំងនេះ ភាគច្រើន ស្ថិតនៅតាមព្រំដែនជាមួយប្រទេសវៀតណាម ឡាវ និងថៃ។ ផ្ទុយទៅវិញ ភូមិភាគកណ្តាល និងដងទន្លេមេគង្គ គឺជាតំបន់ដែលសំបូរដោយប្រជាពលរដ្ឋខ្មែររស់នៅ។ ការពុំមានការសិក្សាប្រជាជនឱ្យបានគ្រប់គ្រាន់ នាំឱ្យគេមានការលំបាកក្នុងការកំណត់ពីចំនួនក្រុមជាតិពន្ធុក្នុងប្រទេសកម្ពុជា។ ក្រសួងអភិវឌ្ឍន៍ជនបទបានលើកឡើងថា ជនជាតិដើមភាគតិច អាចរស់នៅក្នុងសហគមន៍របស់ពួកគេរួមគ្នាជាមួយនឹងសហគមន៍ខ្មែរទូទៅ ឬបានធ្វើសមាហរណកម្មទាំងស្រុងចូលទៅក្នុងសហគមន៍ខ្មែរ ប៉ុន្តែនៅរក្សាលក្ខណៈពិសេសនៃជាតិពន្ធុរបស់ពួកគេ ហើយក្នុងករណីមួយចំនួន នៅបន្តរក្សាភាសារបស់ពួកគេ។ ការចុះប្រមូលព័ត៌មាននៅតាមខេត្ត ដែលអាចនឹងត្រូវជ្រើសរើសធ្វើជាខេត្តគោលដៅរបស់គម្រោង បានបញ្ជាក់ថា ក្រុមដែលកំណត់អត្តសញ្ញាណខ្លួនឯងថា ជាជនជាតិដើមភាគតិច បានលើកឡើងថា ពួកគេអាចធ្វើការប្រាស្រ័យទាក់ទង ដោយប្រើភាសាខ្មែរបាន ហើយក្នុងពេលជាមួយគ្នា ពួកគេនៅតែបន្តប្រើប្រាស់ភាសាជនជាតិដើមភាគតិចរបស់ពួកគេ។ ពួកគេភាគច្រើនបានលើកឡើងថា ពួកគេបាន និងកំពុងរស់នៅជាមួយនឹងសហគមន៍ជនជាតិខ្មែរជាច្រើនជំនាន់មកហើយ។

14. **ដូចដែលត្រូវបានរកឃើញនៅក្នុងជំរឿនប្រជាជន រដ្ឋាភិបាលបានលើកឡើងថា មានប្រជាជនចំនួន ២៦៤.៦០០ នាក់ជាសមាជិករបស់ក្រុមជនជាតិភាគតិច** ដែលរស់នៅក្នុងប្រទេសនេះ ស្មើនឹងប្រមាណ ៤% នៃចំនួនប្រជាជនសរុប។ ជនជាតិចាម ឬហៅម្យ៉ាងទៀតថា ខ្មែរអ៊ិស្លាម គឺជាសហគមន៍ជនជាតិភាគតិចធំជាងគេទី ២ នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីជនជាតិខ្មែរ ដែលជាក្រុមភាគច្រើន។ សហគមន៍ជនជាតិចិន ដែលមានចំនួនប្រមាណ ៣៤.៥០០ នាក់ គឺជាក្រុមធំជាងគេទី ៣ ហើយអ្វីដែលគួរឱ្យភ្ញាក់ផ្អើល ក្រុមធំជាងគេទី ៤ គឺក្រុមជនជាតិភាគតិចដែលរស់នៅតំបន់ខ្ពង់រាប ដែលហៅថាព្នង។ សហគមន៍ជនជាតិវៀតណាម ត្រូវបានចាត់ចំណាត់ថ្នាក់ថាជាក្រុមធំជាងគេទី ៧។ រហូតមកដល់ឆ្នាំ ១៩៩២ ក្រុមជនជាតិចិន និងជនជាតិវៀតណាម ត្រូវបានចាត់ចំណាត់ថ្នាក់ថាជាក្រុមជនជាតិភាគតិចនៅកម្ពុជា ដែលរស់នៅរួមគ្នានឹងជនជាតិដើមភាគតិច និងជនជាតិចាម។

15. **លើកលែងតែទីក្រុងភ្នំពេញចេញ រាល់ខេត្តទាំងអស់ដែលត្រូវបានលើកស្នើសម្រាប់អនុវត្តគម្រោងនេះ គឺជាតំបន់ដែលក្រសួងអភិវឌ្ឍន៍ជនបទទទួលស្គាល់ថាមានវត្តមាន គ្រួសារជនជាតិភាគតិច** អាចរស់នៅនៅក្នុងសហគមន៍ដាច់ដោយឡែក ឬរស់នៅក្នុងសហគមន៍ ឬនៅលើដីកសិកម្មរួមគ្នាជាមួយនឹងសហគមន៍ខ្មែរទូទៅ។ ដូច្នេះក្នុងអំឡុងពេលអនុវត្តគម្រោងនេះ លទ្ធភាពដែលសកម្មភាពរបស់អនុគម្រោងមួយចំនួន នឹងបញ្ចូលគ្រួសារជនជាតិភាគតិចមួយចំនួនមានកម្រិតខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែលក្ខណៈនៃអន្តរាគមន៍គម្រោងដែលស្នើឡើង និងប្រភេទមុខរបរចិញ្ចឹមជីវិតរបស់ជនជាតិភាគតិច ដែលរស់នៅក្នុងខេត្តអនុវត្តគម្រោង ហានិភ័យសង្គមដែលអាចកើតឡើងចំពោះពួកគេ ត្រូវបានចាត់ទុកដាក់ថាមានតិចតួចប៉ុណ្ណោះ ហើយហានិភ័យភាគច្រើនពាក់ព័ន្ធជាមួយនឹងភាពចាំបាច់ ដើម្បីធ្វើការពិគ្រោះយោបល់ អំពីការងារសាងសង់ ក៏ដូចជាកែសម្រួល និងបកប្រែឯកសារបណ្តុះបណ្តាលអំពីបញ្ហានានា ដូចជា ការប្រើប្រាស់ថ្នាំកសិកម្ម ព័ត៌មានពាក់ព័ន្ធនឹងកសិកម្ម ក៏ដូចជា ឯកសារបង្កើនការយល់ដឹងផ្សេងៗ។

16. **វិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជា៖** ជាមួយនឹងការទទួលស្គាល់ពីសារៈសំខាន់នៃវិស័យកសិកម្មក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច ការធានានូវសមធម៌ និងសន្តិសុខស្បៀង ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច នៅតំបន់ជនបទ រដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្រ្តចំនួនបី៖ (១) ការបង្កើនផលិតភាព ការធ្វើពិពិធកម្ម និងការធ្វើភាវូបពាណិជ្ជកម្មកសិកម្ម តាមរយៈការអនុវត្តបណ្តុះវិធានការ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដូចជា ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្រ្ត ថាមពល/អគ្គិសនី និងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍), (២) ការធ្វើឱ្យកាន់តែប្រសើរនូវការផ្តល់សេវាផ្សព្វផ្សាយ និង (៣) ការធ្វើឱ្យកាន់តែប្រសើរនូវការផ្តល់ធនធានកសិកម្ម កំណែទម្រង់ការគ្រប់គ្រងដីធ្លី សេវាហិរញ្ញវត្ថុ សេវាទីផ្សារ ការចងក្រងកសិករ និងការកសាងស្ថាប័ន និងការសម្របសម្រួល។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ បង្ហាញឱ្យឃើញពីគោលដៅរបស់រដ្ឋាភិបាល ដើម្បីបង្កើនផលិតភាពពិពិធកម្ម និងពាណិជ្ជភាវូបនីយកម្មកសិកម្ម។

17. ក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញផ្សាយឯកសារជំរឿនកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ ២០១៥។ **របាយការណ៍នេះបានរកឃើញថា មានប្រជាពលរដ្ឋ ២,២ លាន**

**គ្រួសារ កំពុងចូលរួមធ្វើសកម្មភាពកសិកម្ម។** បើតាមរបាយការណ៍នានា ក្នុងចំណោមគ្រួសារទាំងនេះ ៨៥% (ស្មើនឹង ១,៨៧ លានគ្រួសារ) កំពុងដាំដុះដំណាំ។ វិស័យកសិកម្ម រួចំណែក ៣៤% នៃផសស របស់ជាតិ និងផ្តល់ការងារដល់កម្លាំងពលកម្ម ៦៣% ក្នុងចំណោមកម្លាំងពលកម្មសរុប (៨,២ លាននាក់)។ មានការប៉ាន់ប្រមាណថា ដីកសិកម្ម (ដីដែលមានជីជាតិ និងដីដែលប្រើប្រាស់សម្រាប់ធ្វើកសិកម្មជាអចិន្ត្រៃយ៍) មានប្រមាណ ៤,៥ លានហិចតា៖ ដីមានជីជាតិ ៣,៩៩ លានហិចតា និងដីដាំដំណាំជាអចិន្ត្រៃយ៍ ០,៥១ លានហិចតា។ ទំហំផ្ទៃដីដាំដុះដំណាំភាគច្រើន ដូចជា (ដំណាំស្រូវ បន្លែ ពោត ម្រេចខ្មៅ) បានបន្តកើនឡើងជាបន្តបន្ទាប់ ដោយផ្ទៃដីដាំកៅស៊ូ និងដំឡូងមីកើនឡើង ៣ ដង។ ផ្ទៃដីសម្រាប់ដាំដុះដំណាំអំពៅ ដូងប្រេង សារម៉ាវ ធុរេន និងពោត ក៏ពង្រីកគួរឱ្យកត់សម្គាល់ផងដែរ ខណៈពេលដែលផ្ទៃដីដំណាំមួយចំនួន ដូចជា ដំឡូងជ្វា, សណ្តែកបាយ, ល្ង, ក្រចៅ, កាហ្វេ និងត្របែក មានការថមថយ។

**18. ប្រព័ន្ធដាំដុះនៅក្នុងប្រទេសកម្ពុជា ផ្តោតសំខាន់លើដំណាំស្រូវ ដែលដាំទាំងរដូវវស្សា ទាំងរដូវប្រាំង។** ស្រូវរដូវវស្សា (២.៥៦៧.៧២៣ ហិចតា) ភាគច្រើនដាំនៅតំបន់វាលទំនាប ដែលត្រូវពឹងអាស្រ័យលើទឹកភ្លៀង (៨០%) ខ្ពង់រាប (២%) និងដាំក្នុងតំបន់ទឹកជ្រៅ/បណ្តែតទឹក (២%)។ ស្រូវរដូវប្រាំង (៤៨៤.៦៩៧ ហិចតា ស្មើនឹង ១៦%) ដាំភាគច្រើននៅតំបន់វាលទំនាប ដែលមានប្រព័ន្ធស្រោចស្រព ជាពិសេស តំបន់ដែលទទួលរងទឹកជំនន់ពីទន្លេមេគង្គ (រួមទាំងតំបន់ជុំវិញបឹងទន្លេសាបផងដែរ)។ កសិករកម្ពុជាក៏ដាំដំណាំផ្សេងទៀត ក្នុងប្រព័ន្ធបង្កបង្កើនផលស្រូវផងដែរ ដូចជា បន្លែ សណ្តែក ដើមឈើហូបផ្លែ។ល។ ដែលជាផ្នែកមួយនៃការដាំដំណាំឆ្លាស់គ្នា ដាំដំណាំចម្រុះលាយជាមួយគ្នា និងដាំដំណាំមួយមុខៗ ដោយឡែកៗពីគ្នា។ ដំណាំស្រូវ-ដាំឆ្លាស់ជាមួយនឹងសណ្តែកបាយ ឬដំណាំសណ្តែកបាយ-ដាំឆ្លាស់ជាមួយនឹងស្រូវ គឺជាប្រភេទដំណាំដាំឆ្លាស់គ្នា ដោយកសិករនៅក្នុងខេត្តកំពង់ស្ពឺ តាកែវ កណ្តាល និងកំពង់ឆ្នាំង។ នៅតំបន់ខ្ពង់រាប និងតំបន់ភ្នំវិញ មានការដាំដំណាំឧស្សាហកម្ម និងដើមឈើហូបផ្លែ ដូចជា កៅស៊ូ ដូងប្រេង អំពៅ ម្រេចខ្មៅ ដំឡូងមី ស្វាយ សារម៉ាវ មាន ជាដើម។ នៅដំណាក់កាលដំបូងៗនៃការដាំដំណាំកៅស៊ូ កសិករដាំពពួកសណ្តែកមួយចំនួននៅចន្លោះដើមកៅស៊ូ ដូចជា សណ្តែកសៀង សណ្តាយបាយ និងសណ្តែកដីជាដើម ដែលដំណាំទាំងនេះក៏ភាគច្រើនត្រូវបានដាំនៅតំបន់ខ្ពង់រាបផងដែរ។

**19. ដើម្បីបង្កើនផលិតភាព និងការធ្វើពិពិធកម្ម ជំនួយបច្ចេកទេស និងជំនួយផ្នែកហិរញ្ញវត្ថុនៅតែត្រូវការជាចាំបាច់ក្នុងទ្រង់ទ្រាយធំ ក៏ដូចជាការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធទាំងអស់** ដើម្បីលើកកម្ពស់ និងបង្កើនលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្ម ប្រព័ន្ធធារាសាស្ត្រ គ្រាប់ពូជ និងបច្ចេកទេសដាំដុះ ដែលធន់ទៅនឹងអាកាសធាតុ ព្រមទាំងការប្រើប្រាស់ធនធានកសិកម្ម និងឥណទានឱ្យបានសមស្រប។ ពូជស្រូវ ១០ មុខ ដែលត្រូវបានជ្រើសរើសសម្រាប់ការបង្កើនផលិតភាព ក្រោមការសាកល្បងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពុំទាន់បានផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់កសិករទាំងអស់នោះឡើយ។ លើសពីនេះ បរិមាណពូជស្រូវទាំង ១០ មុខ នេះ នៅមិនទាន់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់កសិករផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធផ្សេងទៀត មានគោលបំណងរួមគ្នាដម្ទះបញ្ហានេះ តាមរយៈការបង្កើតកសិដ្ឋានស្រាវជ្រាវរបស់រដ្ឋ ដើម្បីផ្គត់ផ្គង់ស្រូវពូជទៅឱ្យក្រុមផលិតស្រូវពូជ ដែលត្រូវផ្គត់ផ្គង់បន្តដល់កសិករ។

**20. ប្រទេសកម្ពុជាទទួលរងគ្រោះញឹកញាប់ដោយសារគ្រោះមហន្តរាយនានា ជាពិសេសគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះធ្ងន់ធ្ងរ ដែលនាំឱ្យមានការបាត់បង់អាយុជីវិត និងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ លំនៅដ្ឋាន និងផលដំណាំនានា។** ចាប់តាំងពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៣ មានផ្ទៃដីប្រមាណ ៤៥២.២១១ ហិចតា (ស្មើនឹង ១៥% នៃផ្ទៃដីដាំដុះស្រូវសរុប) ទទួលរងការបំផ្លិចបំផ្លាញដោយសារគ្រោះរាំងស្ងួត ទឹកជំនន់ និងសត្វល្អិត (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០០៦-២០១៣)។ ក្នុងឆ្នាំ ២០១១ ប្រទេសកម្ពុជាជួបប្រទះនឹងគ្រោះទឹកជំនន់ធ្ងន់ធ្ងរជាងគេមិនធ្លាប់មាន ក្នុងទសវត្សរ៍ចុងក្រោយនេះ។ អង្គការស្បៀង និងកសិកម្មពិភពលោក (២០១២) បានរាយការណ៍ថាមានប្រជាពលរដ្ឋ ៦០.០០០គ្រួសារ (ស្មើនឹង ២៥%) ក្នុងចំណោមគ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារទឹកជំនន់ក្នុងខេត្តចំនួន ១៨ ជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង ដែលស្តែងចេញ តាមរយៈការមានបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ និងរ៉ាំរ៉ៃ ក្នុងចំណោមកុមារក្នុងកម្រិតមួយខ្ពស់។ ក្នុងឆ្នាំ ២០០៩ ខ្យល់ព្យុះកេតសាណាបានវាយប្រហារប្រទេសកម្ពុជាចន្លោះពីថ្ងៃទី ២៩ ខែ កញ្ញា និងថ្ងៃទី ៥ ខែ តុលា។ ក្នុងចំណោមខេត្ត ២៤ មានខេត្តចំនួន ១៤ ទទួលរងផលប៉ះពាល់ដោយសារខ្យល់ព្យុះនេះ និងទឹកជំនន់ទឹកភ្លៀង ដែលកើតឡើងក្រោយព្រឹត្តិការណ៍ខ្យល់ព្យុះនេះ។ ខ្យល់ព្យុះសង្ឃរានេះ ធ្វើឱ្យមនុស្សបាត់បង់ជីវិតចំនួន ៤៣ នាក់ និង ៦៧ នាក់ទទួលរងរបួសធ្ងន់ធ្ងរ។ ខ្យល់ព្យុះនេះបានបំផ្លាញផ្ទះសម្បែង និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រមាណ ៤៩.០០០ គ្រួសារ (ស្មើនឹង ១,៤% នៃចំនួនប្រជាជនសរុបនៅកម្ពុជា)។ ការខាតបង់ ដែលកើតឡើងដោយសារខ្យល់ព្យុះនេះ មានតម្លៃប្រមាណ ៥៦,៥ លានដុល្លារ។ ចុងក្រោយតំបន់ឆ្នេរនៃប្រទេសកម្ពុជា ដែលមានទីតាំងស្ថិតនៅភាគខាងលិច នៃប្រទេស (ខេត្តកំពត ព្រះសីហនុ និងកោះកុង) ជាកន្លែងដែលមានការដាំដុះដំណាំស្រូវ និងដំណាំដទៃទៀត កំពុងជួបប្រទះនឹងការកើនឡើងនូវកម្រិតជាតិប្រៃក្នុងដៃ ដែលនាំឱ្យមានការថយចុះនៃការស្រូបយកជាតិទឹក (ស្រដៀងគ្នានឹងផលប៉ះពាល់នៃគ្រោះរាំងស្ងួតផងដែរ)។ លើសពីនេះ ការកើនឡើងនៃកម្ពស់ទឹកសមុទ្រ ដោយសារការប្រែប្រួលអាកាសធាតុ មានន័យថា ផ្ទៃដីដាំដំណាំស្រូវ

នៅតំបន់ឆ្នេរ និងមានការជ្រាបចូលនូវទឹកសមុទ្រ ដែលក៏នឹងបង្កផលប៉ះពាល់ដល់ការដាំដុះដំណាំផ្សេងទៀតផងដែរ។

**21.** **ស្ត្រីក្នុងវិស័យកសិកម្ម៖** ដូចដែលត្រូវបានរាយការណ៍ក្នុងជំរឿនឆ្នាំ ២០១៥ **ការងារកសិកម្មគឺជាប្រភពការងារដ៏សំខាន់ សម្រាប់បុរស និងស្ត្រីជាច្រើននាក់ (ស្ត្រី ៧៥%) ដែលកំពុងប្រឡូកក្នុងការដាំដុះជាលក្ខណៈគ្រួសារសម្រាប់ហូបចុក។** ស្ត្រីខ្មែរដែលរស់នៅតាមជនបទភាគច្រើន ធ្វើការងារកសិកម្មលើដីខ្លួនឯង ឬធ្វើការងារកសិកម្មដោយពុំទទួលបានប្រាក់ឈ្នួល។ ក្នុងប្រទេសកម្ពុជា ប្រជាពលរដ្ឋដែលប្រកបរបបកសិកម្មមាន ២,៣ លានគ្រួសារ ក្នុងនោះ ៨០% (១.៦១៨.៥៨៨) មានបុរសជាមេគ្រួសារ និង ២០% មានស្ត្រីជាមេគ្រួសារ (៤១២.៥១០)។ កសិករជាស្ត្រីបំពេញ តួនាទីយ៉ាងសំខាន់នៅក្នុងការបំប្លែងកសិផល ជាការធានាសន្តិសុខស្បៀង អាហារូបត្ថម្ភសម្រាប់គ្រួសាររបស់ពួកគេ។ ស្ត្រីជាអ្នកទទួលខុសត្រូវលើការងារផលិតស្បៀង ការជ្រើសរើស និងការរៀបចំចំណីអាហារ ក៏ដូចជា ការថែទាំ និងផ្តល់អាហារដល់កុមារ។ ដូច្នេះពួកគេមានតួនាទីយ៉ាងសំខាន់ ក្នុងការធានាសន្តិសុខស្បៀងដល់គ្រួសាររបស់ពួកគេ។ ស្ត្រីក៏កាន់តែចូលរួមក្នុងផលិតកម្មកសិកម្ម សម្រាប់ធ្វើពាណិជ្ជកម្មផងដែរ ជាពិសេសនៅក្នុងសង្វាក់តម្លៃសាកវប្បកម្ម។ ស្ត្រីនៅក្នុងប្រទេសកម្ពុជាក៏បំពេញតួនាទីសំខាន់នៅក្នុងផ្សារលក់ដុំ និងលក់រាយកសិផលផងដែរ។ ស្ត្រីទាំងនេះ បំពេញតួនាទីជាអ្នកដើរប្រមូលទិញ និង/ឬឈ្មួញ ហើយក៏ជាអ្នកលក់រាយដ៏សំខាន់ផងដែរ ដោយពួកគេធ្វើការងារនៅតាមផ្សារមូលដ្ឋាន ផ្សារខេត្ត និងផ្សារនៅថ្នាក់ជាតិ។ លើសពីនេះ ស្ត្រីក៏ជាដៃគូសំខាន់ក្នុងសហគ្រាសកសិកម្ម ដែលជាសហគ្រាសផ្គត់ផ្គង់ធនធានកសិកម្ម ដោយពួកគេជាអ្នកធ្វើការងារដោយផ្ទាល់ជាមួយនឹងអតិថិជន ផ្តល់ព័ត៌មាន និងចំណេះដឹងអំពីការប្រើប្រាស់ធនធានកិសកម្ម ជីគីមី និងថ្នាំពុលកសិកម្មជាដើម។

**22.** ការពិនិត្យលើឯកសារពាក់ព័ន និងការសម្ភាសដែលត្រូវបានធ្វើឡើងកន្លង បានបញ្ជាក់ថា **ឧបសគ្គផ្អែកតាមយេនឌ័រ ដែលធ្វើឱ្យរាំងស្ទះដល់ការចុះបញ្ជីដីធ្លី រួមមាន៖** បញ្ហាក្នុងការទទួលបានព័ត៌មានអំពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ការលំបាកដែលគ្រួសារដែលមានស្ត្រីជាមេគ្រួសារជួបប្រទះក្នុងការទទួលបានឯកសារ ដើម្បីបញ្ជាក់ពីភាពនៅលីវរបស់ពួកគេ ជាកត្តារាំងស្ទះដល់លទ្ធភាពរបស់ពួកគេក្នុងចុះបញ្ជីដីធ្លី អតុល្យភាពយេនឌ័រក្នុងការគ្រប់គ្រង និងធ្វើសេចក្តីសម្រេចចិត្ត។ ជំរឿនឆ្នាំ ២០១៥ បានរកឃើញថា ក្នុងចំណោមគ្រួសារ ដែលប្រកបរបរកសិកម្មសរុបនៅកម្ពុជា មានប្រមាណ ៨៥% មានដីកសិកម្មប្រើប្រាស់ ដោយជាមធ្យមគ្រួសារប្រកបរបរកសិកម្មមួយមានផ្ទៃដីជាមធ្យម ១.៦៣៧ ហិចតា។ បុរសមានចំនួន ១,៤ លាននាក់ ឬ ៧៣% នៃអ្នកមានប័ណ្ណកកម្មសិទ្ធិទាំងអស់ ខណៈពេលដែលស្ត្រីដែលមាមានប័ណ្ណកម្មសិទ្ធិមាន ០,៥ លាននាក់ ឬស្មើនឹង ២៧%។

**23.** ជំរឿនកសិកម្មក៏បានរកឃើញផងដែរថា **កសិករជាស្ត្រីបំពេញតួនាទីកាន់តែសំខាន់នៅក្នុងការផ្គត់ផ្គង់កសិផលបែបប្រពៃណី ដែលមានតម្លៃខ្ពស់ដល់ទីផ្សារក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ បើធៀបជាមួយនឹងបុរស ស្ត្រីនៅជួបប្រទះនឹងការចាញ់ប្រៀបជាច្រើន ដូចជា លទ្ធភាពផ្លាស់ទីមានកម្រិតទាបជាង កម្រិងអក្ខរកម្មទាបជាង លទ្ធភាពតិចជាងក្នុងការទទួលបានការបណ្តុះបណ្តាល លទ្ធភាពតិចជាងក្នុងទទួលបានព័ត៌មានទីផ្សារ និងលទ្ធភាពតិចជាងក្នុងទទួលបានធនធានផលិតកម្មនានា។** ចំណេះដឹងហិរញ្ញវត្ថុទាបរបស់ស្ត្រី បើធៀបនឹងបុរស និងឧបសគ្គពាក់ព័ន្ធនឹងសុវត្ថិភាពក្នុងការធ្វើដំណើរ ត្រូវបានចាត់ទុកថាជាគម្លាតយេនឌ័រដ៏ធំមួយនៅកម្ពុជា ដើម្បីឱ្យស្ត្រីទទួលបានទីផ្សារ។ ភស្តុតាងនានាក៏បង្ហាញផងដែរថា បុរសអាចប្រឡូកក្នុងការងារផលិតកម្ម និងការផ្សព្វផ្សាយទីផ្សារនៅពេលដែលការធ្វើការងារទាំងនេះផ្តល់នូវប្រាក់ចំណេញក្នុងកម្រិតមួយខ្ពស់។ ដើម្បីស្វែងរកទីផ្សារលក់កសិផលរបស់ខ្លួន កសិកជាស្ត្រីនៅកម្ពុជា ត្រូវការព័ត៌មានទីផ្សារទាន់ពេលវេលាអាចជឿទុកចិត្តបាន និងងាយស្រួលយល់។ ការផ្តល់កម្ចី និងឥណទានក៏មានសារៈសំខាន់ផងដែរ ដើម្បីឱ្យស្ត្រី ដែលប្រកបកសិកម្មខ្នាតតូច អាចមានលទ្ធភាពទិញធនធានកសិកម្មផ្សេងៗ កែលម្អរបៀបដាំដុះ និងអភិវឌ្ឍន៍សហគ្រាសកសិកម្មខ្នាតតូចរបស់ពួកគេ ដើម្បីផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ពួកគេខ្លួនឯង ព្រមទាំងទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគេ។ ការធ្វើសកម្មភាពរួមគ្នា អាចបំពេញតួនាទីសំខាន់ដើម្បីឱ្យស្ត្រីដែលប្រកបរបរកសិកម្មខ្នាតតូច អាចបង្កើនផលិតភាព និងទទួលបានទីផ្សារ។ លើសពីនេះ គំនិតផ្តួចផ្តើម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការទទួលបានទីផ្សារ ក៏ចាំបាច់ត្រូវគិតគូរពិចារណា និងឆ្លើយតបចំពោះឧបសគ្គពាក់ព័ន្ធនឹងយេនឌ័រ ដែលកសិករខ្នាតតូច និងសហគ្រិនកសិកម្មជាស្ត្រីជួបប្រទះផងដែរ។ ដូច្នេះការពង្រឹងលទ្ធភាពទទួលបានទីផ្សាររបស់ពួកគេ តម្រូវឱ្យមានការវិភាគលើសង្វាក់តម្លៃ និងអន្តរាគមន៍ផ្តោតចំគោលដៅ។

**24.** ជាលក្ខណៈប្រពៃណី ដំណាក់កាលដំបូងៗនៃការបង្កបង្កើនផលស្រូវគឺជាការងារដែលបុរសត្រូវធ្វើ ហើយដំណាក់កាលក្រោយៗ គឺជាការងារដែលស្ត្រីត្រូវធ្វើ។ ជាទូទៅបុរសបំពេញការងាររៀបចំដី ខណៈពេលដែលការងារស្ទូង និងសម្អាតស្មៅ ច្រើនតែជាការងារដែលប្រគល់ឱ្យស្ត្រីជាអ្នកធ្វើ។ សកម្មភាពផ្សេងទៀត ដូចជា ការប្រមូលផល ការច្រូត ស្ទូង និងការរកទីផ្សារលក់កសិផល ជាទូទៅ គឺជាការងារដែលធ្វើរួមគ្នា។ បច្ចុប្បន្នតួនាទីទាំងនេះ មានការប្រែប្រួលជាមួយនឹងការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងការធ្វើ

ចំណាកស្រុកយុវជន ចេញពីតំបន់ជនបទ។ ដូច្នេះស្ត្រីកាន់តែប្រឡូកខ្លាំងជាងមុន ក្នុងគ្រប់ការងារដាំដុះទាំងអស់ ដូចជា ការរៀបចំដី ផារាសាស្ត្រ ការបោកស្រូវ និងការជ្រើសរើសកម្មករ ការគ្រប់គ្រងកសិដ្ឋាន និងការជួញដូរជាដើម។ ការរួមចំណែករបស់កសិករជាស្ត្រីចំពោះការដាំដុះដំណាំបន្ទាប់បន្សំ ដូចជា បន្លែ និងការចិញ្ចឹមសត្វពាហនៈ មានវិសាលភាពរីកតែធំផងដែរ។ ដំណាំដែលដាំដុះនៅក្នុងច្បារដំណាំក្នុងបរិវេណផ្ទះ និងសត្វពាហនៈទាំងនេះ ផ្តល់នូវសារធាតុចិញ្ចឹមដ៏សំខាន់ និងរួមចំណែកដល់ការធានាសន្តិសុខស្បៀងរបស់គ្រួសារ។ ដូច្នេះទីផ្សារនៅមូលដ្ឋាន ផ្តល់ឱកាសកាន់តែល្អ ដើម្បីឱ្យស្ត្រីអាចរកប្រាក់ចំណូល តាមរយៈការលក់បន្លែ ដំណាំ និងសត្វពាហនៈជាទ្រង់ទ្រាយតូច។

**25.** **ជនជាតិដើមភាគតិចក្នុងវិស័យកសិកម្ម។** បើតាមក្រសួងអភិវឌ្ឍន៍ជនបទ លក្ខណៈពិសេសជាងគេមួយ របស់សហគមន៍ជនជាតិដើមភាគតិច គឺយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់ពួកគេ ដោយប្រើប្រាស់ផលិតកម្មកសិកម្មជាគោល ដូចជា ការដាំដុះពនេចរ ការដាំដុះស្រូវលិចទឹក ការចិញ្ចឹមជ្រូក និងមាន់ ការប្រមូលអនុផលព្រៃឈើធ្វើជាអាហារ ការបរបាញ់ និងការនេសាទ។ ពួកគេក៏ផលិត និងលក់ទំនិញ និងកម្លាំងពលកម្មតិចតួចផងដែរ។ កសិករជាជនជាតិដើមភាគតិច ភាគច្រើននៅប៉ែកឦសាននៃប្រទេសកម្ពុជា នៅបន្តប្រើប្រាស់បច្ចេកទេសដាំដុះបែបប្រពៃណី៖ ពាក់កណ្តាលពនេចរ ការដាំដុះបែបពនេចរ។ បើទោះបីជាពួកគេមួយចំនួនចាប់ផ្តើមបង្កបង្កើនផលស្រូវនៅតំបន់វាលទំនាប បន្ទាប់ពីដំណើរការនៃការធ្វើសមាហរណកម្មក្នុងទសវត្សរ៍ ៦០ យ៉ាងណាក៏ដោយ ពួកគេនៅបន្តរក្សាវាលសម្រាប់ការធ្វើកសិកម្មពនេចរផងដែរ ដែលនៅតាមទីកន្លែងទាំងនេះ ពួកគេដាំដុះស្រូវតំបន់ខ្ពង់រាប និងដំណាំដទៃទៀតសម្រាប់ធានាសន្តិសុខស្បៀងរបស់ពួកគេ។ មានដំណាំតិចតួចតែប៉ុណ្ណោះ ដែលដាំនៅក្នុងភូមិ ដោយសារតែពួកគេពិបាកការពារពីសត្វស្រុក ដែលជាធម្មតាត្រូវបានគេចិញ្ចឹមឱ្យដើររកចំណីស៊ីពាសវាលពាសកាល។ ដំណាំស្រូវគឺជាដំណាំហូបចុកដ៏សំខាន់នៅក្នុងប្រព័ន្ធដាំដុះពនេចរ ប៉ុន្តែដំណាំផ្សេងទៀត ក៏ត្រូវបានដាំ សម្រាប់ហូបចុកក្នុងគ្រួសារផងដែរ ដូចជា បន្លែ ដំណាំមើម ពពួកត្រឡាច ល្ពៅ ននោង ផ្លែឈើ និងដំណាំមិនប្រើប្រាស់ជាអាហារផ្សេងទៀត ដូចជា ថ្នាំជក់ និងកប្បាសជាដើម។ ការចិញ្ចឹមសត្វ ជាពិសេសគោល ក្របី ជ្រូក និងមាន់ ធ្វើឡើងសម្រាប់បូជា លក់ដើម្បីបានចំណូល ឬសម្រាប់ធ្វើជាអាហារ។

**26.** ក្នុងសម័យខ្មែរក្រហម ជនជាតិដើមភាគតិចដឹងថា បច្ចេកទេសដាំដុះស្រូវតំបន់វាលទំនាប ដែលធ្វើឡើងដោយជនជាតិខ្មែរមកពីតំបន់វាលទំនាប ដែលជាអ្នកជិតខាងរបស់ខ្លួន ផ្តល់នូវទិន្នផលខ្ពស់ជាង និងត្រូវការពលកម្មតិចជាងបច្ចេកទេសដែលប្រើប្រាស់នៅតំបន់ខ្ពង់រាបរបស់ពួកគេ។ អ្នកភូមិមួយចំនួនបាន និងកំពុងបង្កើតវាលស្រែតំបន់វាលទំនាប ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ឬតាមរយៈការធ្វើត្រាប់តាមប្រជាពលរដ្ឋផ្សេងទៀត។ ក្រោយឆ្នាំ ១៩៧៩ ជនជាតិដើមភាគតិចមួយចំនួន បានទម្លាប់កសិកម្មពនេចររបស់ពួកគេវិញ ដោយសារតែបញ្ហាបច្ចេកទេស ឬបញ្ហាផ្សេងទៀត។ សហគមន៍ជនជាតិដើមភាគតិចក៏បាននឹងកំពុងរិះរកជម្រើសចិញ្ចឹមជីវិតផ្សេងទៀតផងដែរ ដូចជា ដាំដើមឈើហូបផ្លែ និងដំណាំអាចលក់ប្តូរជាសាច់ប្រាក់ និងដែលកំពុងមានតម្រូវការខ្ពស់ ដូចជា កាហ្វេ គ្រាប់ស្វាយចន្ទី សណ្តែកខៀវ ខ្ទុរ និងធុរេនជាដើម។ ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធដែលនៅមិនទាន់មានភាពល្អប្រសើរ និងការគាំទ្រទីផ្សារតិចតួច បានបន្ថយបង្អាក់ដល់ទឹកចិត្តដាំដុះដំណាំទាំងនេះរបស់ពួកគេ។

**27.** ការចុះប្រមូលព័ត៌មាននៅក្នុងខេត្តសក្តានុពលទាំងនេះ បានរកឃើញថា **ការទទួលបានទឹក** គឺជាបញ្ហាធំមួយ ដែលកសិករកំពុងជួបប្រទះ ទាំងសហគមន៍មូលដ្ឋាន ទាំងជនជាតិដើមភាគតិច។ បញ្ហាប្រឈមដទៃទៀត ដែលត្រូវបានកំណត់ដោយតំណាងជនជាតិដើមភាគតិច ដែលត្រូវបានសម្ភាស រួមមាន៖

ក. បច្ចេកវិទ្យាកសិកម្មបែបប្រពលវប្បកម្ម កំពុងចូលមកជំនួសទម្លាប់ធ្វើកសិកម្មបែបប្រពៃណីរបស់ជនជាតិដើមភាគតិច។ លើសពីនេះក៏មានការប្រែប្រួលយ៉ាងឆាប់រហ័ស ពីការកាន់កាប់អចលនទ្រព្យជាសមូហភាពទៅជាកម្មសិទ្ធិដីឯកជនក្រោមឥទ្ធិពលរបស់ក្រុមហ៊ុនឯកជន និងបុគ្គលដែលមានឥទ្ធពល។ បញ្ហានេះក៏កើតឡើងដោយសារតែជនជាតិដើមភាគតិច ពុំបានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាំងនេះ។ សហគមន៍ពួកគេពុំបានដឹងពីសិទ្ធិរបស់ពួកគេ ដូចដែលបានលើកឡើងក្នុងច្បាប់របស់ប្រទេសកម្ពុជា និងអនុសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធ។

ខ. ពាក់ព័ន្ធនឹងសង្វាក់តម្លៃកសិកម្មវិញ កង្វះការយល់ដឹងអំពីទីផ្សារ និងតម្លៃកសិផល (ឧទាហរណ៍ ជាធម្មតាស្រូវមានតម្លៃ ១.២០០ រៀល ក្នុងមួយគីឡូក្រាម ប៉ុន្តែជារឿយៗជនជាតិដើមភាគតិចលក់ស្រូវក្នុងតម្លៃ ៧០០ រៀល ក្នុងមួយគីឡូក្រាម) ការបំពេញទៅតាមតម្រូវការទីផ្សារ ពាក់ព័ន្ធនឹងកសិផល (ឧទាហរណ៍ មិនត្រូវទំហំ ព័ណ៌។ល។) និងការផ្តល់តម្លៃទាបសម្រាប់កសិផល កម្រិតនៃការចេះអក្សរ (ជនជាតិដើមភាគតិច ភាគច្រើនមិនចេះអក្សរ ដូច្នេះពុំអាចទទួលបាន

ព័ត៌មានទីផ្សារបាន – លើកស្នើនូវដំណោះស្រាយ ប្រើប្រាស់វិទ្យុ) ការពុំមានសមត្ថភាពរៀបចំផែនការ។

គ. មានការលើកឡើងជាច្រើនលើកជាច្រើនសាថា បំណុលគឺជាការគំរាមកំហែងដ៏ធំមួយសម្រាប់ជនជាតិដើមភាគតិចទូទាំងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។ បំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានការប្រាក់ ៣% ក្នុងមួយខែ ពោលគឺច្រើនជាងការប្រាក់ស្តង់ដា ១,៨% ក្នុងមួយខែ។ ជារឿយៗជនជាតិដើមភាគតិចពុំបានដឹងពីបញ្ហានេះឡើយ ដោយសារតែពួកគេពុំអាចអានកិច្ចសន្យាបាន (ពុំចេះអក្សរ) ពួកគេគិតថា ៣% គឺជាអត្រាការប្រាក់ទាប។ ជនជាតិដើមភាគតិចមួយចំនួនខ្ចីពីអ្នកចងការប្រាក់ ជាមួយនឹងអត្រាការប្រាក់រហូតដល់ ១៥ ទៅ ២០% ក្នុងមួយខែ។ ជារឿយៗពួកគេសងកម្ចីទៅអ្នកចងការប្រាក់ទាំងនេះ ជាមួយនឹងការផ្តល់នូវកសិផលរបស់ពួកគេ ទៅតាមតម្លៃដែលកំណត់ដោយឈ្មួញកណ្តាល ឬដោយផ្តល់ដីសងជំនួសវិញ ដែលធ្វើឱ្យពួកគេកាន់តែត្រូវផ្លាស់ទីឆ្ងាយចូលទៅក្នុងតំបន់ព្រៃ។

**តារាងទី ៤៖** ***ការវិភាគផលប៉ះពាល់សង្គមបឋម***

| ***សមាសភាគរង*** | ***អត្ថប្រយោជន៍ដែលអាចមាន*** | ***ហានិភ័យ និងផលប៉ះពាល់ជាអវិជ្ជមាន*** | ***វិធានការដែលផ្តល់លទ្ធភាពឱ្យមានការចូលរួម/សម្រាលផលប៉ះពាល់*** |
|---|---|---|---|
| ***១.១៖ ការរៀបចំ និងការអនុវត្តផែនការគាំទ្រ ដល់ការធ្វើពិពិធកម្ម*** | ប្រតិបត្តិការអាជីវកម្មកាន់តែទទួលបានជោគជ័យ នៅពេលដែលសំណើនេះ ត្រូវបានអនុវត្ត, ពិនិត្យតាមផលិតភាព ដើម្បីជួយសម្រួលឱ្យមានការចុះកិច្ចព្រមព្រៀងជាមួយអ្នកទិញ ដោយទទួលបានអត្ថប្រយោជន៍ពីផែនការដែលរៀបចំ (បន្ថែមពីលើការបង្កលក្ខណៈងាយស្រួលឱ្យទទួលបានឥណទាន) | ហានិភ័យនៃការផាត់ចេញ ឬហានិភ័យនៃការពុំប្រើប្រាស់សេវារៀបចំផែនការអាជីវកម្ម ដោយជនជាតិដើមភាគតិច ដោយសារតែឧបសគ្គពាក់ព័ន្ធនឹងអក្ខរកម្ម | ការប្រើប្រាស់យុទ្ធនាការបង្កើនចំណេះដឹង ដោយប្រើប្រាស់មធ្យោបាយសោតទស្សន៍<br><br>ការគាំទ្របន្ថែមសម្រាប់សហគមន៍ជនជាតិដើមភាគតិច ដូចជា ការប្រើប្រាស់អ្នកផ្តល់ការណែនាំអំពីរបៀបធ្វើអាជីវកម្មជាដើម |
| ***១.២៖ ការផ្តល់ហិរញ្ញប្បទានដល់ការធ្វើពិពិធកម្មកសិកម្ម*** | ការទទួលបានឥណទាន ដោយអស់ចំណាយសមស្រប ជាមួយនឹងអត្រាការប្រាក់បែបប្រកួតប្រជែង | ហានិភ័យនៃការផាត់ចេញ ឬការមិនប្រើប្រាស់សេវាគាំទ្រហិរញ្ញវត្ថុក្នុងចំណោមអង្គការ ជនជាតិដើមភាគតិច និងកសិករ ដោយសារការព្រួយបារម្ភជុំវិញហានិភ័យនៃការកើនឡើងការជាប់បំណុលវ័ណ្ឌក<br><br>ហានិភ័យបន្ទាប់បន្សំ ដែលពាក់ព័ន្ធចេញពីសកម្មភាពរបស់សហគ្រាសកសិកម្មខ្នាតតូច ដែលប្រើប្រាស់ឥណទាន អាចបង្កផលប៉ះពាល់ជាអវិជ្ជមាន លើដីធ្លី និងបរិស្ថានរបស់សហគមន៍ជនជាតិដើមភាគតិច | ជ្រើសរើសជនជាតិដើមភាគតិចធ្វើជាកម្មករគាំទ្រដល់គម្រោង អាចផ្តល់ដំបូន្មានអំពីការប្រើប្រាស់ឥណទានដល់ជនជាតិដើមភាគតិច ក៏ដូចជា ផលប៉ះពាល់នៃការប្រើប្រាស់ឥណទានទាំងនេះ<br><br>បញ្ជីអវិជ្ជមានក្នុង ESMF ដើម្បីបញ្ចូលសកម្មភាពនានា ដែលអាចបង្កផលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិច ក៏ដូចជា ក្រុមហ៊ុនដែលអាចបង្កផលប៉ះពាល់ដោយសហគមន៍ទាំងនេះកន្លងមក |
| ***១.៣៖ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ*** | ការបង្កើនលទ្ធភាពទទួលបានទីផ្សារ ការកាត់បន្ថយចំណាយលើការដឹកជញ្ជូនទំនិញកសិកម្ម<br><br>ការបង្កើនផលិតភាព ដោយសារការទទួលបានទឹក (ត្រូវបានសហគមន៍ជនជាតិដើមភាគតិចដែលត្រូវបានពិគ្រោះយោបល់ចាត់ទុកជាអាទិភាព) | លទ្ធភាពធ្វើលទ្ធកម្មដីធ្លី និងផលប៉ះពាល់នៃការហូរចូលនូវកម្លាំងពលកម្ម ដោយសារផលប៉ះពាល់ពាក់ព័ន្ធនឹងការសាងសង់ | ការរៀបចំផែនការដោះស្រាយផលប៉ះពាល់តាមទីតាំង និងផែនការជនជាតិដើមភាគតិច និងភស្តុតាងបង្ហាញពីការគាំទ្រទូលំទូលាយរបស់សហគមន៍ (ផ្អែកតាមការពិគ្រោះយោបលដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ) សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ |
| ***២.១៖ ប្រព័ន្ធព័ត៌មានកសិកម្ម*** | បង្កើនលទ្ធភាពអាន និងយល់ពីទីផ្សារ | ការលំបាកក្នុងការទទួលបានព័ត៌មានទីផ្សារ ដែលសហគមន៍ជនជាតិដើមភាគតិចជួបប្រទះ | រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយឱ្យសមស្របតាមស្ថានភាពរបស់សហគមន៍ជនជាតិដើមភាគតិច |
| ***២.២៖ ការគ្រប់គ្រងគុណភាព*** | ការបង្កើនសុខភាពរុក្ខជាតិ និងសត្វ | ការលំបាកក្នុងការចូលរួមក្នុងប្រព័ន្ធទាំងនេះ ដោយសារតែការមិនចាំអក្សរ | រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយឱ្យសមស្របតាមស្ថានភាពរបស់សហគមន៍ជនជាតិដើមភាគតិច |